សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឡុង សីហា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **សឿន សោភ័ណ**


ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ
ជំនាន់ទី ៩ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឡុង សីហា** ជានិស្សិតអាហារូបករណ៍ បានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែករដ្ឋបាលសាធារណៈ ជំនាន់ទី៩ ឆ្នាំ២០១៥-២០១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមសម្តែងនូវ
## ការទទិច្ចគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការចំពោះ

- **លោកឪពុក និងអ្នកម្តាយ** ដែលបានបង្កើតរូបរាងកាយ និងបីបាច់ថែរក្សាចិញ្ចឹមកូន អប់រំទូន្មានកូន តាំងពី តូចដល់ធំ និងបានបញ្ជូនកូនឱ្យបានរៀនសូត្រមានចំណេះដឹង រហូតដល់ពេលបច្ចុប្បន្ន គឺជាគុណូបការៈគុណយ៉ាងអនេកប្បការ និងវិសេសថ្លៃថ្លាបំផុត ដែលមិនអាចមានអ្វីមកកាត់ថ្លៃបាន របស់លោកអ្នកមានគុណទាំងទ្វេ ។
- **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង** ដែលបានខិតខំគ្រប់គ្រង ដឹកនាំ សាកលវិទ្យាល័យ ឱ្យមានគុណភាពអប់រំខ្ពស់។ ទន្ទឹមនឹងនេះក៏សូមថ្លែងអំណរគុណ ដល់ **លោក លោកស្រី** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យ ដែលបានខំខិតបង្ហាត់បង្រៀន និស្សិតគ្រប់ៗរូប កន្លងមកឱ្យក្លាយជាធនធានដ៏សម្រាប់សង្គម។
- ជាពិសេស **បណ្ឌិត សឿន សោភ័ណ** ជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានគតិបណ្ឌិត និងគុណធម៌ ផ្តល់នូវកិត្តិយស ដោយចំណាយពេលដ៏មានតម្លៃរបស់ **លោកបណ្ឌិត** ធ្វើការណែនាំ និងជួយជ្រោមជ្រែងផ្តល់នូវគំនិត យោបល់ និងជួយកែសម្រួលកំហុសឆ្គងនានាដែលមាននៅក្នុងពេលសរសេរសារណាមួយនេះ។
- មិត្តភក្តិ ទាំងអស់ដែលរៀនក្នុងថ្នាក់ P4B1 ទាំងអស់ ដែលតែងតែផ្តល់នូវឯកសារនានាដែលពាក់ព័ន្ធនឹងប្រធានបទ និងលើកទឹកចិត្តក្នុងពេលធ្វើសារណានេះ។

ជាទីបញ្ចប់ ខ្ញុំសូមគោរពជូនពរដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង បណ្ឌិត សឿន សោភ័ណ និងលោក លោកស្រី** សូមឱ្យជួបប្រទះពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ស្តីពី **កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់** គឺជាស្នាដៃ និងជាសមិទ្ធផលនៃការខិតខំប្រឹងប្រែងក្នុងសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទ ដោយបានស្វែងរកឯកសារពីគ្រប់មជ្ឈដ្ឋាន ដើម្បីគាំទ្រប្រធានបទ។ សារណានេះបានឆ្លុះបញ្ចាំងនូវសមត្ថភាព ដែលខ្ញុំមាន និងទទួលបានពីការសិក្សាស្រាវជ្រាវពីឯកសារនានាដែលពាក់ព័ន្ធ ដើម្បីបកស្រាយនូវប្រធានបទមួយនេះឱ្យបានល្អ។

ប្រធានបទដែលខ្ញុំបាទ បានសម្រេចចិត្តជ្រើសរើសមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ គឺជាប្រធានបទដែលកើតចេញពីការសង្កេតឃើញជាក់ស្តែង និងឆន្ទះចង់សិក្សាស្រាវជ្រាវ ព្រមទាំងមានការជម្រុញពីសាស្ត្រាចារ្យ និងមិត្តរួមថ្នាក់ផងដែរ។ម្យ៉ាងទៀតដោយសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាកំពុងតែយកចិត្តទុកយ៉ាងខ្លាំង ក្នុងការធ្វើកំណែទម្រង់ទៅលើវិមជ្ឈការថ្នាក់ឃុំ សង្កាត់នេះ ។ ជាពិសេស ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់សម្រាប់អាណត្តិទី៤ ក៏ជិតមកដល់ទៀត គឺនៅឆ្នាំ២០១៧ ខាងមុខនេះ។ ពិតណាស់ដែលវិមជ្ឈការឃុំ សង្កាត់ កំពុងតែត្រូវបានធ្វើកំណែទម្រង់នៅឡើយ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានឱកាសជាច្រើនដល់រាជរដ្ឋាភិបាល ក្នុងកិច្ចបន្តកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់។ ជាក់ស្តែងក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានបង្កើតក្នុងឆ្នាំ២០០៥ ដូចគ្នា ដែលសំដៅឱ្យដំណើរការរដ្ឋបាលឃុំ សង្កាត់កាន់តែល្អប្រសើរ។ ក្រៅពីនេះកម្មវិធីជាតិ និងកម្មវិធីនយោបាយនានារបស់រាជរដ្ឋាភិបាលបានត្រួសត្រាយផ្លូវបន្ថែម បម្រើឱ្យការងារកំណែទម្រង់នេះបានសម្រេចដោយជោគជ័យ។ ដោយមើលឃើញដូចនេះ ទើបខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទនេះ មកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

សារណាមួយនេះ ត្រូវបានបញ្ចប់ដោយជោគជ័យ តែមិនមែនថាមិនមានកំហុសឆ្គងកើតឡើងនោះឡើយ។ ភាពខុសឆ្គងដែលកើតមានឡើងក្នុងសារណានេះ ដោយសារតែខ្ញុំបាទម្នាក់ឯងមានការពិបាកក្នុងការស្វែងរកឯកសារ និងព័ត៌មានដែលពាក់ព័ន្ធ។ ដូចនេះខ្ញុំ សូមការអភ័យទោសទុកជាមុនពីសំណាក់ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមិត្តនិស្សិតអ្នកអានទាំងអស់នូវរាល់កំហុសទាំងឡាយដែលកើតមាន។ ខ្ញុំបាទនឹងទទួលនូវរាល់មតិរិះគន់ កែលម្អកំហុសឆ្គង ដោយសេចក្តីត្រេកអរបំផុត។

# មាតិកា


**សេចក្តីថ្លែងអំណរគុណ**

**អារម្ភកថា**

**អក្សរកាត់** ........................................ iv

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១ ទិដ្ឋភាពទូទៅនៃរដ្ឋបាលឃុំ សង្កាត់** ........................................ ៤

**១.១. សញ្ញាណទូទៅនៃរដ្ឋបាលឃុំ សង្កាត់** ........................................ ៤

**១.២. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់** ........................................ ៥

**១.៣. តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់** ........................................ ៦

១.៣.១. តួនាទីបម្រើកិច្ចការមូលដ្ឋាន ........................................ ៦

១.៣.២. តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ........................................ ៧

**១.៤. ការអភិវឌ្ឍឃុំ សង្កាត់** ........................................ ៨

១.៤.១. ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ........................................ ៨

១.៤.២. ការត្រួតពិនិត្យ និងវាយតម្លៃ ........................................ ៩

**១.៥. ប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់** ........................................ ៩

១.៥.១. ហិរញ្ញវត្ថុឃុំ សង្កាត់ ........................................ ៩

១.៥.២. ទ្រព្យសម្បត្តិឃុំ សង្កាត់ ........................................ ១០

១.៥.៣. មូលនិធិឃុំ សង្កាត់ ........................................ ១១

១.៥.៤. ថវិកាឃុំ សង្កាត់ ........................................ ១១

**ជំពូកទី២ គោលការណ៍សំខាន់ៗនៃកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់** ........................................ ១២

**២.១. ភាពជាតំណាង** ........................................ ១២

**២.២. ការចូលរួមរបស់ប្រជាពលរដ្ឋ** ........................................ ១៣

២.២.១. ប្រភេទនៃការចូលរួម ........................................ ១៤

២.២.១.១. ការចូលរួមដោយផ្ទាល់ ........................................ ១៤

២.២.១.២. ការចូលរួមតាមរយៈអ្នកតំណាង ........................................ ១៤

២.២.២. វិធីសាស្ត្រដើម្បីជម្រុញការចូលរួម....................................................................១៥
**២.៣. តម្លាភាព**...........................................................................................................១៥
**២.៤. គណនេយ្យភាព និងការឆ្លើយតប**....................................................................... ១៦
២.៤.១. ការលើកកម្ពស់តម្លាភាព និងភាពងាយទទួលបាននូវព័ត៌មានអំពីស្តង់ដារ ថវិកា និងការបំពេញការងារ........................................................................................... ១៧
២.៤.២. ការសម្របសម្រួលឱ្យមានការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋទៅលើសកម្មភាព និងការផ្តល់សេវាកម្មមូលដ្ឋាន...................................................................... ១៨
២.៤.៣. ការលើកកម្ពស់សមត្ថភាពយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកា..................... ១៨
២.៤.៤. ការគាំទ្រដល់តួអង្គនានា និងការកសាងសមត្ថភាព ដល់តួអង្គទាំងនេះ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានានៃគណនេយ្យភាពសង្គម ........................................................................................................... ១៨
២.៤.៥. ការប្រមូលមេរៀន បទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន .១៩
**២.៥. ប្រសិទ្ធភាពការងារ**..........................................................................................១៩
២.៥.១. ការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ..........................................................២០
២.៥.២. ការអនុវត្តសកម្មភាពជាអាទិភាពខ្ពស់............................................................២០
២.៥.៣. ជៀសវាងអនុវត្តការិយាធិបតេយ្យ ................................................................... ២១
២.៥.៤. ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ ............................ ២១
២.៥.៥. គ្មានអំពើពុករលួយ ......................................................................................... ២១
២.៥.៦. ការសម្រេចចិត្តតាមបែបវិមជ្ឈការ .................................................................. ២១
**២.៦. ការផ្ទេរមុខងារ និងធនធាន**................................................................................ ២២
**២.៧. ការអភិវឌ្ឍសមត្ថភាព**.........................................................................................២៣
២.៧.១. យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាព........................................................................២៤
២.៧.២. យន្តការអភិវឌ្ឍន៍សមត្ថភាព ..........................................................................២៥
**២.៨. ការកាត់បន្ថយភាពក្រីក្រ**..................................................................................... ២៦
**២.៩. វិមជ្ឈការហិរញ្ញវត្ថុ**............................................................................................. ២៦

**ជំពូកទី៣ លទ្ធផលដែលសម្រេចបាន** ........ ២៨
**៣.១. ភាពជាតំណាង** ........ ២៩
**៣.២. មុខងារ និងធនធាន** ........ ២៩
៣.២.១ មុខងារជារដ្ឋបាលទូទៅរបស់ឃុំ សង្កាត់ ........ ២៩
៣.២.២. ការអភិវឌ្ឍរបស់ឃុំ សង្កាត់ ........ ៣១
**៣.៣. គណនេយ្យភាព និងការឆ្លើយតប** ........ ៣២
**៣.៤. ការចូលរួម** ........ ៣៤
**៣.៥. ការអភិវឌ្ឍសមត្ថភាព** ........ ៣៦
**៣.៦. ភាពក្រីក្រ** ........ ៣៨
**២.៧. វិមជ្ឈការហិរញ្ញវត្ថុ** ........ ៤១
**ជំពូកទី៤ ការវិភាគទិន្នន័យ និងរបកគំហើញ** ........ ៤៧
**៤.១. វិភាគទិន្នន័យដែលរកបាន** ........ ៤៧
៤.១.១. ភាពជាតំណាង ........ ៤៧
៤.១.២. មុខងាររបស់ឃុំ សង្កាត់ ........ ៤៧
៤.១.៣. ការអភិវឌ្ឍសមត្ថភាព ........ ៤៨
៤.១.៤. គណនេយ្យភាព និងការឆ្លើយតប ........ ៤៩
៤.១.៥. ហិរញ្ញវត្ថុ ........ ៥០
៤.១.៦. ភាពក្រីក្រ ........ ៥១
**៤.២. របកគំហើញ** ........ ៥១
៤.២.១. ចំណុចខ្លាំង ........ ៥១
៤.២.២. ចំណុចខ្សោយ ........ ៥២
**សេចក្ដីសន្និដ្ឋាន** ........ ៥៤
**អនុសាសន៍** ........ ៥៦
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

គ.ជ.អ.ប = គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ផអ៣ = ផែនការអនុវត្តរយៈពេលបីឆ្នាំ

UNICEF = United Nations International Children's Emergency Fund (អង្គការមូលនិធិរបស់អង្គការសហប្រជាជាតិសម្រាប់កុមារ)

UNDP = United Nations Development Programme (កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ)

WB = World Bank (ធនាគារពិភពលោក)

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

រដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្កើតឡើង និងបានដំណើរការអស់រយៈពេលជាង ១០ឆ្នាំមកហើយ ដោយអនុវត្តទៅតាមគោលនយោបាយវិមជ្ឈការដូចដែលមានចែងក្នុងច្បាប់។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺច្បាប់គ្រឹះមួយ ដែលធ្វើឱ្យឃុំ សង្កាត់ អនុវត្តតាមបែបវិមជ្ឈការដោយពិតប្រាកដ។

ទោះជាយ៉ាងណាក៏ដោយ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បែបវិមជ្ឈការនៅកម្ពុជាពីឆ្នាំ ២០០១មកនេះ មិនសូវជាធ្វើដំណើរដោយរលូនប៉ុន្មានទេ។ ដោយមើលឃើញពីលទ្ធផលកន្លងមកដែលឃុំ សង្កាត់បានសម្រេច ហាក់ដូចជាមិនទាន់ឆ្លើយតបទៅតាមអ្វីដែលរាជរដ្ឋាភិបាលចង់បានក៏ដូចជាគោលបំណងក្នុងការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន និងការអភិវឌ្ឍសេដ្ឋកិច្ចឱ្យបានល្អនៅឡើយទេ។ ទន្ទឹមនឹងនេះ សង្កេតឃើញពីការបង្កើតឡើងនូវលិខិតបទដ្ឋានគតិយុត្តិ របស់រាជរដ្ឋាភិបាល ដែលមានការពាក់ព័ន្ធទៅនឹងគោលការណ៍ ត្រូវធ្វើកំណែទម្រង់ ដើម្បីគាំទ្រនូវប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការឃុំ សង្កាត់ឱ្យប្រសើរឡើង។ ចំណុចនេះអាចធ្វើការសន្និដ្ឋានបានថា រដ្ឋបាលឃុំ សង្កាត់ពិតជាជួបនូវបញ្ហារាំងស្ទះមែន។

ការធ្វើកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់នេះ គឺត្រូវការពេលវេលាដ៏យូរ ទើបអាចសម្រេចជោគជ័យបានល្អប្រសើរ។ រដ្ឋបាលឃុំ សង្កាត់នៅកម្ពុជាយើង គឺនៅមានអាយុតិចនៅឡើយទេ ឬអាចនិយាយថា នៅក្មេងខ្ចី។ ភាពក្មេងខ្ចីនៃរដ្ឋបាលឃុំ សង្កាត់ ដែលបណ្តាលឱ្យកើតមាននូវបញ្ហា ឬជួបនឹងឧបសគ្គខ្លះៗ ក្នុងការអនុវត្ត។ តែទោះជាយ៉ាងក៏ដោយ បើមានបញ្ហា ឬឧបសគ្គ ត្រូវតែព្យាយាមដោះស្រាយ កែលម្អ ទោះជាមិនអាចលុបបំបាត់ទាំងអស់ក៏ដោយ តែត្រូវធ្វើការដោះស្រាយ កែលម្អតាមលទ្ធភាពដែលអាចធ្វើបាន។ ហេតុនេះហើយ ការធ្វើកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលក៏បានព្យាយាមកែលម្អ ដោយបានបង្កើតលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងបញ្ហាដែលកើតមានឡើងក្នុងពេលកំពុងអនុវត្ត។ ដូចនេះទោះបីជាយ៉ាងណា ប្រសើរជាងការដែលមិនបានធ្វើអ្វីទាំងអស់នោះដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ស្ថិតនៅក្នុងប្រធានបទស្តីពី "កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់" បានចោទជាបញ្ហាមួយចំនួនដូចជា៖

តើទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាមបែបវិមជ្ឈការមានលក្ខណៈដូចម្តេច?

ក្នុងការងារកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ តើគេបានផ្តោតទៅលើគោលការណ៍អ្វីខ្លះ?

តើការធ្វើកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ ទទួលបាននូវលទ្ធផលអ្វីខ្លះ?

## ៣. ដែនកំណត់នៃការស្រាវជ្រាវ

ការកំណត់នូវដែនកំណត់នូវការស្រាវជ្រាវ នឹងមិនធ្វើឱ្យការបកស្រាយមានការចាកប្រធាន ឬលើសដែនកំណត់។ ដូច្នេះសម្រាប់ប្រធានបទស្តីពី "កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់"នេះ ខ្ញុំសូមធ្វើការបកស្រាយតែទៅលើកំណែទម្រង់សម្រាប់តែរដ្ឋបាលថ្នាក់ឃុំ សង្កាត់ និងការធ្វើកំណែទម្រង់ទៅលើគោលការណ៍សំខាន់ៗនៃកំណែទម្រង់ប៉ុណ្ណោះ ព្រមជាមួយនិងការបង្ហាញនូវលទ្ធផលដែលមានចាប់ពីឆ្នាំ២០០១ មកដល់ឆ្នាំ២០១៦នេះ ។

## ៤. គោលបំណងនៃការស្រាវជ្រាវ

ដោយសង្កេតឃើញថា រាជរដ្ឋាភិបាលបានប្រឹងប្រែង និងប្តេជ្ញាយ៉ាងមុតមាំក្នុងការធ្វើកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាពការងារ ធ្វើឱ្យលទ្ធិប្រជាធិបតេយ្យមានការរីចម្រើន និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានភាពល្អប្រសើរ។ ដូច្នេះក្នុងនាមជានិស្សិត និងជាប្រជាពលរដ្ឋរបស់ប្រទេសកម្ពុជា ត្រូវតែធ្វើការសិក្សាស្រាវជ្រាវឱ្យបានយល់ច្បាស់ និងចែករំលែកដល់អ្នកអានទាំងអស់បានជ្រាបជាព័ត៌មាន។

## ៥. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទរបស់ខ្ញុំ គឺត្រូវបានប្រើប្រាស់វិធីសាស្ត្របែបគុណភាព ដោយយោងទៅលើប្រភពឯកសារដូចខាងក្រោម៖

- លិខិតបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការរដ្ឋបាលឃុំ សង្កាត់។
- សៀវភៅ និងឯកសារពាក់ព័ន្ធនឹងការធ្វើកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់។
- របាយការណ៍ និងឯកសារនានា ដែលបង្ហាញពីលទ្ធផលពាក់ព័ន្ធកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់។
- គេហទំព័ររបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ៦. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះ ដំណើរការល្អ និងប្រកបដោយភាពជោគជ័យ សារណានេះត្រូវបានបែងចែកដូចតទៅ៖

សេចក្តីថ្លែងអំណរគុណ

អារម្ភកថា

អក្សរកាត់

សេចក្តីផ្តើម

ជំពូកទី១ ទិដ្ឋភាពទូទៅនៃរដ្ឋបាលឃុំ សង្កាត់

ជំពូកទី២ គោលការណ៍សំខាន់ៗនៃកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់

ជំពូកទី៣ លទ្ធផលដែលសម្រេចបាន

ជំពូកទី៤ ការវិភាគទិន្នន័យ និងរបកគំហើញ

សេចក្តីសន្និដ្ឋាន

អនុសាសន៍

គន្ថនិទ្ទេស

ឧបសម្ព័ន្ធ

# ជំពូកទី១
# ទិដ្ឋភាពទូទៅនៃរដ្ឋបាលឃុំ សង្កាត់

## ១.១. សញ្ញាណទូទៅនៃរដ្ឋបាលឃុំ សង្កាត់

នៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដែលតំណាងរាស្ត្រ ត្រូវបានបោះឆ្នោតចេញពីប្រជាពលរដ្ឋ។[1] ការគ្រប់គ្រងរដ្ឋបាល ត្រូវបានបែងចែកដាច់ពីគ្នាគឺ មានខេត្ត និងក្រុង ដែលខេត្តចែកជាស្រុក ហើយស្រុកចែកជាឃុំ ឯក្រុង ត្រូវចែកជាខណ្ឌ ហើយខណ្ឌ ចែកជាសង្កាត់។[2] ថ្វីបើមានកំណត់យ៉ាងច្បាស់ ពីការបង្កើតនូវរដ្ឋបាលចំណុះខេត្ត និងក្រុង រហូតដល់ថ្នាក់មូលដ្ឋានឃុំ សង្កាត់ តែគេមិនទាន់ឃើញមានលេចឡើងជាទម្រង់គ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិដូចជាស្រុក ខណ្ឌ និងឃុំ សង្កាត់នៅឡើយទេ។

ក្រោយពីការបោះឆ្នោតឆ្នាំ១៩៩៨ បានបញ្ចប់ រដ្ឋាភិបាលនាអាណត្តិទី២នេះ មានគម្រោងរៀបចំកែប្រែ ការគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន ពីបែបមជ្ឈការ ទៅតាមបែបវិមជ្ឈការវិញ។[3] ដែលវិមជ្ឈការគឺជារបៀបរៀបចំរដ្ឋបាលមួយ ដែលអនុញ្ញាតឱ្យមានរចនាសម្ព័ន្ធនានាផ្សេងពីរចនាសម្ព័ន្ធរបស់រដ្ឋ ដើម្បីឱ្យមានលទ្ធភាពគ្រប់គ្រងភារកិច្ចរដ្ឋបាលទាំងឡាយនៅមូលដ្ឋាន។[4] រាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្តីត្រូវរបស់មូលដ្ឋាន។ ដើម្បីរៀបចំការគ្រប់គ្រងថ្នាក់មូលដ្ឋានតាមបែបវិមជ្ឈការនេះ រដ្ឋាភិបាលបានរៀបចំគម្រោងបោះឆ្នោត នៅថ្នាក់ឃុំ សង្កាត់។ គួររំលឹកថានៅក្នុងអាណត្តិទី១ រាជរដ្ឋាភិបាលក៏មានគម្រោងរៀបចំការបោះឆ្នោតមេឃុំ ចៅសង្កាត់ ដែលនឹងត្រូវបោះឆ្នោតនៅក្នុងអំឡុងឆ្នាំ១៩៩៧ដែរ តែដោយសារព្រឹត្តិការណ៍ប្រឈមមុខដាក់គ្នាដោយកម្លាំងអាវុធមួយ នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ គម្រោងនៃការបោះឆ្នោតនោះ ក៏ត្រូវអាក់ខាន និងត្រូវបានពន្យារពេល។[5] តែនៅអាណត្តិទី២ រាជរដ្ឋាភិបាលបានសម្រេចគោលដៅមួយជោគជ័យល្អប្រសើរ ដោយមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១។ ទន្ទឹមនឹងនេះ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃខែឆ្នាំជាមួយនិងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ផងដែរ។ មកដល់

---

[1] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា៥១ថ្មី។

[2] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា១៤៥ថ្មី។

[3] ខុមែប្រូល, *ស្វ័យភាពក្រុមប្រឹក្សាឃុំ-សង្កាត់ និងគោលនយោបាយវិមជ្ឈការ*, (ភ្នំពេញ៖ ០៨ កញ្ញា ២០០៨), http://kh.cisa.org.kh/index.php?option=com_content&task=view&id=776&Itemid=31(ថតចម្លងថ្ងៃទី២០ មិថុនា ២០១៦)។

[4] អ៊ុង ចំរើន, *សិក្ខាប័ននីតិរដ្ឋបាល*, បោះពុម្ពលើកទី១ (ភ្នំពេញ៖ ភ្នំពេញ, សីហា ២០១១), ៦។

[5] ដូច៣។

ពេលបច្ចុប្បន្ននេះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដំណើរការបាន បីអាណត្តិមក ហើយ។ ដោយការបោះឆ្នោតលើកទី១ ធ្វើឡើងកាលពីខែកុម្ភៈ ឆ្នាំ២០០២ លើកទី២ កាលពីខែ មេសា ឆ្នាំ២០០៧ លើកទី៣ កាលពីខែមិថុនា ឆ្នាំ២០១២ ហើយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់នៅអាណត្តិទី៤ នឹងត្រូវធ្វើឡើងក្នុងឆ្នាំ២០១៧ ខាងមុខនេះ។

## ១.២. រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលក្រុមប្រឹក្សាឃុំ សង្កាត់បានមកពីការបោះឆ្នោតជាសកល ដោយសេរី ត្រឹមត្រូវនិងមានភាពយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ។[6] ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមាន ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ហើយប្រធានក្រុមប្រឹក្សាឃុំ សង្កាត់នេះ ក៏ជាមេឃុំ ចៅសង្កាត់ផង ដែរ។[7] ក្នុងការងារប្រចាំថ្ងៃរបស់មេឃុំ សង្កាត់គឺមានអ្នកជំនួយការដូចខាងក្រោម៖

ចំពោះមេឃុំ អ្នកជំនួយការមានពីររូប៖

- ជំទប់ទី១ មួយរូប
- ជំទប់ទី២ មួយរូប។

ចំពោះចៅសង្កាត់ អ្នកជំនួយការមានពីររូប៖

- ចៅសង្កាត់រងទី១ មួយរូប
- ចៅសង្កាត់រងទី២ មួយរូប។[8]

ក្នុងរដ្ឋបាលឃុំ សង្កាត់ ត្រូវមានបុគ្គលិកដែលមានក្របខ័ណ្ឌនៃក្រសួងមហាផ្ទៃមួយរូប ធ្វើជាស្មៀនឃុំ សង្កាត់ ដែលត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានភារកិច្ចជួយកិច្ចការឃុំ សង្កាត់ និងធានានិរន្តរភាពកិច្ចការរដ្ឋបាលទាំងឡាយរបស់ឃុំ សង្កាត់។[9]

ដើម្បីធ្វើឱ្យការងាររបស់ឃុំ សង្កាត់ដំណើរការល្អ ចំពោះការងារដែលមានសារៈសំខាន់ ឬ ចាំបាច់នោះ ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួនបាន ដោយត្រូវសម្រេចដោយក្រុមប្រឹក្សាឃុំ សង្កាត់ជាមុនសិន។ ម្យ៉ាងទៀតដើម្បីលើកកម្ពស់ប្រសិទ្ធភាព ការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិ ម្នាក់ សម្រាប់ភូមិនីមួយៗ ចំណុះឃុំ សង្កាត់របស់ខ្លួន។[10]

[6] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤។
[7] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា២៥។
[8] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា២៦។
[9] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា២៨។
[10] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៣០។

យោងតាមមាត្រា ៣១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ មេភូមិមានភារកិច្ចដូចតទៅ៖

- អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ សង្កាត់ ឬមេឃុំ ចៅសង្កាត់ប្រគល់ឱ្យដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ។
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន។
- ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។

និងរបៀបរបបធ្វើការងារ និងភារកិច្ចដទៃទៀត ដែលនឹងត្រូវកំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ១.៣. តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

ថ្វីបើឃុំ សង្កាត់ មានសមត្ថកិច្ចគ្រប់គ្រងដែនដីរដ្ឋបាលតូចតែពិតមែន តែមានតួនាទីសំខាន់ អភិវឌ្ឍមូលដ្ឋាន ពង្រឹងសុខសណ្តាប់ធ្នាប់ និងចូលរួមរក្សាសុខសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ហើយក៏មានតួនាទីជាភ្នាក់ងាររដ្ឋដ៏ល្អ ដែលត្រូវគោរព និងប្រតិបត្តិតាមលិខិតបទដ្ឋានគតិយុត្តិនានាដែលនៅជាធរមានផងដែរ។ រដ្ឋបាលឃុំ សង្កាត់មានតួនាទីជម្រុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។[11] រដ្ឋបាលឃុំ សង្កាត់ត្រូវរ៉ាប់រងនូវតួនាទីច្រើន តែតួនាទីសំខាន់របស់ឃុំ សង្កាត់ គឺបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។ និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។[12]

### ១.៣.១. តួនាទីបម្រើកិច្ចការមូលដ្ឋាន

ឃុំ សង្កាត់ មានតួនាទីជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ឃុំ សង្កាត់ ត្រូវផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ និងការមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ ពោលគឺរក្សាឱ្យបាននូវនិរន្តរភាពនៃសេវាសាធារណៈ។ ឃុំ សង្កាត់ ត្រូវធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ក្នុងដែនសមត្ថកិច្ចនៃឃុំ

[11] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤១។

[12] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤២។

សង្កាត់នីមួយៗ និងការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ ទៅតាមទំនៀមទម្លាប់ប្រពៃណីក្នុងតំបន់នីមួយៗ។ ក្រៅពីនេះឃុំ សង្កាត់ ក៏ត្រូវលើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យប្រជាពលរដ្ឋអាចចូលរួមក្នុងកិច្ចការអភិវឌ្ឍជាមួយឃុំ សង្កាត់។

## ១.៣.២. តួនាទីជាភ្នាក់ងារតំណាងរដ្ឋ

រដ្ឋបាលឃុំ សង្កាត់ ជាភ្នាក់ងារមួយតំណាងរដ្ឋ ដែលតួនាទីដូចមានចែងច្បាប់អង្គការ ហើយមុខងារ និងតួនាទីដទៃទៀត ដែលជាភារកិច្ចរបស់ក្រសួង ស្ថាប័ននៃរដ្ឋបាលថ្នាក់លើ ក្នុងធ្វើប្រតិភូកម្មមកឱ្យឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិត បទដ្ឋានពាក់ព័ន្ធ ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើន សមត្ថភាព និងផ្តត់ផ្គង់ មធ្យោបាយ សម្ភារ ថវិកាសម្រាប់អនុវត្ត ។ ប្រតិភូកម្មខាងលើនេះ ត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។[13] ដោយឡែកឃុំ សង្កាត់ គ្មានសិទ្ធិអំណាចសម្រេចលើវិស័យមួយចំនួនដូចខាងក្រោម៖

- ព្រៃឈើ
- ប្រៃសណីយ៍ ទូរគមនាគមន៍
- ការពារប្រទេស
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។[14]

ក្រៅពីតួនាទីជាតំណាងរបស់ប្រជាពលរដ្ឋ និងភ្នាក់ងារតំណាងរបស់រដ្ឋ ឃុំ សង្កាត់ក៏មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិដែរ។ អំណាចបញ្ញត្តិរបស់ឃុំ សង្កាត់ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ សម្រាប់ គ្រប់គ្រងកិច្ចការនានា ក្នុងក្របខ័ណ្ឌ តួនាទី មុខងារ និងអំណាចរបស់ខ្លួន ។ ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ ប៉ុន្តែដីកាឃុំ សង្កាត់នេះមិនអាចផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិ

[13] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤៤។

[14] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤៥។

ដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ស្មារតីរដ្ឋធម្មនុញ្ញ ផ្ទុយនឹងច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ បានឡើយ បើពុំដូចនេះទេ ដីកាឃុំ សង្កាត់នឹងត្រូវមោឃៈដាច់ខាត។[15] រីឯអំណាចប្រតិបត្តិគឺ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវដីកា ដែលបានសម្រេចរួចហើយ។

## ១.៤. ការអភិវឌ្ឍឃុំ សង្កាត់

### ១.៤.១. ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ឃុំ សង្កាត់ ជារដ្ឋបាលនៅដាច់ឆ្ងាយពីរដ្ឋបាលកណ្តាល តែនៅក្បែរប្រជាជនជាងរដ្ឋបាលដទៃទៀត ហើយក៏ដឹងច្បាស់ពីតម្រូវការរបស់ប្រជាពលរដ្ឋ ក៏ដូចជាស្ថានភាពនៃមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗផងដែរ។ ដូច្នេះការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗ ត្រូវពឹងផ្អែកលើវិធានការ និងការរៀបចំគម្រោងនានារបស់ឃុំ សង្កាត់នីមួយៗ ស្របតាមលទ្ធភាពផ្ទាល់ខ្លួននីមួយៗ។

ការរៀបចំ អនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយគោលបំណងនៃការបង្កើតផែនការអភិវឌ្ឍន៍នេះ គឺដើម្បីកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។[16] ថ្វីបើឃុំ សង្កាត់ត្រូវបានកំណត់ ឱ្យរៀបចំនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ដោយខ្លួនឯង និងទៅតាមលទ្ធភាពនៃឃុំ សង្កាត់រៀងៗខ្លួនក៏ដោយ តែផែនការអភិវឌ្ឍន៍នេះ គឺត្រូវតែស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ។[17]

ផែនការអភិវឌ្ឍន៍ គឺមានសារៈសំខាន់ ដែលក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ និងអនុម័ត ហើយធ្វើការកែសម្រួលនូវទិន្នន័យថ្មីៗប្រែប្រួលជារាល់ឆ្នាំ នៅពេលស្ថិតក្នុងអាណត្តិ ឬក្នុងឆ្នាំទី១ នៃអាណត្តិក្រុមប្រឹក្សាដែលទើបជាប់ឆ្នោត។[18] "ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំ ឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង ។ ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ក៏ត្រូវកំណត់ផងដែរ នូវវិធីសាស្ត្រ និងមធ្យោបាយនានា ដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល។"[19]

ករណីដែលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ណាមួយ ធ្វើឡើងមិនស្របតាមច្បាប់ទេនោះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នឹងធ្វើការណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ កែតម្រូវឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ

[15] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤៩។
[16] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦០។
[17] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦១។
[18] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦២។
[19] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦៤។

ធ្វើការកែសម្រួលផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[20]

### ១.៤.២. ការត្រួតពិនិត្យ និងវាយតម្លៃ

បន្ទាប់ពីការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់រួច ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃទៅលើសកម្មភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ កម្មវិធី គម្រោង និងការផ្តល់សេវាសាធារណៈនានារបស់ឃុំ សង្កាត់ ប្រកបដោយតម្លាភាព ជាមួយនឹងការទទួលខុសត្រូវខ្ពស់របស់អ្នកផ្តល់សេវា។[21] ពេលខ្លះ ដោយស្របទៅតាមស្ថានភាពជាក់ស្តែង ក្រុមប្រឹក្សាឃុំ សង្កាត់អាចនឹងជ្រើសរើសយកសមាសភាពផ្សេងទៀតមកអនុវត្តផែនការ កម្មវិធី និងគម្រោងនានារបស់ឃុំ សង្កាត់ ប៉ុន្តែក្រុមប្រឹក្សាឃុំ សង្កាត់ នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃចំពោះការអនុវត្តរបស់សមាសភាពនោះ។[22]

ម្យ៉ាងទៀត ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការរបស់ឃុំ សង្កាត់ "រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវណែនាំដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីវិធីសាស្រ្តផ្សេងៗក្នុងការអនុវត្តផែនការ និងក្នុងការត្រួតពិនិត្យ វាយតម្លៃរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ចំពោះការប្រើប្រាស់មូលនិធិសម្រាប់ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់"[23]។

## ១.៥. ប្រព័ន្ធហិរញ្ញវត្ថុឃុំ សង្កាត់

ឃុំ សង្កាត់ ជានីតិបុគ្គលសាធារណៈ។ ឃុំ សង្កាត់ ជានីតិបុគ្គល ដែលត្រូវមានធនធានសម្រាប់ដំណើរការ សកម្មភាពរបស់ខ្លួន។ តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តម្រូវឱ្យឃុំ សង្កាត់ នីមួយៗ មាន ធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។[24] ដោយឡែកឃុំ សង្កាត់នីមួយៗ ត្រូវមានមូលនិធិឃុំ សង្កាត់រៀងៗខ្លួនបន្ថែមទៀត ដើម្បីធ្វើការផ្ទេរនូវប្រាក់ចំណូលពីជាតិ និងប្រាក់ចំណូលផ្សេងៗទៀតទៅឱ្យថវិកាឃុំ សង្កាត់។[25]

### ១.៥.១. ហិរញ្ញវត្ថុឃុំ សង្កាត់

ឃុំ សង្កាត់ជានីតិបុគ្គលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់កើតឡើងដោយការបោះឆ្នោតផ្ទាល់ពីប្រជាពលរដ្ឋ តាមលក្ខណៈប្រជាធិបតេយ្យ។ តាមអត្ថន័យទូទៅវិមជ្ឈការមានន័យថាសិទ្ធិអំណាច

[20] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦៥។
[21] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦៦។
[22] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦៧។
[23] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៦៨។
[24] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៧៣។
[25] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៧៧។

ការទទួលខុសត្រូវ និងធនធានមួយ ចំនួនត្រូវបានផ្ទេរពីរដ្ឋាភិបាលថ្នាក់ជាតិឱ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់។

តាមច្បាប់ស្តីពីការគ្រប់រដ្ឋបាលឃុំ សង្កាត់តម្រូវឱ្យឃុំ សង្កាត់មានសិទ្ធិទទួលចំណូលផ្ទាល់ ដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗនៅក្នុងមូលដ្ឋាន ឃុំ សង្កាត់របស់ខ្លួន។ ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋ សម្រាប់ថវិការបស់ខ្លួន ដែលធនធានទាំងនោះរួមមានៈ

- ការផ្ទេរទាំងមូល ឬមួយផ្នែកនូវប្រាក់ចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធដ៏ជាក់លាក់របស់រដ្ឋ
- ទាយជ្ជទាន និងធនធានវិភាជន៍ ឧបត្ថម្ភធន ឬអនុប្បទានដែលបានមកពីប្រាក់ចំណូលរដ្ឋ។ ធនធានវិភាជន៍ខាងលើនេះត្រូវផ្តល់ទៅឱ្យឃុំ សង្កាត់តាមរតនាគាររាជធានី ខេត្ត។[26]

ក្រៅពីតួនាទីតំណាងឱ្យប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឃុំ សង្កាត់ ក៏ភ្នាក់ងារតំណាងឱ្យរាជរដ្ឋាភិបាលដែរ។ ដូច្នេះនៅពេលដែលរាជរដ្ឋាភិបាល ផ្ទេរនូវមុខងារទៅឱ្យឃុំ សង្កាត់ ឃុំ សង្កាត់នឹងទទួលបាននូវប្រាក់កម្រៃ ដែលជាប្រាក់បន្ថែមពីលើប្រាក់ចំណូលរបស់ឃុំ សង្កាត់ ឬប្រាក់វិភាជន៍ផ្សេងៗដែលឃុំ សង្កាត់ទទួលបានពីប្រាក់ចំណូលរដ្ឋ។ ហើយបើក្នុងករណីដែលការប្រគល់អំណាច មុខងារទាំងនោះមានលក្ខណៈជាអចិន្ត្រៃយ៍ទៅឱ្យឃុំ សង្កាត់រាជរដ្ឋាភិបាលត្រូវរៀបចំឱ្យមានធនធានហិរញ្ញវត្ថុរយៈពេលយូរអង្វែងសម្រាប់ផ្តល់មកឱ្យឃុំ សង្កាត់ អនុវត្តមុខងារទាំងនោះ។[27]

### ១.៥.២. ទ្រព្យសម្បត្តិឃុំ សង្កាត់

ឃុំ សង្កាត់ មានសិទ្ធិទទួលបាននូវការផ្ទេរទ្រព្យសម្បត្តិមួយផ្នែករបស់រដ្ឋមកធ្វើជាទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ដោយត្រូវគ្រប់គ្រងឱ្យបានល្អនូវទ្រព្យសម្បត្តិទាំងនោះ ជាពិសេសត្រូវចេះថែរក្សានូវទ្រព្យសម្បត្តិដែលឃុំ សង្កាត់រកបានដោយខ្លួនឯង។ ឃុំ សង្កាត់ ត្រូវតែថែរក្សាការពារទ្រព្យសម្បត្តិដែលទទួលបានពីឱ្យបានគង់វង្ស និងអាចប្រើប្រាស់ទ្រព្យសម្បត្តិនោះ ដើម្បីទាញផលប្រយោជន៍បាន។ ឃុំ សង្កាត់ គ្មានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់នៃទ្រព្យសម្បត្តិដែលរដ្ឋប្រគល់ឱ្យដោយគ្មានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានយោបល់ឯកភាពរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ។[28]

[26] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៧៥។

[27] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៧៦។

[28] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៨១។

### ១.៥.៣. មូលនិធិឃុំ សង្កាត់

មូលនិធិឃុំ សង្កាត់ ត្រូវបានបង្កើតឡើង សម្រាប់ទទួលថវិកាដែលត្រូវវិភាជន៍ដោយរដ្ឋ។ "ការផ្ទេរប្រាក់ចំណូលពីជាតិទៅមូលនិធិខាងលើនេះត្រូវធ្វើឡើងទៅតាមរូបមន្ត ឬតាមអត្រាជាក់លាក់មួយ សម្រាប់ថេរៈវេលាយ៉ាងតិច ៣ឆ្នាំ និងមិនលើសពី ៥ឆ្នាំដែលកំណត់ដោយអនុក្រឹត្យ។"[29]

ក្រៅពីការទទួលថវិកាវិភាជន៍រដ្ឋ មូលនិធិឃុំ សង្កាត់ អាចទទួលថវិកាដែលបានមកពីអនុប្បទាន និងការខ្ចីពីប្រភពក្នុងប្រទេស និងក្រៅប្រទេស។[30]

### ១.៥.៤. ថវិកាឃុំ សង្កាត់

ថវិកា ជាចំណុចសំខាន់ ក្នុងការដំណើរការរដ្ឋបាលឃុំ សង្កាត់ឱ្យបានល្អ និងប្រើប្រាស់សម្រាប់អនុវត្តសកម្មភាព ផែនការ និងគម្រោងនានាក្នុងមូលដ្ឋាន។ ការអភិវឌ្ឍតិច ឬច្រើននៅក្នុងមូលដ្ឋានរបស់ឃុំ សង្កាត់ក៏ពឹងផ្អែកលើចំនួនថវិកានេះផងដែរ។ ម្យ៉ាងទៀតការប្រើប្រាស់ទោះតិច ឬច្រើន គឺត្រូវមានការរៀបចំទុកជាមុន ដើម្បីទទួលបានជោគជ័យទៅតាមលទ្ធភាពរបស់ឃុំ សង្កាត់នីមួយៗ។ ដូច្នេះ "ជារៀងរាល់ឆ្នាំឃុំ សង្កាត់ត្រូវរៀបចំ និងអនុម័តថវិការបស់ខ្លួន ទៅតាមទម្រង់មួយ និងអនុម័ត នៅក្នុងកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទមួយអនុលោមទៅតាមប្រព័ន្ធថវិកាជាតិ ហើយត្រូវមានតុល្យភាពរវាងចំណូលសរុប និងចំណាយសរុបនៃថវិការបស់ខ្លួន។ ដោយថវិកានេះត្រូវឆ្លុះបញ្ចាំងអំពីអាទិភាព និងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍ និងកម្មវិធី នយោបាយរបស់ឃុំ សង្កាត់។"[31] ដោយឡែក "ឃុំ សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់បានឡើយ ។ ឃុំ សង្កាត់មិនអាចធានារ៉ាប់រងចំពោះការខ្ចី រឺកាតព្វកិច្ចហិរញ្ញវត្ថុណាមួយបានឡើយ"[32]។

[29] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៧៧។
[30] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៧៨។
[31] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៧៩។
[32] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៨០។

# ជំពូកទី២
# គោលការណ៍សំខាន់ៗនៃកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់

ការងារកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ ត្រូវបានអនុវត្តជាច្រើនឆ្នាំមកហើយ ចាប់ពីការបង្កើតរដ្ឋបាលឃុំ សង្កាត់ឆ្នាំ២០០១មក។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានបើកឱកាសច្រើនផងដែរសម្រាប់ កិច្ចបន្តកំណែទម្រង់ប្រព័ន្ធវិមជ្ឈការឃុំ សង្កាត់នៅកម្ពុជា ឱ្យទទួលជោគជ័យ ដែលជាពិសេសគឺការអភិវឌ្ឍប្រជាធិបតេយ្យនៅមូលដ្ឋាន និងការអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន។ តែការធ្វើកំណែទម្រង់ គឺទាមទារនូវរយៈពេលវែង និងការបង្កើតលិខិតបទដ្ឋានគតិយុត្តិដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង សម្រាប់កំណែទម្រង់ឱ្យកាន់តែស៊ីជម្រៅ។

## ២.១. ភាពជាតំណាង

ក្នុងរបបប្រជាធិបតេយ្យ សិទ្ធិ និងអំណាចគឺជារបស់ប្រជាពលរដ្ឋ ប៉ុន្តែមិនបានប្រើប្រាស់នូវសិទ្ធិ និងអំណាចទាំងអស់ដោយខ្លួនឯងបានទេ។ ដូច្នេះប្រជាពលរដ្ឋត្រូវប្រើប្រាស់សិទ្ធិ និងអំណាចទាំងអស់តាមរយៈតំណាងរបស់ខ្លួន ហើយអ្នកតំណាងគឺត្រូវប្រើប្រាស់សិទ្ធិ និងអំណាចដោយគិតពីម្ចាស់សិទ្ធិ និងអំណាច ជាងនេះទៅទៀតគឺដើម្បីផលប្រយោជន៍ទូទៅ សម្រាប់ប្រជាពលរដ្ឋ។

ពិតណាស់ក្នុងរបបប្រជាធិបតេយ្យ ប្រជាជនគឺជាម្ចាស់ប្រទេស និងម្ចាស់អំណាច ដែលត្រូវប្រើប្រាស់សម្រាប់គ្រប់គ្រងរដ្ឋ។ តែការអនុវត្តអំណាចរបស់ប្រជាជន គឺមិនមែនដោយផ្ទាល់ទាំងអស់នោះទេ តែអំណាចទាំងនោះនឹងត្រូវបានអនុវត្តដោយតំណាងរបស់ប្រជាពលរដ្ឋទៅតាមតំបន់នីមួយៗ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងប្រជាធិបតេយ្យដ៏រឹងមាំ ។ ការធ្វើកំណែទម្រង់វិមជ្ឈការបើកឱកាសខាងនយោបាយ សម្រាប់ការកែលម្អភាពជាតំណាង នៅកម្រិតមូលដ្ឋាននៃគណបក្សនយោបាយ និងក្រុមប្រជាពលរដ្ឋមានភាពទន់ខ្សោយ រួមទាំងស្ត្រីផង។ នៅថ្នាក់មូលដ្ឋានឃុំ សង្កាត់ ប្រជាពលរដ្ឋមានតំណាងរបស់ខ្លួនជាក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកើតឡើងដោយការបោះឆ្នោតពីប្រជាពលរដ្ឋ។[33] ភាពជាតំណាង មិនត្រឹមតែឆ្លុះបញ្ចាំងនូវការយល់ដឹងពីគោលការណ៍ប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយតភ្ជាប់គម្លាងរវាងរដ្ឋ ឬអាជ្ញាធរ និងប្រជាពលរដ្ឋទៀតផង មានន័យថាប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសអ្នកតំណាង ហើយអ្នកតំណាងមានបេសកកម្មបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង ព្រោះអ្នកតំណាងដូចជាក្រុមប្រឹក្សាឃុំ សង្កាត់គឺនៅជិតប្រជាពលរដ្ឋ ប្រាកដជាដឹងច្បាស់ពីតម្រូវការរបស់ប្រជាពលរដ្ឋ។

[33] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៤, ១៩ មីនា ២០០១, មាត្រា៩ (ពីពេលនេះទៅហៅថាច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់)។

ហេតុដូចនេះហើយ ក្នុងនាមជាក្រុមប្រឹក្សាដែលកើតចេញពីប្រជាពលរដ្ឋ ត្រូវតែឈរខាងប្រជាពលរដ្ឋជានិច្ច។ ហើយត្រូវប្រើប្រាស់តួនាទីរបស់ខ្លួនតំណាងឱ្យប្រជាពលរដ្ឋ គិតពីផលប្រយោជន៍របស់ប្រជាពលរដ្ឋ ធំជាងផលប្រយោជន៍គណបក្សនយោបាយ។

## ២.២. ការចូលរួមរបស់ប្រជាពលរដ្ឋ

ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាចំណុចសំខាន់មួយនៃការធ្វើកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់។ ឃុំ សង្កាត់ត្រូវបើកឱ្យទូលាយ និងផ្សព្វផ្សាយព័ត៌មានទៅកាន់ប្រជាពលរដ្ឋ ដើម្បីឱ្យប្រជាពលរដ្ឋអាចចូលរួមក្នុងសកម្មភាពរបស់រដ្ឋបាលឃុំ សង្កាត់ ជាពិសេសការចូលរួមក្នុងធ្វើសេចក្ដីសម្រេច និងផ្ដល់យោបល់ទៅលើផែនការនានាសម្រាប់អភិវឌ្ឍឃុំ សង្កាត់។ ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាផ្នែកមួយដែលជួយបង្កើននូវប្រសិទ្ធភាពនៃសេចក្ដីសម្រេច ព្រោះគេអាចសម្រេចលើបញ្ហាណាមួយបានដោយជោគជ័យ បើមានការចូលរួមផ្លាស់ប្ដូរមតិយោបល់គ្នា ដើម្បីបំពេញនូវចន្លោះខ្វះខាត។ ផ្ទុយទៅវិញ គេក៏អាចដកចេញនូវចំណុចទាំងឡាយណាដែល វាអាចបណ្ដាលឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍ទូទៅផងដែរ។

ថ្វីបើការចូលរួមនេះមានសារៈសំខាន់យ៉ាងណាក៏ដោយ ប៉ុន្តែវានៅតែជាបញ្ហា ព្រោះប្រជាពលរដ្ឋភាគច្រើនទៅហើយ ដែលត្រូវរារាំងដោយឧបសគ្គដូចជា វប្បធម៌ និងសេដ្ឋកិច្ចជាដើម ដែលតែងកំណត់លើការចូលរួមរបស់ប្រជាពលរដ្ឋ។ ពិតណាស់បញ្ហាវប្បធម៌ គឺជាឧបសគ្គមួយដែលច្រើនតែកើតឡើងចំពោះប្រជាពលរដ្ឋ ជាពិសេសស្ត្រី។ ស្ថានភាពរស់នៅខ្សត់ខ្សោយបង្ខំឱ្យប្រជាពលរដ្ឋជាច្រើននាក់ត្រូវចំណាយពេលវេលាច្រើនក្នុងការប្រកបមុខរបរ ជាជាងចូលរួមក្នុងសកម្មភាពសាធារណៈ ឬការអភិវឌ្ឍសហគមន៍ ហើយកត្តាសេដ្ឋកិច្ចទន់ខ្សោយនេះ ក៏ជម្រុញឱ្យពួកគាត់សម្លឹងរកតែផលប្រយោជន៍ភ្លាមៗ ដោយសារតែខ្វះការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងការងារនៅមូលដ្ឋាន។ ឯស្ត្រី ត្រូវគេចាត់ទុកថា ជាអ្នកទទួលរ៉ាប់រងតែការងារក្នុងផ្ទះសំបែង ដាំបាយ បោកខោអាវ មើលថែកូនតែប៉ុណ្ណោះ ដោយហេតុថាស្ត្រីមិនមានកម្លាំងរឹងមាំ ដែលអាចធ្វើការងារខាងក្រៅផ្ទះធ្ងន់ៗបាន ដូច្នេះទើបស្ត្រី គេមិនសូវឃើញវត្តមានរបស់ស្ត្រីចូលរួមក្នុងសកម្មភាពសង្គមច្រើនប៉ុន្មានទេ ។ ក្រៅពីនេះ ភាពខ្វះខាតនូវព័ត៌មាន និងចំណេះដឹងរបស់ប្រជាពលរដ្ឋ ក៏ជាបញ្ហាអាក់ខានដល់ការចូលរួមផងដែរ ពីព្រោះពេលខ្លះប្រជាពលរដ្ឋមិនបានដឹងពីរបៀបនៃការចូលរួម ឬត្រូវចូលរួមនៅពេលណា និងម្យ៉ាងទៀតប្រជាពលរដ្ឋដែលមិនមានចំណេះដឹងគ្រប់គ្រាន់ឆ្លើយតបទៅនឹងបញ្ហាដែលខ្លួនត្រូវផ្ដល់យោបល់។

ដោយមើលឃើញពីបញ្ហាទាំងនេះ ការធ្វើកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ ការចូលរួម ជាចំណុចសំខាន់មួយ ដែលកំណត់ថាជាគោលការណ៍សំខាន់មួយក្នុងកំណែទម្រង់វិមជ្ឈការ។ ការ

ធ្វើកំណែទម្រង់ទៅលើចំណុចនេះ នឹងបង្ហាញពីនីតិវិធី ដែលធ្វើឱ្យប្រាកដថាសាធារណជនទាំងអស់ ជាពិសេសស្ត្រី ជនងាយរងគ្រោះ និងប្រជាជនក្រីក្រ អាចចូលរួមក្នុងការធ្វើសេចក្ដីសម្រេចរបស់ឃុំ សង្កាត់បាន។[34] ដើម្បីឱ្យការចូលរួមទទួលបានជោគជ័យនោះ រាជរដ្ឋាភិបាលក៏បានតាក់តែងនូវ អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវអនុម័តក្នុងខែវិច្ឆិកា ឆ្នាំ២០០៥។ ការចូលរួម គឺជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ទាំង៨ នៃអភិបាលកិច្ចល្អ។ ការចូលរួមក្នុងបរិបទ អភិបាលកិច្ចល្អ សំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រី ក្នុងដំណើរការធ្វើ សេចក្ដីសម្រេចចិត្ត និងអនុវត្តសេចក្ដីសម្រេចចិត្តនោះ។[35] ការបើកឱ្យមានការចូលរួមនេះ គឺដើម្បី ធានាថា ព័ត៌មានរបស់ប្រជាពលរដ្ឋគ្រប់រូបដូចជា តម្រូវការ និងបំណងប្រាថ្នា ត្រូវបានប្រមូល និង វិភាគបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសម្រេចចិត្ត។ ការចូលរួម អាចធ្វើឡើងតាម ២របៀប គឺ ការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈអ្នកតំណាង។

### ២.២.១. ប្រភេទនៃការចូលរួម

#### ២.២.១.១. ការចូលរួមដោយផ្ទាល់

ប្រជាពលរដ្ឋ អាចចូលរួមដោយផ្ទាល់នៅក្នុងការងារឃុំ សង្កាត់របស់ខ្លួន។ ប្រជាពលរដ្ឋ អាចចូលរួមដោយផ្ទាល់នៅក្នុងឃុំ សង្កាត់របស់ខ្លួន ដោយទទួលបានព័ត៌មានពីការធ្វើសេចក្ដី សម្រេចចិត្តលើបញ្ហាណាមួយនៅក្នុងឃុំ សង្កាត់សាមី។ ការចូលរួមនេះ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធ គ្រប់រូបទាំងអស់ អាចចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្ត សេចក្ដីសម្រេចនោះ។ ក្រៅពីនេះប្រជាពលរដ្ឋ ក៏អាចចូលរួមយ៉ាងសកម្មក្នុងសកម្មភាពអភិវឌ្ឍ របស់ឃុំ សង្កាត់។ ប្រជាពលរដ្ឋ អាចចូលរួមពិភាក្សាជាមួយឃុំ សង្កាត់ពីផលប៉ះពាល់ទាំងឡាយ ដល់បរិស្ថាន ដែលបណ្ដាលមកពីគម្រោងអភិវឌ្ឍន៍។ ជាពិសេសប្រជាពលរដ្ឋ អាចចូលរួមតាមដាន ត្រួតពិនិត្យលើសកម្មភាពការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងធ្វើការវាយតម្លៃដាក់ពិន្ទុថែមទៀត។ វត្តមានរបស់ប្រជាពលរដ្ឋ ក្នុងសកម្មភាពនានារបស់ឃុំ សង្កាត់ ពិតជាមានសារៈសំខាន់ និងមិនខ្វះ បានឡើយ។

#### ២.២.១.២. ការចូលរួមតាមរយៈអ្នកតំណាង

ប្រជាពលរដ្ឋ មិនតម្រូវឱ្យធ្វើការចូលរួមដោយផ្ទាល់ដូចបានបកស្រាយខាងលើទេ មានន័យ ថាប្រជាពលរដ្ឋមានអ្នកតំណាង ហើយអ្នកតំណាងរបស់ប្រជាពលរដ្ឋ ចូលរួមក្នុងដំណើរការនៃការ

---

[34] រាជរដ្ឋាភិបាលកម្ពុជា, *ក្របខណ្ឌយុទ្ធសាស្ត្រស្ដីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ* (ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ១៧ មិថុនា ២០០៥)។

[35] ក្រសួងមហាផ្ទៃ, *អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់* (ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, វិច្ឆិកា ២០០៥), ៧។

សម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចនោះជំនួសខ្លួន។ ជារៀងរាល់ ៥ឆ្នាំម្តង ដែលប្រជាពលរដ្ឋធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់គឺជាតំណាងរបស់ប្រជាពលរដ្ឋ ហើយអនុវត្តសកម្មភាពដើម្បីបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ការបំពេញការងារក្នុងនាមជាតំណាងរបស់ប្រជាពលរដ្ឋ គឺតំណាងឱ្យឆន្ទៈ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឱ្យ។ ដូចនេះប្រជាពលរដ្ឋមិនចាំបាច់ ចូលរួមដោយផ្ទាល់នោះទេ។

### ២.២.២. វិធីសាស្ត្រដើម្បីជម្រុញការចូលរួម

ដើម្បីជម្រុញឱ្យសកម្មភាពចូលរួមកាន់តែមានភាពប្រសើរឡើង និងដើម្បីធានាឱ្យប្រជាពលរដ្ឋ និងអ្នកតំណាងរបស់ប្រជាពលរដ្ឋ មានឱកាសចូលរួមយ៉ាងពេញលេញ ជាពិសេសតំណាងក្រុមអ្នកក្រីក្រ និងក្រុមងាយរងគ្រោះ ក្រុមប្រឹក្សាឃុំ សង្កាត់គួរពិចារណាលើចំណុចមួយចំនួន ដូចខាងក្រោម៖

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់ និងភាពចាំបាច់នៃការចូលរួមរបស់ពួកគេ
- ផ្សព្វផ្សាយព័ត៌មានស្តីពីកិច្ចប្រជុំ និងព័ត៌មានផ្សេងៗ ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
- កំណត់ពេលវេលា និងទីកន្លែងប្រជុំឱ្យបានសមស្រប
- បង្កបរិយាកាសនៃការប្រជុំឱ្យមានលក្ខណៈជាចំហ មានការចូលរួមយ៉ាងផុលផុស និងសប្បាយរីករាយ
- រៀបចំទីកន្លែងប្រជុំប្រកបដោយផាសុកភាព
- រៀបចំឱ្យមានប្រព័ន្ធទទួល និងផ្តល់ព័ត៌មានដែលមានលក្ខណៈងាយៗ និងអាចទទួលយកបាន
- បង្កើតទំនាក់ទំនងល្អ និងស្និទ្ធស្នាលជាមួយប្រជាពលរដ្ឋ។

ដូចនេះវិធីសាស្ត្រនឹងជួយជាកម្លាំងមួយ ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងវិស័យសាធារណៈក្នុងឃុំ សង្កាត់ដែលគេរស់នៅផ្ទាល់។

### ២.៣. តម្លាភាព

ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានតម្លាភាព គឺត្រូវបំពេញការងារដោយចំហ ពោលគឺបើកឱកាសឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា និងក្នុងរឿងថវិកាជាដើម។ ម្យ៉ាងទៀត ក្រុមប្រឹក្សា ត្រូវបង្ហាញព័ត៌មាននានា ដែលពាក់ព័ន្ធ និងមានសារៈសំខាន់ ដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានខ្លួន ជាពិសេសស្ត្រី និងជនជាតិដើមភាគតិច។ តម្លាភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថា រាល់ការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចនោះ ត្រូវធ្វើឡើង៖

- ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិនានា។

- ព័ត៌មានពាក់ព័ន្ធនឹងការសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចត្រូវផ្សព្វផ្សាយជាចំហ តាមរយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបាន ជាពិសេសចំពោះអ្នកដែលទទួលរងនូវផលប៉ះពាល់ពីការសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចចិត្តទាំងនោះ។
- ព័ត៌មានទាំងនោះត្រូវតែមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់។[36]

ក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវធ្វើការប្រជុំយ៉ាងតិចម្ដងក្នុង១ខែ ត្រូវតែធ្វើឡើងជាសាធារណៈ ហើយត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន។ របៀបវារៈនៃកិច្ចប្រជុំ ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរឱ្យប្រជាពលរដ្ឋបានដឹងមុន ដូច្នេះប្រជាពលរដ្ឋអាចស្នើសុំបន្ថែមចំណុចផ្សេងៗទៅក្នុងរបៀបវារៈកិច្ចប្រជុំ ដែលមានភាពចាំបាច់សម្រាប់ប្រយោជន៍ទូទៅ។[37] ដោយឡែកឃុំ សង្កាត់ ត្រូវអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំ ដែលចំណូល និងចំណាយមានភាពស្មើគ្នា។ ដើម្បីរៀបចំ និងអនុម័តថវិកាសម្រាប់ឆ្នាំនីមួយៗ ឃុំ សង្កាត់ត្រូវធានាថាអ្នកពាក់ព័ន្ធនានា ជាពិសេសប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន អាចចូលរួមក្នុងដំណើរការរៀបចំ និងអនុម័តថវិកានេះ។[38] ការធ្វើបែបនេះ ធ្វើឱ្យការអនុម័តថវិការបស់ឃុំ សង្កាត់ក្នុងឆ្នាំនីមួយៗ អនុវត្តប្រកបដោយប្រសិទ្ធភាព និងសម្រេចលទ្ធផលការងារល្អប្រសើរសម្រាប់ឃុំ សង្កាត់ទាំងមូល។

## ២.៤. គណនេយ្យភាព និងការឆ្លើយតប

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានផ្ដល់នូវមូលដ្ឋានគ្រឹះ សម្រាប់ដំណើរការកែទម្រង់តាមបែបប្រជាធិបតេយ្យ ដោយតម្រូវឱ្យបង្កើតក្រុមប្រឹក្សាតាមរយៈការបោះឆ្នោត ដើម្បីដើរតួនាទីជាតួអង្គតំណាងផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺត្រូវបានកើតឡើងដោយការបោះឆ្នោតពីប្រជាពលរដ្ឋទូទៅ ហើយបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋ។[39] ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានគណនេយ្យភាពជាចម្បង និងដោយផ្ទាល់ចំពោះប្រជាពលរដ្ឋដើម្បីធានាដល់ការបង្កើននូវតម្លាភាព ជម្រុញការចូលរួមរបស់ប្រជាពលរដ្ឋ និងផ្ដោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើសម្លេង និងតម្រូវការរបស់ប្រជាពលរដ្ឋទាំងបុរស ស្ត្រី និងក្រុមងាយរងគ្រោះ នៅក្នុងការធ្វើសេចក្ដីសម្រេចចិត្តលើការប្រើប្រាស់ និងការគ្រប់គ្រងធនធាន ព្រមទាំងការផ្ដល់សេវាសាធារណៈ សេវារដ្ឋបាល ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងមូលដ្ឋានរបស់ខ្លួន។

ក្នុងរយៈពេលកន្លងមកនេះ គណនេយ្យភាពត្រូវបានពង្រឹងយ៉ាងខ្លាំងក្នុងក្របខ័ណ្ឌនៃកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន ក៏ដូចជាថ្នាក់ក្រោម

[36] ដូច៣៥, ១៦។

[37] ដដែល, ១៦-១៧។

[38] ដដែល, ១៦-១៨។

[39] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៩។

ជាតិ។[40] គោលបំណងនៃគណនេយ្យភាព គឺផ្តល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឱ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានា ក្នុងការចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងការផ្តល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយទទួលបានព័ត៌មាន និងការចូលរួមពិនិត្យតាមដានលើការងារថវិកា និងការបំពេញការងាររបស់រដ្ឋបាល។ គណនេយ្យភាព ជម្រុញឱ្យមានការផ្លាស់ប្តូរនូវការផ្តល់សេវា និងការឆ្លើយតបកាន់តែប្រសើរដល់ប្រជាពលរដ្ឋ ជាពិសេសសមត្ថភាពរបស់ប្រជាពលរដ្ឋទាំងស្ត្រី និងបុរស និងតំណាងនានារបស់ប្រជាពលរដ្ឋ នឹងត្រូវបានលើកកម្ពស់កាន់តែប្រសើរឡើង។[41]

ដូច្នេះ គណនេយ្យភាពនឹងផ្តល់នូវផលប្រយោជន៍ជាច្រើនក្នុងការផ្តល់សេវាកម្ម និងការបែងចែកធនធានរបស់រដ្ឋបាលឃុំ សង្កាត់នឹងកាន់តែមានលក្ខណៈប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសមធម៌។ សហគមន៍មូលដ្ឋាន និងប្រជាពលរដ្ឋទាំងឡាយ ជាពិសេសស្ត្រី និងយុវវ័យដែលជាតួអង្គសំខាន់ក្នុងការចូលរួមចំណែកធ្វើឱ្យមានការផ្លាស់ប្តូរ នឹងត្រូវបានលើកកម្ពស់នូវសិទ្ធិអំណាចរបស់ខ្លួន តាមរយៈការបង្កលក្ខណៈឱ្យពួកគេមានការយល់ដឹងកាន់តែច្រើនឡើងអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាលឃុំ សង្កាត់។

ដើម្បីកសាងនូវប្រព័ន្ធគណនេយ្យភាពដ៏ល្អ ចាំបាច់ត្រូវប្រើប្រាស់នូវយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម៖

### ២.៤.១. ការលើកកម្ពស់តម្លាភាព និងភាពងាយទទួលបាននូវព័ត៌មានអំពីស្តង់ដារ ថវិកា និងការបំពេញការងារ

ព័ត៌មាន គឺជាឧបករណ៍សំខាន់ក្នុងការជម្រុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។ ច្បាស់លាស់នៃព័ត៌មាន ទិន្នន័យ និងភស្តុតាងនានា នឹងនាំឱ្យការពិគ្រោះយោបល់នានាសម្រេចបានលទ្ធផលល្អដែរ។ ហេតុនេះ ប្រសិនបើគ្មានព័ត៌មាននោះទេ ប្រជាពលរដ្ឋក៏ពុំអាចមានលទ្ធភាពចូលរួមជួយពង្រឹង និងកែលម្អការបំពេញកិច្ចការរបស់រដ្ឋបាលបានដែរ។

រដ្ឋបាលឃុំ សង្កាត់ ត្រូវផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋអំពីស្តង់ដារនៃការផ្តល់សេវាកម្មដោយរៀបរាប់អំពីកម្រិត និងគុណភាពនៃសេវាកម្មដែលត្រូវផ្តល់ ព្រមទាំងត្រូវបិទផ្សាយនូវព័ត៌មានអំពីស្តង់ដារទាំងនេះ រួមទាំងថវិកា និងការចំណាយនានានៅតាមសាលាឃុំ សង្កាត់ មណ្ឌលសុខភាព និងសាលារៀនទាំងឡាយ។ ទោះបីជាព័ត៌មានទាំងនោះនឹងត្រូវបានផ្តល់ក្នុងទម្រង់បែបផែនដែល

[40] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* (ភ្នំពេញ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កក្កដា ២០១៣), ១។

[41] ដូច៤០, ២។

ងាយស្រួលក្នុងការស្វែងរក និងទទួលបានក៏ដោយ ក៏ចាំបាច់ត្រូវមានការគាំទ្រដល់ប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះនានាក្នុងការប្រើប្រាស់នូវព័ត៌មានទាំងនោះផងដែរ។

### ២.៤.២. ការសម្របសម្រួលឱ្យមានការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋទៅលើសកម្មភាព និងការផ្តល់សេវាកម្មមូលដ្ឋាន

ក្រុមប្រជាពលរដ្ឋ ត្រូវផ្តួចផ្តើមកិច្ចដំណើរការតាមដានទៅលើសកម្មភាពនានា និងការផ្តល់សេវារបស់រដ្ឋបាល ដើម្បីពង្រឹងនូវគណនេយ្យភាពរបស់រដ្ឋបាលឱ្យកាន់តែច្រើនឡើង។ រដ្ឋបាលឃុំ សង្កាត់ នឹងធ្វើការសម្របសម្រួលឱ្យប្រជាពលរដ្ឋមានតួនាទីយ៉ាងសកម្មក្នុងការត្រួតពិនិត្យតាមតានដោយភាពងាយស្រួល។ ការសម្របសម្រួលឱ្យប្រជាពលរដ្ឋមានតួនាទីយ៉ាងសកម្មក្នុងការត្រួតពិនិត្យតាមដាននេះនឹងផ្តល់លទ្ធភាពធ្វើឱ្យមានការឆ្លុះបញ្ចាំង អំពីលទ្ធផលនៃការបំពេញការងារ ហើយធ្វើឱ្យរដ្ឋបាលប្រកាន់យកដើម្បីពង្រឹង និងកែលម្អដល់ការបំពេញការងាររបស់ខ្លួនឱ្យកាន់តែប្រសើរ។ ជាមួយគ្នានេះដែរ ការត្រួតពិនិត្យតាមដានរបស់ប្រជាពលរដ្ឋទៅលើការបំពេញការងាររបស់រដ្ឋបាលឃុំ សង្កាត់ ក៏នឹងផ្តល់លទ្ធភាពឱ្យស្ត្រី យុវវ័យ និងប្រជាពលរដ្ឋទាំងឡាយក្នុងមូលដ្ឋានទទួលបានព័ត៌មាន ដើម្បីផ្តល់យោបល់នៅក្នុងកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគសម្រាប់ឆ្នាំបន្តបន្ទាប់ផងដែរ។

### ២.៤.៣. ការលើកកម្ពស់សមត្ថភាពយល់ដឹងរបស់ប្រជាពលរដ្ឋអំពីថវិកា

សមត្ថភាពនៃការយល់ដឹងរបស់ប្រជាពលរដ្ឋ គឺសំខាន់ ដែលអាចឆ្លើយតបនឹងការចូលរួមផ្តល់យោបល់លើបញ្ហាថវិការបស់មូលដ្ឋាន។ ការលើកកម្ពស់សមត្ថភាពរបស់ប្រជាពលរដ្ឋអំពីថវិកានឹងធ្វើឱ្យប្រជាពលរដ្ឋយល់ដឹងច្បាស់ពីការបែងចែក ការចាត់ចែង ការប្រើប្រាស់ និងការគ្រប់គ្រងថវិការបស់រដ្ឋបាលឃុំ សង្កាត់។ ប្រជាពលរដ្ឋ មានលទ្ធភាពក្នុងការកំណត់អាទិភាពនៃតម្រូវការនានា និងផ្តល់យោបល់ដល់ការបែងចែកមូលនិធិរបស់ឃុំ សង្កាត់។

### ២.៤.៤. ការគាំទ្រដល់តួអង្គនានា និងការកសាងសមត្ថភាព ដល់តួអង្គទាំងនេះ ដើម្បីសម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចដំណើរការនានានៃគណនេយ្យភាពសង្គម

ដើម្បីជម្រុញឱ្យមានការប្រាស្រ័យទាក់ទងរវាងរដ្ឋបាល និងប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ចាំបាច់តម្រូវឱ្យមានកិច្ចអន្តរាគមន៍ដល់ក្រុមប្រជាពលរដ្ឋ ទាំងក្នុងការបង្កើត និងការជួយគាំទ្រដល់ក្រុមប្រជាពលរដ្ឋ។ ការពង្រឹងសមត្ថភាពរបស់ក្រុមប្រជាពលរដ្ឋក្នុងការប្រាស្រ័យទាក់ទងជាមួយរដ្ឋបាល គឺជាយុទ្ធសាស្ត្រមួយក្នុងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងកិច្ចដំណើរការគណនេយ្យភាពសង្គម។

ពាក់ព័ន្ធនឹងកិច្ចការនេះ ចាំបាច់ត្រូវធានាឱ្យមានការជួយគាំទ្រផ្នែកបច្ចេកទេសដល់រដ្ឋបាលឃុំ សង្កាត់ ដើម្បីមានសមត្ថភាពក្នុងផ្តួចផ្តើមគំនិតសម្រាប់រៀបចំ និងអនុវត្តសកម្មភាពនានាពាក់ព័ន្ធនឹងគណនេយ្យភាពសង្គម។ អាស្រ័យហេតុនេះ ទើបការកសាងសមត្ថភាពគឺឆ្លើយតបនឹងស្ថានភាពចាំបាច់ និងលើកកម្ពស់គណនេយ្យភាពសង្គមផងដែរ។

### ២.៤.៥. ការប្រមូលមេរៀន បទពិសោធន៍ដែលបានមកពីអន្តរាគមន៍នានានៅមូលដ្ឋាន

ផ្អែកតាមមេរៀន និងបទពិសោធន៍ដែលបានដកស្រង់ចេញពីការអនុវត្តជាក់ស្តែង ត្រូវធានាថាគំនិតផ្តួចផ្តើមសាមញ្ញនានា ដែលបានប្រើប្រាស់ប្រកបដោយជោគជ័យនៅក្នុងស្ថានភាពរបស់សហគមន៍ជាក់លាក់ណាមួយ ត្រូវបានលើកកម្ពស់ និងអាចមានលទ្ធភាពយកទៅអនុវត្តនៅកន្លែងដទៃទៀត ព្រមទាំងត្រូវធានាថារាល់គោលនយោបាយរបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងតម្លាភាព និងគណនេយ្យភាពត្រូវមានលក្ខណៈឆ្លើយតបទៅនឹងបញ្ហាប្រឈមនានា និងអាចអនុវត្តបានដោយជោគជ័យ។

### ២.៥. ប្រសិទ្ធភាពការងារ

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសឡើងតាមលក្ខណៈប្រជាធិបតេយ្យដោយប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ។ ភារកិច្ចសំខាន់បំផុតរបស់ឃុំ សង្កាត់ គឺអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន លើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋ និងការផ្តល់សេវាសាធារណៈនានាទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ សង្កាត់បានអនុវត្តតាមក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលសម្រាប់ថ្នាក់ក្រោមជាតិ ដើម្បីកែលម្អជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ដូច្នេះហើយរាល់សកម្មភាពការងាររបស់ក្រុមប្រឹក្សា ក៏ដូចជាឃុំ សង្កាត់ទាំងមូល គឺទាមទារនូវការភ្ជាប់មកជាមួយនូវប្រសិទ្ធភាព។

ប្រសិទ្ធភាពការងារ គឺជាចំណុចមួយដែលត្រូវកែលម្អ និងជម្រុញឱ្យឃុំ សង្កាត់ទាំងអស់ប្រកាន់ខ្ជាប់ គ្រប់ការងារទាំងឡាយ។ ប្រសិទ្ធភាពការងារ មិនសំដៅតែទៅលើការងារគ្រប់គ្រងរដ្ឋបាលតែប៉ុណ្ណោះទេ។ តែប្រសិទ្ធភាពការងារ គឺសំដៅទៅលើការប្រើប្រាស់ធនធានឱ្យអស់លទ្ធភាព និងសន្សំសំចៃ ដើម្បីសម្រេចនូវគោលដៅដោយជោគជ័យ ពោលគឺបង្កើតនូវលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណច្រើន អាចបម្រើផលប្រយោជន៍ជាអតិបរមា និងបានឆ្លើយតបទៅតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ និងសង្គមទាំងមូល។[42]

ការធ្វើកំណែទម្រង់ទៅលើប្រសិទ្ធភាពការងារ នឹងជម្រុញឱ្យការផ្តល់សេវានានាកាន់តែនៅជិតប្រជាពលរដ្ឋ។ កាលណាប្រជាពលរដ្ឋមើលឃើញ អំពីប្រសិទ្ធភាពការងាររបស់ឃុំ សង្កាត់ ក្នុង

[42] ដូច៣៥, ២៤។

ការផ្តល់សេវាសាធារណៈ ប្រជាពលរដ្ឋមានទំនុកចិត្តក្នុងការទទួលយកសេវាទាំងនោះ។ ដូច្នេះការអភិវឌ្ឍឃុំ សង្កាត់ ប្រជាពលរដ្ឋនឹងកាន់តែមានការជឿជាក់ទៅលើក្រុមប្រឹក្សាឃុំ សង្កាត់ដែលខ្លួនបានបោះឆ្នោតឱ្យ ព្រោះប្រសិទ្ធភាពការងាររបស់ឃុំ សង្កាត់ក្នុងសកម្មភាពអភិវឌ្ឍឃុំ សង្កាត់បង្ហាញអំពីការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋរបស់ខ្លួន។ ជាងនេះទៅទៀត ប្រជាពលរដ្ឋក៏នឹងចូលរួមក្នុងសកម្មភាពនានារបស់ឃុំ សង្កាត់ដូចជាវេទិកាសាធារណៈក្នុងឃុំ សង្កាត់ ការចូលរួមក្នុងការផ្តល់យោបល់ទៅលើផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងចូលរួមធ្វើសេចក្តីសម្រេចនានា ជាដើម ។

កន្លងមក ប្រជាពលរដ្ឋតែងតែរអ៊ូរទាំអំពីប្រសិទ្ធភាពការងាររបស់អ្នកផ្តល់សេវា ក៏ដូចជាអង្គភាពផ្តល់សេវាទាំងមូល។ ដូច្នេះដើម្បីកែលម្អទៅលើបញ្ហាដែលមិនល្អនេះ រាជរដ្ឋាភិបាលបានប្រឹងប្រែងស្វែងយល់ និងរកវិធីដោះស្រាយជាច្រើន។ នៅឆ្នាំ២០០៥ ក្រសួងមហាផ្ទៃ បានដាក់ចេញនូវ អភិបាលកិច្ចល្អ សម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលក្នុងនោះប្រសិទ្ធភាពការងារត្រូវបានដាក់ចូលជាគោលការណ៍មួយ ក្នុងចំណោមគោលការណ៍ទាំង៨នៃអភិបាលកិច្ចល្អ ។ ដូច្នេះដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារឱ្យបានល្អប្រសើរ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

### ២.៥.១. ការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវ

ធនធានជាធាតុសំខាន់ក្នុងសកម្មភាពការងារទាំងមូល ហើយក្នុងន័យនេះធនធានសំដៅដូចជា ធនធានមនុស្ស ធនធានថវិកា សម្ភារ ពេលវេលា ជាដើម។ ដូច្នេះកាលណាចេះប្រើប្រាស់ធនធានទាំងនេះ ឱ្យបានត្រឹមត្រូវ នាំឱ្យមានប្រសិទ្ធភាពការងារខ្ពស់។ ត្រូវដឹងថាធនធានទាំងនេះវាតែងតែមានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក។

### ២.៥.២. ការអនុវត្តសកម្មភាពជាអាទិភាពខ្ពស់

ការអនុវត្តសកម្មភាពជាអាទិភាពខ្ពស់ មានន័យថាក្រុមប្រឹក្សា ត្រូវដឹងពីតម្រូវការរបស់ប្រជាពលរដ្ឋឱ្យច្បាស់លាស់ ថាតើអ្វីដែលជាតម្រូវចាំបាច់ និងពិតប្រាកដ និងតម្រូវណាខ្លះដែលតម្រូវធ្វើជាបន្ទាន់បំផុតសម្រាប់ប្រជាពលរដ្ឋទូទៅ ឬសម្រាប់ប្រជាពលរដ្ឋក្រុមណា ដែលក្រុមប្រឹក្សាយល់ថាត្រឹមត្រូវ និងត្រូវតែធ្វើការដោះស្រាយមុនគេ។

ប្រសិនបើមានបញ្ហាមួយចំនួន ដែលមានការចូលរួមពីប្រជាពលរដ្ឋជាលើកឡើងថាជាសកម្មភាពអាទិភាព ត្រូវបានអនុវត្តនោះ ប្រជាពលរដ្ឋនឹងមានចូលរួមកាន់តែច្រើន ហើយមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការថែទាំសមិទ្ធិផលទាំងអស់នោះទៀតផង។ លើសពីនេះទៀតក៏មានការពេញចិត្តបង់ទុនចូលរួម ព្រោះវាឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់គេ។

### ២.៥.៣. ជៀសវាងអនុវត្តការិយាធិបតេយ្យ

ដើម្បីប្រសិទ្ធភាពការងារល្អប្រសើរ ត្រូវជៀសវាងនូវការិយាធិបតេយ្យ ព្រោះសកម្មភាពការងារដែលត្រូវធ្វើ ឬបញ្ហាដែលត្រូវដោះស្រាយ តែងតែពន្យារជាបន្តបន្ទាប់ ដោយសារតែត្រូវបំពេញនូវទម្រង់បែបបទច្រើនពេក រង់ចាំការរត់ឯកសារ ការពិនិត្យឯកសារ និងការអនុម័តយល់ព្រមពីអ្នកដឹកនាំពីម្នាក់ទៅម្នាក់ទៀត ពីមួយថ្នាក់ទៅមួយថ្នាក់ទៀត ឬអាចបញ្ជូនឯកសារត្រឡប់មកវិញ ឬត្រឡប់ចុះឡើង ធ្វើឱ្យការងារកាន់តែយឺតយ៉ាវខ្លាំង ហួសពេលកំណត់។

### ២.៥.៤. ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ

ការគិតគូរពីការប្រើប្រាស់ និងការអាស្រ័យទៅលើធនធានធម្មជាតិ ដោយគិតពីរយៈពេលឱ្យបានវែងពីការទាញយកផលប្រយោជន៍ពីធនធានធម្មជាតិនោះ។ ចំពោះការសម្រេចចិត្តរបស់ក្រុមប្រឹក្សាមិនត្រូវធ្វើឱ្យខាតប្រយោជន៍ ឬបាត់បង់នូវប្រយោជន៍ដែលអាចទាញយកបាននាពេលអនាគតឡើយ។ ការសម្រេចចិត្តរបស់ក្រុមប្រឹក្សា ក៏ត្រូវគិតពីតម្លៃនៃធនធាន និរន្តរភាពនៃការប្រើប្រាស់ និងផលប៉ះពាល់នានាដែលអាចជះឥទ្ធិពលដល់បរិស្ថាន និងកម្រិតនៃភាពកកើតឡើងវិញបាននូវធនធានធម្មជាតិទាំងនោះ។

### ២.៥.៥. គ្មានអំពើពុករលួយ

អំពើពុករលួយ ជាអំពើមួយដែលគេគ្រប់គ្នាស្អប់ខ្ពើម ហើយបើមានអំពើពុករលួយកន្លែងណាមួយក្នុងការបម្រើសេវាសាធារណៈ តែងតែមានការរអូសទាំពីភាពយឺតយ៉ាវនៃការងារ និងធ្វើឱ្យប្រសិទ្ធភាពការងារអន់ខ្សោយ។ ដូច្នេះក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធានាមិនត្រូវឱ្យមានអំពើពុករលួយកើតមានឡើងក្នុងឃុំ សង្កាត់របស់ខ្លួនឡើយ។ គ្មានអំពើពុករលួយ នៅក្នុងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាកត្តាមួយសំខាន់ណាស់ ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទទួលបាននូវទំនុកចិត្តពីប្រជាពលរដ្ឋ។

### ២.៥.៦. ការសម្រេចចិត្តតាមបែបវិមជ្ឈការ

ក្រុមប្រឹក្សាឃុំ សង្កាត់ គឺកើតឡើងដោយប្រជាពលរដ្ឋ និងធ្វើការងារដើម្បីប្រយោជន៍ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ សង្កាត់រស់នៅ និងធ្វើការផ្ទាល់ជាមួយប្រជាពលរដ្ឋ ដូច្នេះរាល់តម្រូវការរបស់ប្រជាពលរដ្ឋ និងការទាមទាររបស់ប្រជាពលរដ្ឋ ច្បាស់ជាក្រុមប្រឹក្សាដឹងច្បាស់ណាស់ហើយ។ ក្រុមប្រឹក្សាអាចដឹងអំពីបញ្ហា តម្រូវការពិតប្រាកដ និងអាចរកដំណោះស្រាយណាមួយដែលមានប្រសិទ្ធភាពខ្ពស់ និងសមស្របតាមស្ថានភាពជាក់ស្តែងក្នុងឃុំ សង្កាត់របស់ខ្លួន។

ដូច្នេះ ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការចូលរួមពីប្រជាពលរដ្ឋ អាចមានប្រសិទ្ធភាពខ្ពស់ជាងអ្នកមកពីខាងក្រៅ ឬអ្នកដទៃទៀត។

## ២.៦. ការផ្ទេរមុខងារ និងធនធាន

ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន ព្រោះត្រូវបានកើតឡើងដោយបោះឆ្នោតពីប្រជាពលរដ្ឋផ្ទាល់ ហើយមានបេសកកម្មបម្រើប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន។ ដូច្នេះឃុំ សង្កាត់មានតួនាទីបំពេញនូវតម្រូវការរបស់ប្រជាពលរដ្ឋ និងរៀបចំចាត់ចែងសេវាសាធារណៈចាំបាច់សម្រាប់ប្រជាពលរដ្ឋ ជាពិសេសគឺរៀបចំសណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ម្យ៉ាងទៀតឃុំ សង្កាត់ក៏មានការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ទៅតាមលទ្ធភាពនៃថវិការបស់ខ្លួនដែលមាន និងការផ្ដល់ពីថ្នាក់ជាតិ។

ក្នុងការរ៉ាប់រងនូវកិច្ចការសំខាន់ៗមួយចំនួន ព្រមជាមួយនិងការអភិវឌ្ឍឃុំ សង្កាត់ និងការផ្ដល់សេវាសាធារណៈ រដ្ឋបាលឃុំ សង្កាត់ ទាមទារនូវការប្ដេជ្ញាចិត្តផ្ទាល់ និងការគាំទ្ររបស់អាជ្ញាធរថ្នាក់លើ ដើម្បីចូលរួមពង្រឹងការអនុវត្តផែនការនានារបស់ឃុំ សង្កាត់។ ឃុំ សង្កាត់មានតួនាទីជម្រុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។[43] ដូច្នេះឃុំ សង្កាត់ត្រូវធ្វើសកម្មភាពឱ្យបានច្រើន បម្រើប្រជាពលរដ្ឋឱ្យល្អប្រសើរ និងការអភិវឌ្ឍមូលដ្ឋានតាមបែបប្រជាធិបតេយ្យពិតប្រាកដ ហើយត្រូវបំពេញកិច្ចការទូទៅដើម្បីឆ្លើយតបសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋផងដែរ។

ពាក់ព័ន្ធនឹងការផ្ដល់សេវាសាធារណៈ និងបម្រើដល់ផលប្រយោជន៍ទូទៅ ក៏មិនអាចផ្ដល់ទៅតាមអ្វីដែលជាតម្រូវការរបស់ប្រជាពលរដ្ឋ និងដើម្បីប្រយោជន៍ទាំងអស់នោះបានទេ មានន័យថាចំពោះវិស័យមួយចំនួនឃុំ សង្កាត់គ្មានអំណាចដើម្បីសម្រេចឡើយ។[44] ទោះជាយ៉ាងណាក៏ដោយ ក្នុងនាមជាភ្នាក់ងាររបស់រដ្ឋ អាជ្ញាធររដ្ឋអាចធ្វើការផ្ទេរអំណាច ឬសេវាដែលសមស្រប ដែលជាការចាំបាច់សម្រាប់អភិវឌ្ឍមូលដ្ឋាន និងផ្ដល់ឱ្យប្រជាពលរដ្ឋកាន់តែឆាប់រហ័ស និងចំណាយប្រាក់តិចគិតទៅតាមតម្លៃដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តិរបស់អាជ្ញាធរមានសមត្ថកិច្ច។ "អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្គត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកា សម្រាប់អនុវត្ត។"[45]

[43] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤១។
[44] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤៤។
[45] ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, មាត្រា៤៥។

ក្នុងផែនការអនុវត្តរយៈពេលបីឆ្នាំដំបូង (២០១១-២០១៣) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(ផអ៣) រាជរដ្ឋាភិបាលកម្ពុជា មានគោលបំណងផ្ទេរនូវសិទ្ធិអំណាច និងមុខងារពីរដ្ឋបាលថ្នាក់កណ្តាល និងពីក្រសួងស្ថាប័ននានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការពិនិត្យមើលតាមបែបប្រជាធិបតេយ្យ និងដើម្បីធានាដល់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។ អាស្រ័យហេតុនេះ ប្រសិនបើរដ្ឋបាលឃុំ សង្កាត់ទទួលបាននូវការប្រគល់មុខងារ និងការទទួលខុសត្រូវក្នុងការផ្តល់សេវាជាក់លាក់មួយចំនួន នោះនឹងអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិទាំងមូលជាមិនខាន។ ដូច្នេះ ប្រសិនបើការងារនេះត្រូវបានអនុវត្តយ៉ាងច្បាស់លាស់ ដោយមានការប្រគល់នូវការទទួលខុសត្រូវក្នុងការអភិវឌ្ឍវិស័យជាក់លាក់ទៅឱ្យឃុំ សង្កាត់ នោះនឹងធ្វើឱ្យអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យបោះជំហានទៅមុខយ៉ាងខ្លាំង។ ជាងនេះទៅទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកើតឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ អាចត្រូវបានយកចិត្តទុកដាក់កាន់តែខ្លាំងឡើង និងមានតួនាទីកាន់តែខ្លាំងក្នុងការរៀបចំគោលនយោបាយ និងការអនុវត្ត(ដូចជា ការទទួលខុសត្រូវលើការផ្តល់សេវាក្នុងវិស័យសាធារណៈសំខាន់ៗ)។

ពាក់ព័ន្ធនឹងការធ្វើប្រតិភូកម្មមុខងារទៅឱ្យឃុំ សង្កាត់ នឹងធ្វើឱ្យឃុំ សង្កាត់បំពេញការងារក្នុងនាមជាអង្គភាពស្វ័យភាពក្នុងការអនុវត្តកម្មវិធីនានារបស់ក្រសួង ស្ថាប័ន។ ឃុំ សង្កាត់នឹងទទួលខុសត្រូវទាំងស្រុងលើការផ្តល់សេវា ដែលក្នុងដំណាក់កាលដំបូង ក្រសួង ស្ថាប័នពាក់ព័ន្ធ និងមន្ទីរអង្គភាពជំនាញរបស់ខ្លួន ជាអ្នកផ្តល់មូលនិធិ និងត្រួតពិនិត្យមើលការផ្តល់សេវានេះ។ ក្នុងដំណើរការនេះឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលដំណើរការ និងស្តង់ដារនៃការផ្តល់សេវាឱ្យសមស្របទៅនឹងស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសេវា ព្រមទាំងពង្រឹងសមត្ថភាពរបស់ខ្លួនផ្ទាល់ក្នុងការផ្តល់សេវាទាំងនេះ។

ការផ្ទេរមុខងារបន្ថែមទៅឱ្យឃុំ សង្កាត់ គឺស្របទៅតាមគោលការណ៍នៃវិមជ្ឈការដែលមានចែងក្នុងច្បាប់អង្គការ។ ការផ្តល់មុខងារបន្ថែមនេះ ផ្តល់លទ្ធភាពឱ្យឃុំ សង្កាត់អាចរកចំណូលបន្ថែមបានច្រើនជាងមុន ដែលអាចប្រើប្រាស់ចំណូលនេះ ទៅជាការអភិវឌ្ឍឃុំ សង្កាត់នីមួយៗ និងបំពេញតាមតម្រូវការផ្សេងៗរបស់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី ជនងាយរងគ្រោះ កុមារ និងជនជាតិដើមភាគតិច។

## ២.៧. ការអភិវឌ្ឍសមត្ថភាព

ការអភិវឌ្ឍសមត្ថភាពក្រុមប្រឹក្សា និងក្រុមការងារនៅក្នុងឃុំ សង្កាត់ ដែលចាំបាច់សម្រាប់ធានាដល់ការបង្កើត ជម្រុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ការ

អភិវឌ្ឍសមត្ថភាព មិនសំដៅតែទៅលើការអភិវឌ្ឍចំណេះដឹងរបស់បុគ្គលិកក្នុងស្ថាប័ននោះទេ។ ប៉ុន្តែ "ការអភិវឌ្ឍន៍សមត្ថភាព គឺសំដៅទៅលើការគាំទ្របច្ចេកទេសកាលានុវត្តភាពនៃការសិក្សារៀនសូត្រ និងតម្រូវការព័ត៌មាន ទិន្នន័យ សម្ភារបរិក្ខារ ប្រព័ន្ធ និងនីតិវិធីនានា ដែលបង្កលក្ខណៈឱ្យបុគ្គលិក និងស្ថាប័ននានា អាចសម្រេចបាននូវលទ្ធផលទាំងឡាយនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"[46]។

ការអភិវឌ្ឍសមត្ថភាព នឹងត្រូវរៀបចំឡើងដើម្បីដោះស្រាយតម្រូវការចាំបាច់ និងបន្ទាន់របស់បុគ្គលិក និងនានាក្នុងការអនុវត្តនូវការទទួលខុសត្រូវ និងសិទ្ធិអំណាចរបស់ខ្លួននៅក្នុងរដ្ឋបាលរបស់ខ្លួនផ្ទាល់។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៅមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ទាមទារនូវការបង្កើនសមត្ថភាព និងមានវគ្គបណ្តុះបណ្តាលឱ្យបានច្រើនសម្រាប់ក្រុមប្រឹក្សា រួមជាមួយនិងបុគ្គលិកទាំងអស់ដែលបម្រើការងារនៅក្នុងរដ្ឋបាលឃុំ សង្កាត់។ ការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាដោយសារក្រុមប្រឹក្សាឃុំ សង្កាត់ភាគច្រើនមិនសូវជាមានចំណេះដឹងជ្រៅជ្រះនោះទេ ព្រោះលក្ខខ័ណ្ឌដែលអាចឈរឈ្មោះបោះឆ្នោតបានគឺមិនទាមទារនូវកម្រិតវប្បធម៌ ឬចំណេះដឹងខ្ពស់នោះទេ គឺត្រឹមតែចេះអាន និងសរសេរអក្សរខ្មែរក៏បានដែរ។[47] ហេតុនេះហើយការអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារជាមួយនឹងបច្ចេកវិទ្យាទំនើបៗ សម្ភារបច្ចេកទេសទំនើបៗ ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋកាន់តែឆាប់រហ័ស និងមានប្រសិទ្ធភាព។

### ២.៧.១. យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាព

ការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាបញ្ហាសំខាន់ ដោយហេតុថាមានតែឃុំ សង្កាត់ធ្វើជាមួយប្រជាពលរដ្ឋ ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋច្រើនជាងគេ។ ប៉ុន្តែប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ដែលតំណាងឱ្យផលប្រយោជន៍ប្រជាពលរដ្ឋ មិនមានសមត្ថភាពគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋផង នោះប្រជាពលរដ្ឋក៏លែងទុកចិត្តលើក្រុមប្រឹក្សាតទៅទៀតហើយ។ ដូចនេះគោលបំណងក្នុងការពង្រឹងប្រជាធិបតេយ្យនៅមូលដ្ឋាន ក៏មិនអាចសម្រេចបានលទ្ធផលល្អដែរ។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ រាជរដ្ឋាភិបាលបានប្រើប្រាស់នូវយុទ្ធសាស្ត្រ ក្នុងការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តែកជាសំខាន់លើះ

[46] រាជរដ្ឋាភិបាលកម្ពុជា, *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ២០១០-២០១៩* (ភ្នំពេញះ រាជរដ្ឋាភិបាលកម្ពុជា, ២៨ ឧសភា ២០១០), ២៧។

[47] ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ, មាត្រា៩៤។

- ការអភិវឌ្ឍសមត្ថភាពដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត ដែលមានសមាសភាពមកពីទីចាត់ការ និងអង្គភាពនានានៃសាលារាជធានី ខេត្ត
- ការផ្តល់មន្ត្រីសម្របសម្រួលដល់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ការផ្តល់ការប្រឹក្សាយោបល់ និងការរៀនសូត្រតាមរយៈអនុវត្តការងារ
- វិធីសាស្ត្របណ្តុះបណ្តាលបន្ត ដែលគ្រូបង្គោលថ្នាក់ជាតិបណ្តុះបណ្តាលដល់ក្រុមអភិវឌ្ឍន៍សមត្ថភាពរាជធានី ខេត្ត បន្ទាប់មកក្រុមនេះបន្តបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងគណៈអភិបាល និងមន្ត្រី បុគ្គលិករដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។[48]

**២.៧.២. យន្តការអភិវឌ្ឍន៍សមត្ថភាព**

ការគាំទ្រការអភិវឌ្ឍសមត្ថភាព គឺត្រូវផ្តោតទៅលើតម្រូវការជាអាទិភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ បច្ចុប្បន្នការងារអប់រំ បណ្តុះបណ្តាល និងកសាងសមត្ថភាព គឺទទួលបន្ទុកដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដែលត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីរៀបចំយន្តការសមស្រប ក្នុងការអភិវឌ្ឍសមត្ថភាព។[49]

ជំនួយបច្ចេកទេសនឹងនៅតែជាចំណែកមួយដ៏សំខាន់ សម្រាប់ធ្វើការអភិវឌ្ឍសមត្ថភាព ព្រោះគោលបំណងនៃជំនួយបច្ចេកទេស គឺការផ្ទេរចំណេះដឹង និងជំនាញដល់មន្ត្រី បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលឃុំ សង្កាត់ ដែលត្រូវតែពង្រឹងសមត្ថភាពដើម្បីបំពេញការងារដោយមានការចូលរួម គណនេយ្យភាព តម្លាភាព និងការឆ្លើយតបក្នុងការផ្តល់សេវាសាធារណៈសម្រាប់អភិវឌ្ឍមូលដ្ឋាន ។ ការអភិវឌ្ឍសមត្ថភាពនឹងត្រូវផ្តោតសំខាន់ទៅលើការប្រឹក្សាយោបល់ និងការគាំទ្រដល់ក្រុមប្រឹក្សា ការផ្តល់សម្ភារ និងឯកសារព័ត៌មាន ការឆ្លើយតបភ្លាមៗតាមរយៈប្រព័ន្ធអ៊ិនធឺណែត(សារអេឡិចត្រូនិច ប្រព័ន្ធទំនាក់ទំនងសង្គម) និងទូរស័ព្ទ។ ម្យ៉ាងទៀតក៏មានការសម្របសម្រួលសិក្ខាសាលា និងវេទិកានានា ការរៀបចំវគ្គបណ្តុះបណ្តាលដោយផ្ទាល់ តាមរយៈសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬពីថ្នាក់ជាតិផងដែរ។

យន្តការគាំទ្រខាងលើ នឹងធ្វើឱ្យរដ្ឋបាលឃុំ សង្កាត់មានការយល់ដឹងច្រើន ហើយអាចអភិវឌ្ឍឃុំ សង្កាត់ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញកិច្ចការនានាក្នុងឃុំ សង្កាត់។

[48] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទីពីរ(២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ* (ភ្នំពេញ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ធ្នូ ២០១៤), ៥៤។

[49] ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, លេខ១៩៥០ ប្រ.ក ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០២, ប្រការ៣។

## ២.៨. ការកាត់បន្ថយភាពក្រីក្រ

ភាពក្រីក្ររបស់ប្រជាជន ជាបញ្ហាមួយ ដែលត្រូវបានគេយកចិត្តទុកដាក់ និងស្វែងវិធីសាស្ត្រ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាព។ ហើយភាពក្រីក្រ គឺជាឧបសគ្គមួយដល់ការអភិវឌ្ឍ ប្រជាធិបតេយ្យនៅមូលដ្ឋាន។ ភាពក្រីក្រ បានបង្ខំឱ្យប្រជាជនធ្វើការគ្មានឈប់សម្រាក ដើម្បីចិញ្ចឹម ជីវិត។ ប្រជាជនដែលក្រីក្រ ត្រូវធ្វើការផ្លាស់ប្តូរទីលំនៅ និងចំណាកស្រុក ដើម្បីស្វែងរកការងារ ឬ មុខរបរដែលអាចរកប្រាក់បានច្រើន។ ហេតុដូចនេះហើយ ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុង សកម្មភាពសាធារណៈ ក៏មិនបានល្អប្រសើរដែរ ហើយប្រជាធិបតេយ្យក៏មិនបានជ្រួលជ្រាបដល់ ប្រជាពលរដ្ឋដែរ។

ភាពក្រីក្រ ជាបញ្ហាដែលកើតឡើងនៅលើពិភពលោកទាំងមូល មិនថាកើតមានតែក្នុង ប្រទេសក្រីក្រ ឬប្រទេសកំពុងអភិវឌ្ឍនោះទេ តែសូម្បីប្រទេសអភិវឌ្ឍក៏ជួបប្រទះនឹងបញ្ហានេះដែរ។ ដោយឡែកនៅកម្ពុជា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើការកាត់បន្ថយភាពក្រី ក្រនេះ។ ហេតុនេះ ដើម្បីដោះស្រាយបញ្ហានេះ នៅឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័ត យល់ព្រមអនុវត្តតាមគោលដៅទាំង ៨ នៃគោលដៅអភិវឌ្ឍសហសវត្សរ៍របស់អង្គការសហប្រជាជាតិ។[50] ក្នុងចំណោមគោលដៅទាំង ៨នេះ គោលដៅទី១ គឺជាគោលដៅដើម្បីការលុបបំបាត់នូវភាពក្រីក្រ និងការស្រេកឃ្លានដាច់ខាត។

នៅក្នុងកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ ការយកចិត្តទុកដាក់បន្ថែមទៅលើការកាត់បន្ថយ ភាពក្រីក្ររបស់ប្រជាជន។ ការធ្វើកំណែទម្រង់លើចំណុចនេះ នឹងធ្វើការពង្រឹងសមត្ថភាពរបស់រដ្ឋ បាលឃុំ សង្កាត់ ក្នុងការប្រើប្រាស់ធនធាននានារបស់ខ្លួន ដើម្បីគាំទ្រ និងឆ្លើយតបទៅនឹង សកម្មភាពនៃការកាត់បន្ថយភាពក្រីក្រនៅក្នុងមូលដ្ឋានរបស់ខ្លួន ជាពិសេសក្រុមជនងាយរងគ្រោះ ប្រជាជនក្រីក្រ ស្ត្រី និងកុមារ ក្នុងគោលបំណងសម្រេចនូវគោលដៅអភិវឌ្ឍសហសវត្សរ៍របស់ រាជរដ្ឋាភិបាលកម្ពុជា។

## ២.៩. វិមជ្ឈការហិរញ្ញវត្ថុ

ច្បាប់រៀបចំអង្គការបានកំណត់អំពីសិទ្ធិអំណាចរបស់រដ្ឋបាលមូលដ្ឋានមួយនេះ មានធនធាន ហិរញ្ញវត្ថុផ្ទាល់ ដោយអាចប្រើប្រាស់វាបាន ដើម្បីបម្រើផលប្រយោជន៍មូលដ្ឋានរបស់ខ្លួន។ ធនធាន ហិរញ្ញវត្ថុឃុំ សង្កាត់ បានមកពីប្រភពចំណូលផ្ទាល់នៅមូលដ្ឋាន និងការផ្ទេរធនធានពីថ្នាក់ជាតិ តាមរយៈមូលនិធិគ្មានភ្ជាប់លក្ខខណ្ឌបន្ថែមទៅលើមូលនិធិឃុំ សង្កាត់។ ថ្វីបើឃុំ សង្កាត់ មានសិទ្ធិ អំណាចក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុផ្ទាល់ក៏ដោយ ក៏មិនមែនថាប្រាកដថា

[50] Sherif Rushdyç Achiecing Cambodia´s Millennium Development Goals—Gap Analysis, 2009, October 15 ។

អនុវត្តប្រកបដោយប្រសិទ្ធភាពនោះដែរ ។ ដើម្បីធ្វើឱ្យការងារអភិវឌ្ឍមូលដ្ឋានកាន់តែល្អប្រសើរ រាជរដ្ឋាភិបាល បានកំពុងតែបន្តសកម្មភាពពង្រឹងការអនុវត្តហិរញ្ញវត្ថុរបស់ឃុំ សង្កាត់ ដោយការវិភាជន៍មូលនិធិបន្ថែម ទៅលើមូលនិធិ ដែលឃុំ សង្កាត់។ មូលនិធិដែលវិភាជន៍ទៅឱ្យឃុំ សង្កាត់នេះ គឺជាមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ដែលមូលនិធិនេះទទួលបាននូវការរួមធនធានប្រចាំឆ្នាំពីថវិការដ្ឋ។ ការវិភាជន៍ធនធានពីមូលនិធិឃុំ សង្កាត់សម្រាប់ឃុំ សង្កាត់នីមួយៗ ត្រូវបានធ្វើឡើងតាមរូបមន្តដោយផ្អែកតាមលក្ខណៈវិនិច្ឆ័យ និងសន្ទស្សន៍ជាក់លាក់ដូចជា ចំណែកស្មើគ្នាជាមូលដ្ឋាន គឺសមាសភាគរដ្ឋបាលទូទៅ និងសមាសភាគអភិវឌ្ឍមូលដ្ឋាន។[51]

[51] ដូច៤៨, ៧០។

# ជំពូកទី៣
# លទ្ធផលដែលសម្រេចបាន

ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ រាជរដ្ឋាភិបាលបានសម្រេចនូវសមិទ្ធផលជាច្រើនក្នុងកិច្ចការកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងរដ្ឋឱ្យមានសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍជានិរន្តរ ក្នុងឱកាសដែលប្រទេសជាតិកំពុងតែមានសុខសន្តិភាព និងស្ថេរភាពនយោបាយ។ កំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ ចាប់ផ្តើមតាំងពី១៩៩៣មកម្ល៉េះ តែមិនមានលទ្ធផលនោះទេ ទើបតែឆ្នាំ២០០១មកទេ ដែលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ត្រូវបានអនុម័ត ហើយបានត្រួសត្រាយផ្លូវសម្រាប់ការអនុវត្តនូវការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បែបវិមជ្ឈការ។

កំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ បានបង្កើតឱ្យមានរដ្ឋបាលវិមជ្ឈការ ដែលកើតឡើងដោយការបោះឆ្នោតពីប្រជាពលរដ្ឋដោយផ្ទាល់។ រហូតមកដល់បច្ចុប្បន្ននេះ កម្ពុជាបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ចំនួនបីដងរួចមកហើយ គឺលើកទី១ នៅខែកុម្ភៈ ឆ្នាំ២០០២ លើកទី២ នៅខែមេសា ឆ្នាំ២០០៧ និងលើកទី៣ នៅខែ ឆ្នាំ២០១២។ ដូច្នេះក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាតំណាងរបស់ប្រជាពលរដ្ឋ និងធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់ប្រជាពលរដ្ឋ។ ដោយហេតុថាដើម្បីផលប្រយោជន៍ប្រជាពលរដ្ឋ ដូចនេះប្រជាពលរដ្ឋត្រូវតែចូលរួមដោយផ្ទាល់ជាមួយនឹងឃុំ សង្កាត់ដើម្បីផ្តល់យោបល់លើគម្រោងអភិវឌ្ឍន៍នានានៅក្នុងមូលដ្ឋានរបស់ខ្លួន។ ការអនុវត្ត ព្រមជាមួយនិងលទ្ធផលដែលទទួលបានកន្លង មួយផ្នែកធំសម្រេចបានតាមរយៈការបង្កើតមូលនិធិឃុំ សង្កាត់ដែលនាំឱ្យមានលំហូរថវិកាកើនឡើងជានិច្ចទៅឱ្យរដ្ឋបាលឃុំ សង្កាត់។[52] ថវិកាជាតិដែលវិភាជន៍ទៅឱ្យមូលនិធិឃុំ សង្កាត់បានបង្កើន១,៥% នៃចំណូលចរន្តក្នុងស្រុកនៅក្នុងឆ្នាំ២០០២ រហូតដល់ ២,៧៥%ក្នុងឆ្នាំ២០០៩។[53]

រាជរដ្ឋាភិបាលក្នុងសកម្មភាពបន្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ឱ្យកាន់តែល្អប្រសើរជាងមុន ក៏បានអនុម័តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅខែមិថុនា ឆ្នាំ២០០៥ ដោយបានដាក់ចេញនូវចក្ខុវិស័យ សម្រាប់ចង្អុលទិសដល់ការរៀបចំកំណែទម្រង់ប្រព័ន្ធអភិបាលកិច្ចសម្រាប់ថ្នាក់ក្រោមជាតិ និងជាពិសេសគឺបន្តពង្រឹងកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់បន្ថែមទៀត។

[52] ដូច៥៦, ៧។

[53] ដដែល។

### ៣.១. ភាពជាតំណាង

វិមជ្ឈការ បានបើកឱកាសខាងនយោបាយ សម្រាប់ការធ្វើការកែលម្អភាពជាតំណាង នៅកម្រិតមូលដ្ឋាននៃគណបក្សនយោបាយ និងក្រុមប្រជាពលរដ្ឋមានភាពទន់ខ្សោយ រួមទាំងស្ត្រីផង។ ភាពជាតំណាងនេះ បានចាប់ផ្ដើមមានឡើងដោយការបង្កើតច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ដោយហេតុថាក្រុមប្រឹក្សាត្រូវបានកើតចេញពីប្រជាពលរដ្ឋ ដូច្នេះក្រុមប្រឹក្សាត្រូវតែធ្វើប្រយោជន៍ ដើម្បីប្រជាពលរដ្ឋ។

ភាពជាតំណាង មិនត្រឹមតែឆ្លុះបញ្ចាំងនូវការយល់ដឹងពីគោលការណ៍ប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយតភ្ជាប់គម្លាតរវាងរដ្ឋ/អាជ្ញាធរ និងប្រជាពលរដ្ឋទៀតផង។ ការកែលម្អភាពជាតំណាង បានភ្ជាប់គម្លាតរវាងប្រជាពលរដ្ឋ និងរដ្ឋបានល្អជាមុន។ តាំងពីមានកំណែទម្រង់មក បរិយាកាសប្រកបដោយភាពភ័យខ្លាច ការគាបសង្កត់ និងការបង្ខិតបង្ខំ ក៏បានរលាយបាត់ជាបណ្ដើរៗ។[54] ម្យ៉ាងទៀតថ្វីបើ សមាជិកក្រុមប្រឹក្សានីមួយៗ អាចមកពីគណបក្សផ្សេងៗគ្នាក៏ដោយ តែក្នុងពេលដែលបំពេញការងារ គឺក្រុមប្រឹក្សាត្រូវតំណាងឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានទាំងមូល ដោយមិនប្រកាន់និន្នាការនយោបាយអ្វីទាំងអស់។ កំណែទម្រង់ភាពជាតំណាងនេះ បង្កើតឱ្យមានភាពទន់ភ្លន់នៃឥរិយាបថរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ បូករួមនឹងការឆ្លើយតបរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ។ ដូចនេះឃើញថា ភាពជាតំណាងនេះនឹងកាន់តែមានភាពប្រសើរឡើងជាលំដាប់នាពេលខាងមុខ។

### ៣.២. មុខងារ និងធនធាន

#### ៣.២.១ មុខងាររដ្ឋបាលទូទៅរបស់ឃុំ សង្កាត់

ឃុំ សង្កាត់ ត្រូវដំណើរការរដ្ឋបាលទូទៅរបស់ខ្លួន គឺផ្ដល់នូវសេវាអគ្រានុកូលដ្ឋានប្រចាំថ្ងៃមិនឱ្យអាក់ខាន។ ឃុំ សង្កាត់ អាចដំណើរការរដ្ឋបាលទៅបានក្នុងឆ្នាំនីមួយៗ ដោយមានការវិភាជន៍ថវិកាពីរដ្ឋជារៀងរាល់ឆ្នាំ។ ថវិកាសម្រាប់ដំណើរការរដ្ឋបាល ត្រូវប្រើប្រាស់សម្រាប់បើកប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្សេងៗទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មការភូមិ និងចំណាយលើប្រតិបត្តិការថ្លៃទឹក ភ្លើង ការធ្វើដំណើរ និងផ្សេងៗទៀត។[55]

ក្នុងមុខងារផ្ដល់សេវាអគ្រានុកូលដ្ឋាន ឃុំ សង្កាត់ មានតួនាទីសំខាន់ក្នុងការផ្ដល់នូវសេវាមូលដ្ឋានដល់ប្រជាពលរដ្ឋនៅតាមដែនសមត្ថកិច្ចរៀងៗខ្លួន ដែលសេវានោះមានសារៈសំខាន់ មិន

[54] ហេង សីហា, គឹម សេតារា និងសូ សុខប៊ុនធឿន, *អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យក្នុងប្រព័ន្ធនយោបាយបែបកូនកាត់៖ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងបរិបទប្រទេសកម្ពុជា*, លេខ១៥ (២០១១), ៣។

[55] គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ* (ភ្នំពេញ៖គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ), ៦។

អាចខ្វះបានចំពោះការរស់នៅរបស់ប្រជាពលរដ្ឋ។ សេវាអត្រានុកូលដ្ឋាន ជាសេវាដែលឃុំ សង្កាត់ត្រូវចេញសំបុត្រកំណើត សំបុត្រមរណភាព សំបុត្រអាពាហ៍ពិពាហ៍ សេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋានផ្សេងទៀត សម្រាប់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ច។[56]

លទ្ធផលនៃកំណែទម្រង់ បានធ្វើឱ្យមានការកំណត់ច្បាស់លាស់នូវតម្លៃ សុពលភាព និងរយៈពេលដែលត្រូវបំពេញ ដែលមានកំណត់ក្នុងប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**តារាងទី១៖ តម្លៃសេវាអត្រានុកូលដ្ឋាន**[57]

| ល.រ | បរិយាយ | តម្លៃសេវា (រៀល) | រយៈពេល | សុពលភាព (ថ្ងៃធ្វើការ) | ចំនួន |
|---|---|---|---|---|---|
| **១-ការងារអត្រានុកូលដ្ឋាន** | | | | | |
| **១.១-ចំពោះឃុំ សង្កាត់នៅរាជធានី ខេត្ត** | | | | | |
| ១ | សំបុត្រកំណើត(ក្នុងរយៈពេល៣០ថ្ងៃក្រោយថ្ងៃកើត) | មិនយកកម្រៃ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ២ | សំបុត្របញ្ជាក់កំណើត | ១០ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត | ៣ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៤ | ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ | ៣ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរជាមួយពលរដ្ឋខ្មែរ) | ១៥ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦ | សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរជាមួយជនបរទេស) | ៣០ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៧ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៣ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៨ | សំបុត្រមរណៈភាព(ក្នុងរយៈពេល ១៥ថ្ងៃ) | មិនយកកម្រៃ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៩ | សំបុត្រមរណៈភាព(ហួសរយៈពេល ១៥ថ្ងៃ ក្នុងឆ្នាំ) | ៣ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ១០ | សេចក្តីចម្លងសំបុត្រមរណៈភាព | ២ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| **២-ការចេញលិខិតអនុញ្ញាត** | | | | | |

[56] ដូច៥៥, ២។

[57] ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ៣៨៥៦ប្រ.ក, ០២ ធ្នូ ២០១៣, ២២-២៤ (ពីពេលនេះទៅហៅថាប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាល)។

| ២.១-ចំពោះឃុំ សង្កាត់រាជធានី ខេត្ត | | | | | |
|---|---|---|---|---|---|
| ១ | លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬ ពោះម៉ាយ | ៥ ០០០ | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ២ | លិខិតបញ្ជាក់ទីលំនៅ | ៤ ០០០ | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ៣ | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | ៤ ០០០ | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ ច្បាប់ |
| ៤ | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | ១០ ០០០ | ៧ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| ៥ | លិខិតបញ្ជាក់ទាយាទ | ៥ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ សន្លឹក |
| ៦ | លិខិតបញ្ជាក់កិរិយាមារយាទ | ៥ ០០០ | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ៧ | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | ៥ ០០០ | ៣ ថ្ងៃ | ៣ ខែ | ១ សន្លឹក |
| ៨ | លិខិតបញ្ជាក់ទិញ លក់ សត្វពាហនៈ(គិតក្នុង១ក្បាល) | ៣ ០០០ | ៣ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ៩ | លិខិតបញ្ជាក់តបណ្តាញអគ្គិសនី | ៥ ០០០ | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ១០ | លិខិតបញ្ជាក់តបណ្តាញទឹកស្អាត | ៥ ០០០ | ៧ ថ្ងៃ | ១ លើក | ១ សន្លឹក |
| ១១ | លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ | ១០ ០០០ | ៣ ថ្ងៃ | ចប់កិច្ចសន្យា | ១ ច្បាប់ |
| ១២ | លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ | ៥ ០០០ | ៧ ថ្ងៃ | ១ ឆ្នាំ | ១ ច្បាប់ |
| ១៣ | លិខិតបញ្ជាក់លើលិខិតស្នាមផ្សេងៗ (ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) | ៥ ០០០ | ៣ ថ្ងៃ | អចិន្ត្រៃយ៍ | ១ ច្បាប់ |
| *បញ្ជាក់៖ ចំពោះតម្លៃសេវាដែលបានកំណត់ខាងលើនេះមិនទាន់គិតបញ្ចូលថ្លៃតែមប្រ៍សារពើពន្ធនៅឡើយ។ | | | | | |

*(ប្រភព៖ ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៣)*

**សម្គាល់៖** តម្លៃសេវាអគ្រានុកូលដ្ឋានសម្រាប់ខេត្តរតនគីរី មណ្ឌលគីរី ស្ទឹងត្រែង ព្រះវិហារ និងខេត្តឧត្តរមានជ័យ មានតម្លៃទាបជាងតម្លៃដែលកំណត់ក្នុងតារាងទី១។[58]

### ៣.២.២. ការអភិវឌ្ឍរបស់ឃុំ សង្កាត់

ការអភិវឌ្ឍ របស់ឃុំ សង្កាត់ផ្តោតទៅលើវិស័យពីរយ៉ាង គឺ វិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសេវាសង្គម។ ការកសាង និងការកែលម្អផ្សេងៗដូចជា ផ្លូវ ប្រព័ន្ធធារាសាស្ត្រ ជាការងារដែលឃុំ សង្កាត់គ្រប់អាណត្តិបានយកចិត្តទុកដាក់ខ្លាំងបំផុត។ ជាក់ស្តែងនៅខេត្តបន្ទាយមានជ័យ មានការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ ដែលគម្រោងសម្រាប់ដេញថ្លៃ គឺពាក់ព័ន្ធនឹងការងារសាងសង់ សំណង់អគារ ប្រឡាយ ទំនប់ ផ្លូវ

[58] ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាល, ២២-២៤។

ដីស ផ្លូវក្រួសក្រហម ។ល។[59] ឯនៅខេត្តបាត់ដំបង ក៏មានការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៣ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ សម្រាប់គម្រោងសាងសង់ សំណង់ អគារ ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហមផងដែរ។[60] រីឯរាជធានីភ្នំពេញវិញ ក៏មានការរៀបចំ បញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤ សម្រាប់ គម្រោងសាងសង់ សំណង់អគារ ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហមនេះផងដែរ។[61] ចំពោះ ខេត្តដទៃទៀត ក៏មានរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤នេះផងដែរ។[62] ការអភិវឌ្ឍហេដ្ឋា រចនាសម្ព័ន្ធនេះ ឃុំ សង្កាត់បានប្រើប្រាស់មូលនិធិឃុំ សង្កាត់ ដែលបានមកពីចំណូលផ្ទាល់ និងការ វិភាជន៍ពីរដ្ឋបន្ថែមទៀត។ ដោយឡែកចំពោះសេវាសង្គមវិញ ឃុំ សង្កាត់ត្រូវទទួលខុសត្រូវទៅលើ វិស័យសេវាសង្គមដែលមានដូចជា សុខាភិបាល អប់រំ ឧបត្ថម្ភអ្នកក្រីក្រ ការគ្រប់គ្រងគ្រោះមហន្តរាយ ជាដើម។[63]

## ៣.៣. គណនេយ្យភាព និងការឆ្លើយតប

ក្រោយពីបានអនុវត្តនូវកំណែទម្រង់វិមជ្ឈការរដ្ឋបាលឃុំ សង្កាត់កន្លងមក ឃើញថាមានការ ប្រែប្រួលច្រើន ពាក់ព័ន្ធនឹងគណនេយ្យភាព និងការឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ក្រុមប្រឹក្សា និងអ្នករដ្ឋបាលដទៃទៀត។ ក្រុមប្រឹក្សាឃុំ សង្កាត់ មានទំនួលខុសត្រូវចំពោះប្រជាពលរដ្ឋ ហើយ អនុវត្តតួនាទីរបស់ខ្លួនដោយផ្អែកលើគោលការណ៍នៃគណនេយ្យភាព។ ប្រជាពលរដ្ឋមូលដ្ឋានយល់ ថា ខ្លួនទទួលបានសិទ្ធិអំណាចពីដំណើរការវិមជ្ឈការ ដោយអាចទាមទារគណនេយ្យភាពពីថ្នាក់ ដឹកនាំ ដែលជាប់ឆ្នោត បានតាមរយៈការប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួន ក្នុងការបោះឆ្នោត ទម្លាក់ពីតំណែងនូវសមាជិកក្រុមប្រឹក្សាណាដែលអសមត្ថភាព ហើយប្រជាពលរដ្ឋមិនពេញចិត្តនឹង សកម្មភាពរបស់ក្រុមប្រឹក្សានោះ។

---

[59] សេចក្តីជូនដំណឹងស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ របស់សាលាខេត្តបន្ទាយមានជ័យ, លេខ ៣៧៣ សជណ, ០៥ កញ្ញា ២០១៣។

[60] សេចក្តីជូនដំណឹងស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ របស់សាលាខេត្តបាត់ដំបង, លេខ ៩៧ សជណ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

[61] សេចក្តីជូនដំណឹងស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ របស់សាលារាជធានីភ្នំពេញ, លេខ ១៧ សជណ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៣។

[62] គណៈកម្មធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៣*, ( 2013 Contractor Pre-qualification ), http://www.ncdd.gov.kh/km/media-center/announcement/336-contractor-2014, (ថតចម្លងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦)។

[63] ដូច៥៥, ៦១

បើទោះជាយ៉ាងនេះក៏ដោយ ការងារកំណែទម្រង់លើចំណុចនេះនៅតែបន្ត តាមរយៈការរៀបចំវេទិកាពិគ្រោះយោបល់ជាសាធារណៈ និងការអនុវត្តនូវផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គម ដើម្បីធានាដល់ការបង្កើនការប្រាស្រ័យ ទាក់ទងរវាងរដ្ឋបាល ជាមួយប្រជាពលរដ្ឋ និងជម្រុញឱ្យមានការចូលរួមបន្ថែមទៀតពីប្រជាពលរដ្ឋក្នុងតាមដានពិនិត្យទៅលើការបំពេញការងាររបស់រដ្ឋបាល។ ក្នុងឆ្នាំ២០១៤ លេខាធិការដ្ឋាន គ.ជ.អ.ប បានសម្រេចជ្រើសរើសយកស្រុកចំនួន២២ ក្នុងខេត្តចំនួន១២ ដើម្បីអនុវត្តសាកល្បងការងារគណនេយ្យភាពសង្គមសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះមានសាលារៀនចំនួន ១៩៦ មណ្ឌលសុខភាពចំនួន ១៣៦ ហើយក៏មានអនុវត្តសម្រាប់ថ្នាក់ឃុំផងដែរ គឺមានសាលាឃុំចំនួន ១៨៦។[64] ក្នុងនោះដែរផ្ទាំងធំព័ត៌មានសម្រាប់ប្រជាពលរដ្ឋចំនួន ២៥៨០០ច្បាប់ និងសៀវភៅតូចស្តីពីព័ត៌មានសម្រាប់ប្រជាពលរដ្ឋចំនួន ២៦០០ក្បាល ត្រូវបានបោះពុម្ពផ្សាយ និងចែកជូនដល់បណ្តាស្រុកគោលដៅទាំងអស់ដើម្បីធ្វើការបិទផ្សាយនៅតាមសាលារៀន មណ្ឌលសុខភាព និងសាលាឃុំ សម្រាប់ប្រជាពលរដ្ឋ។[65] ការធ្វើបែបនេះ ជាសកម្មភាពដែលធ្វើកំណែទម្រង់វិមជ្ឈការនៅថ្នាក់ស្រុក ហើយជាពិសេសគឺការបន្តធ្វើកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់បន្ថែមទៀតឱ្យប្រជាពលរដ្ឋជ្រាបជាព័ត៌មាន និងគោលបំណងពង្រឹងលទ្ធិប្រជាធិបតេយ្យ។

មួយវិញទៀត គេក៏សង្កេតឃើញដែលថា មានកំណើនការឆ្លើយតបពីថ្នាក់ដឹកនាំនៅមូលដ្ឋានផងដែរ។ កាលពីឆ្នាំ២០១២ កន្លងទៅតាមរយៈសកម្មភាពក្នុងសង្គមរបស់ឃុំ សង្កាត់ បានសម្រេចនូវលទ្ធផលដូចខាងក្រោម៖

**តារាងទី២៖ ការអនុវត្តសកម្មភាពសេវាសង្គមរបស់ឃុំ សង្កាត់[66]**

| សកម្មភាព | លទ្ធផល |
|---|---|
| ការងារអប់រំ | ការផ្តល់សេវាគាំទ្រសិក្សាសហគមន៍ចំនួន ២០៩៥សាលា តាមរយៈការជួយឧបត្ថម្ភប្រាក់បៀវត្សដល់គ្រូមតេយ្យសិក្សាសហគមន៍ និងសម្ភារសិក្សា ដែលមានកុមារសរុបចំនួន |

64 គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, *ព្រឹត្តិបត្រព័ត៌មាន.* ឆ្នាំទី១, លេខ១ (២០១៥)។

65 ដដែល។

66 ស ខេង, *របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអនុវត្ត៣ឆ្នាំដំបូង(ផអ៣) ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១២* (ភ្នំពេញ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កក្កដា ២០១២), ៣៩។

| | |
|---|---|
| | ប្រមាណ ៥១៤០៤នាក់ (កុមារី៥៣%) បានចូលរៀន។ |
| ការលើកកម្ពស់សុខមាលភាពរបស់ប្រជាពលរដ្ឋ | – ការផ្តល់សេវាគាំទ្រដល់សាលារៀនចំនួន ៨៥៩ និងមណ្ឌលសុខភាពចំនួន ២២៥ កែលម្អអនាម័យ។<br>– ការផ្តល់សេវាគាំទ្រគ្រួសារងាយរងគ្រោះចំនួន ៦.០៩៣គ្រួសារ កែលម្អអនាម័យ។<br>– ការផ្តល់សេវាគាំទ្រគ្រួសារងាយរងគ្រោះចំនួន ៧.៣៧៧គ្រួសារ ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់។<br>– ការផ្តល់សេវាជួយគាំទ្រស្ត្រីមានផ្ទៃពោះចំនួន ៧.៥៥៣នាក់ ដោយបានបញ្ជូនស្ត្រីមានផ្ទៃពោះទាំងនោះ ទៅសម្រាលកូននៅមណ្ឌលសុខភាព តាមរយៈការជួយគាំទ្រថ្លៃធ្វើដំណើរ |

*(ប្រភព៖ របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអនុវត្ត៣ឆ្នាំដំបូង(ផអ៣) ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១២)*

## ៣.៤. ការចូលរួម

លេខាធិការដ្ឋាន គ.ជ.អ.ប គាំទ្រថវិកាដោយអង្គការយូនីសេហ្វ និងអង្គការផេកគាំទ្រថវិកាពីទីភ្នាក់ងារអង្គការសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍរបស់ប្រទេសស៊ុយអែត បានសហការជាមួយគ្នា ក្នុងគោលបំណង សម្របសម្រួលការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការតាមដាន និងវាយតម្លៃទៅលើការអនុវត្តសកម្មភាព និងការផ្តល់សេវារបស់ក្រុមប្រឹក្សា មណ្ឌលសុខភាព និងសាលាបឋមសិក្សាក្នុងឃុំចំនួន៤៣ ។ គម្រោងនេះ បានចាប់ផ្តើមពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ដែលបានសម្រេចលទ្ធផលរួមមាន៖

**តារាងទី៣៖ គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**[67]

| សកម្មភាព | ចំនួនអ្នកចូលរួម |
|---|---|
| រៀបចំប្រជុំផ្សព្វផ្សាយនៅក្នុងឃុំគោលដៅទាំង៤៣ | ១,២២០នាក់(ស្ត្រី៣៨%) |
| រៀបចំកិច្ចប្រជុំរួមគ្នាតាមវិស័យចំនួន ១២៦ដង | ១,២៧១នាក់(ស្ត្រី៦០%) |
| រៀបចំកិច្ចប្រជុំរួមពហុវិស័យចំនួន ៤៣ដង | ៤៤៧នាក់(ស្ត្រី៥១%) |

*(ប្រភព៖ ព្រឹត្តិបត្រលើកទី៩៖គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៥)*

ការរៀបចំឱ្យមានការដាក់ពិន្ទុ និងការវាយតម្លៃពីប្រជាពលរដ្ឋ ចំពោះសកម្មភាព និងការផ្តល់សេវារបស់ក្រុមប្រឹក្សា មណ្ឌលសុខភាព និងសាលាបឋមសិក្សាក្នុងថ្នាក់ឃុំនេះ បង្ហាញឱ្យឃើញនូវគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ឃុំ ចំពោះប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះ ការដាក់ពិន្ទុ និងការវាយតម្លៃពីប្រជាពលរដ្ឋ ក៏បានបង្កើននូវវត្តមានរបស់ប្រជាពលរដ្ឋក្នុងវិស័យសាធារណៈនៅមូលដ្ឋានឃុំ របស់ខ្លួនផងដែរ។ គម្រោងដែលរៀបចំដោយអង្គការផេក និងលេខាធិការដ្ឋាន គ.ជ.អ.ប ជាលទ្ធផលមួយ ដែលបានឆ្លងកាត់ដំណើរការដាក់ពិន្ទុ និងពិភាក្សាផ្ទាល់ជាមួយប្រជាពលរដ្ឋ អ្នកផ្តល់សេវាភាគច្រើនបង្ហាញឥរិយាបថវិជ្ជមាន និងទទួលយកយោបល់ពីប្រជាពលរដ្ឋ ហើយដាក់ពិន្ទុ និងសំណូមពរឱ្យបន្តអនុវត្តជារៀងឆ្នាំ។[68]

ក្រៅពីនេះ គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលត្រូវបានធ្វើឡើង នៅតាមបណ្តាខេត្តគោលដៅ(ពោធិ៍សាត់ បាត់ដំបង កំពង់ចាម និងមណ្ឌលគីរី) បានគាំទ្រឃុំ សង្កាត់ចំនួន៦៣ រៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់បានចំនួន ៩ដង មានកិច្ចប្រជុំប្រចាំខែក្រុមប្រឹក្សា ៣៦ដង និងឃុំ សង្កាត់ ១៨៤ដង និងកិច្ចពិគ្រោះយោបល់មូលដ្ឋាន ៤៤ដង ក្នុងរយៈពេល ៦ខែ ដោយគិតចាប់ពីខែតុលា ឆ្នាំ២០១៤ ដល់ខែមីនា ឆ្នាំ២០១៥[69]។ ក្រោយពីសកម្មភាពខាងលើ ត្រូវបានបញ្ចប់ ក្រុមប្រឹក្សាបានឆ្លើយតប

[67] អង្គការផេក, *ព្រឹត្តិបត្រលើកទី៩គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*, លេខ៩ (២០១៥)។

[68] ដដែល។

[69] ដដែល។

ចម្ងល់របស់ប្រជាពលរដ្ឋ និងបានចាត់វិធានការដោះស្រាយបញ្ហាដែលប្រជាពលរដ្ឋបានលើក ក៏ដូចជាសំណូមពរឱ្យមានដំណោះស្រាយ។ បញ្ហា និងដំណោះស្រាយមួយចំនួនមានដូចជា៖

- ការកាប់បំផ្លាញព្រៃលិចទឹករបស់សហគមន៍ភូមិក្រងវែង ឃុំស្នាអន្សា ស្រុកក្រគ ខេត្តពោធិ៍សាត់ ដែលលើកឡើងដោយលោក **ប៉ែន សុខុម** តំណាងសហគមន៍ព្រៃឈើ។ ក្រុមប្រឹក្សាឃុំ បានសហការជាមួយមន្ត្រីរដ្ឋបានជលផល ប៉ូលីស និងប្រធានភូមិ ចុះផ្សព្វផ្សាយច្បាប់ជលផល និងបង្កើតក្រុមល្បាត ការពារតំបន់ព្រៃ លិចទឹកសហគមន៍ នៅខែវិច្ឆិកា ឆ្នាំ២០១៤។
- តម្រូវការកន្លែងរង់ចាំ សម្រាប់អ្នកជំងឺនៅមណ្ឌលសុខភាពឃុំវត្តតាមឹម ស្រុកសង្កែ ត្រូវបានប្រធានមណ្ឌលសុខភាពសហការជាមួយក្រុមប្រឹក្សា និងស្ថាប័នពាក់ព័ន្ធដោះស្រាយជូនប្រជាពលរដ្ឋ នៅខែតុលា ឆ្នាំ២០១៤ ដោយបានសង់អគារទំហំ ១០ម៉ែត្រ គុណនឹង ៦ម៉ែត្រ។[70]

មានបញ្ហា និងការដោះស្រាយ ផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានសហការជាមួយអ្នកពាក់ព័ន្ធ ហើយធ្វើការឆ្លើយតបយ៉ាងឆាប់រហ័សរបស់ក្រុមប្រឹក្សាទៅតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន ដើម្បីបម្រើផលប្រយោជន៍ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។

ដូច្នេះឃើញថា ការចូលរួមរបស់ប្រជាពលរដ្ឋ ពិតជាមានសារៈសំខាន់ដល់ការងាររបស់ឃុំ សង្កាត់ពិតមែន ហើយការឆ្លើយតបរបស់ឃុំ សង្កាត់ក៏ឆាប់រហ័សថែមទៀត។

### ៣.៥. ការអភិវឌ្ឍសមត្ថភាព

កិច្ចការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលឃុំ សង្កាត់ ក៏ជាការងារមួយរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ។ កន្លងមកការអភិវឌ្ឍសមត្ថភាព នាយកដ្ឋានរដ្ឋបាលមូលដ្ឋានបានសម្រេចនូវលទ្ធផលដូចតទៅ៖

**តារាងទី៤៖ របាយការណ៍ស្ដីពីការអភិវឌ្ឍសមត្ថភាពរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានឆ្នាំ២០១០**[71]

| **ឆ្នាំ២០១០** | |
|---|---|
| **សកម្មភាព** | **ក្រុមគោលដៅ** |
| បានរៀបចំការប្រឡងវាយតម្លៃសមត្ថភាពរបស់ស្មៀនឃុំ សង្កាត់ | ឃុំ សង្កាត់នៅទូទាំងប្រទេសដែលមានវត្តមាន **១៦០៥ នាក់(ស្ត្រី១១៨នាក់)**។<br>ជាលទ្ធផលស្មៀនចំនួន **១២៥៩នាក់(៧៨%)** បាន |

[70] ដូច៦៧។

[71] ឃិន ម៉ាលីណា, *របាយការណ៍ស្ដីពីសកម្មភាពការងារប្រចាំឆ្នាំ២០១០ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន*, លេខ០០៩ លស/រ.ម (ភ្នំពេញ៖ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, ១១ កុម្ភៈ ២០១១), ៣។

| | |
|---|---|
| | ប្រឡងជាប់ ហើយស្មៀនឃុំ សង្កាត់ប្រឡងមិនជាប់មានប្រមាណ **៣៨៦នាក់** ដែលចាំបាច់ត្រូវបំពេញសមត្ថភាពបន្ថែមទៀត។ |
| បានបើកវគ្គបណ្តុះបណ្តាលសាកល្បង ស្តីពីគោលគំនិតនៃការអភិវឌ្ឍឃុំ សង្កាត់ | នៅខេត្តបាត់ដំបង ដែលមានសិក្ខាកាមជាមេឃុំ ចៅសង្កាត់ ស្មៀនឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធផ្សេងទៀតសរុបចំនួន ៣២រូប។ |
| បានបើកវគ្គបណ្តុះបណ្តាលសាកល្បងដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ស្តីពីសកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍសេវាសង្គមពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សា សហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ | នៅខេត្តព្រៃវែង ដែលមានសិក្ខាកាមសរុបប្រមាណ ៣២រូប។ |
| បានបើកវគ្គបណ្តុះបណ្តាលសាកល្បង ស្តីពីការសរសេរសំណើគម្រោងខ្នាតតូចផងដែរ ដល់ក្រុមប្រឹក្សាឃុំសង្កាត់ | នៅខេត្តស្វាយរៀង អ្នកចូលរួមសរុប ៣២រូប។ |

*(ប្រភព៖ របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំឆ្នាំ២០១០ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)*

**តារាងទី៥៖ របាយការណ៍ស្តីពីការអភិវឌ្ឍសមត្ថភាពរបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានឆ្នាំ២០១២**[72]

| **ឆ្នាំ២០១២** | |
|---|---|
| **សកម្មភាព** | **ក្រុមគោលដៅ** |
| បានបើកវគ្គបណ្តុះបណ្តាលស្តីពីពលកម្មកុមារ និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់ គាំទ្រដោយអនុកម្មវិធីទី២ នៃផ.អ.៣ | មន្ត្រីនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ព្រមទាំងមន្ត្រីមកពីខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តកណ្តាល ខេត្តកំពត ខេត្តកែប ខេត្តកោះកុង និងខេត្តព្រះសីហនុ ដែលមានអ្នកចូលរួម៦៥នាក់(ស្រីចំនួន ១៦នាក់)។ |
| បានរៀបចំបណ្តុះបណ្តាលតម្រង់ទិសស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់តាម | នៅខេត្តបាត់ដំបង និងខេត្តកំពង់ចាមដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទើបជាប់ឆ្នោត ដែលពីមុនមកពុំ |

[72] យិន ម៉ាលីណា, *របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានប្រចាំឆ្នាំ២០១២,* លេខ០៨១ របក/រម (ភ្នំពេញ៖ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, មីនា ២០១៣), ៣។

| | |
|---|---|
| បែបវិមជ្ឈការ | ដែលធ្លាប់ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ (ខេត្តកំពង់ចាមមានអ្នកចូលរួមចំនួន៧៩នាក់ និងខេត្តបាត់ដំបងចំនួន១២២នាក់)។ |
| បានរៀបចំវគ្គបណ្តុះបណ្តាលរៀបចំដោយគម្រោងសាកល្បងលើកកម្ពស់ការថែទាំ និងអភិវឌ្ឍកុមារតូច ដល់ជំនួយការឃុំទទួលបន្ទុកអភិវឌ្ឍន៍កុមារតូចនៅតាមភូមិក្នុងឃុំ សង្កាត់ | នៅខេត្តមណ្ឌលគិរី ដែលមានសិក្ខាកាមចូលរួមចំនួន១១នាក់ និងខេត្តស្វាយរៀង ដែលសិក្ខាកាមចំនួន៥៥នាក់។ |
| បានគាំទ្រក្រុមប្រឹក្សា ដើម្បីជួយពួកគាត់ឱ្យបំពេញតួនាទីបានល្អជាងមុន ដើម្បីការពារកុមារងាយរងគ្រោះចំនួន១,០៥៩នាក់(ក្មេងស្រីចំនួន ៥៤៩នាក់)។ | ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន២៧ នៅក្នុងរាជធានី ខេត្តចំនួន០៧ (រាជធានីភ្នំពេញ ខេត្តបាត់ដំបង កំពង់ស្ពឺ ឧត្តរមានជ័យ ព្រៃវែង សៀមរាប ស្ទឹងត្រែង និងខេត្តស្វាយរៀង |

***(ប្រភព៖ របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានប្រចាំឆ្នាំ២០១២)***

ក្រៅពីនេះនៅខេត្តសៀមរាប បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌ ដល់គ្រូឧទ្ទេសថ្នាក់រាជធានី ខេត្ត ដែលមានអ្នកចូលរួមចំនួនសរុប ៨២ នាក់(ស្ត្រីចំនួន២០នាក់)។ ក្រោយពីវគ្គបណ្តុះបណ្តាលនេះបញ្ចប់ គ្រូឧទ្ទេសរាជធានី ខេត្ត ត្រូវរៀបចំនូវការបណ្តុះបណ្តាលបន្តដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីសេវាសង្គមនៅ រាជធានី ខេត្ត របស់ខ្លួន។[73] ដូចនេះឃើញថាការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ បានកំពុងតែមានការរីកចម្រើនគួរឱ្យកត់សម្គាល់។

## ៣.៦. ភាពក្រីក្រ

រាជរដ្ឋាភិបាលកម្ពុជា កន្លងមកបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ធ្វើឱ្យប្រជាជនរស់នៅមានជីវភាពធូរធារ។ ការធ្វើកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់របស់រាជរដ្ឋាភិបាលក៏មានបំណងសំខាន់ជម្រុញ ដល់ការផ្តល់នូវការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រជាជន នៅតាមមូលដ្ឋានរបស់ឃុំ សង្កាត់នីមួយៗផងដែរ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាល ចង់សម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ

[73] នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, *វគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌*(សៀមរាប៖ ០១ វិច្ឆិកា ២០១២), http://gda-interior.gov.kh/index.php?option=com_content&view=article&id=110%3Aunicef-traning-at-siem-reap&catid=1%3Ageneral&Itemid=92&lang=kh(ថតចម្លងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៦)។

ក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានមុនឆ្នាំ២០១៥។ជាក់ស្តែង នៅឆ្នាំ២០១២ អត្រានៃភាពក្រីក្រ របស់កម្ពុជា មានត្រឹមតែ ១៨,៨៩ភាគរយប៉ុណ្ណោះ បើធៀបទៅនឹងឆ្នាំ២០០៤ មាន ៥៣,២ភាគរយ។[74] ក្នុងនោះគឺរាជធានីភ្នំពេញ គឺមានចំនួន ១៦,២៥% និងនៅតាមតំបន់ជនបទ គឺមានចំនួន ១៩,៩៨%។

ដោយឡែក ក្នុងដំណើរទស្សនកិច្ចលើកទី១ មកកាន់ប្រទេសកម្ពុជា របស់លោក Axel Van Trotsenburg អនុប្រធានធនាគារពិភពលោក (WB) ទទួលបន្ទុកតំបន់អាស៊ីខាងកើត និងប៉ាស៊ីហ្វិក បានធ្វើការវាយតម្លៃពីការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា។ លោកបានមានប្រសាសន៍ថា "សេដ្ឋកិច្ចរបស់កម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស និងកំពុងបន្តរីកចម្រើនថែមទៀត ទោះបីជាសេដ្ឋកិច្ចក្នុងពិភពលោកស្ថិតក្នុងស្ថានភាពស្មុគស្មាញក៏ដោយ លើសពីនេះទៅទៀតអត្រាភាពក្រីក្ររបស់ប្រទេសកម្ពុជា ក៏មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់ផងដែរ"[75]។ ជាពិសេសនៅឆ្នាំ ២០១៤ កម្ពុជាទទួលបានចំណាត់ថ្នាក់ ជាប្រទេសជោគជ័យទី៤ លើពិភពលោក ក្នុងការកាត់បន្ថយភាពក្រីក្រ។ កម្ពុជា ទទួលបានផលិតផលសរុបក្នុងស្រុក សម្រាប់ប្រជាជនម្នាក់ បានត្រឹមតែ២៥៣ដុល្លារអាមេរិក នៅឆ្នាំ១៩៩៨ប៉ុណ្ណោះ តែមកដល់ឆ្នាំ២០១៥ កម្ពុជាអាចទទួលបានផលិតផលសរុបក្នុងស្រុករហូតទៅដល់ ១២២៥ដុល្លារអាមេរិក។[76] អត្រាភាពក្រីក្រនៅកម្ពុជា ត្រូវបានកាត់បន្ថយពី ៥៣,២ភាគរយ នៅឆ្នាំ២០០៤ មកត្រឹម ១៣,៥ភាគរយ នៅឆ្នាំ២០១៤ ដែលនេះជាជោគជ័យល្អបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា។[77]

បន្ថែមពីនេះ អត្រាភាពក្រីក្រក្នុងប្រទេស ដែលត្រូវបានរៀបចំដោយក្រុមការងារវិមជ្ឈការ វិសហមជ្ឈការ និងសិទ្ធិកុមារក្រសួងផែនការបានបង្ហាញពីអត្រានៃភាពក្រីក្រតាមបណ្តាឃុំ សង្កាត់ ក្រុងស្រុក ខណ្ឌ និងរាជធានី ខេត្ត នៅក្នុងតារាងខាងក្រោមនេះ៖

---

[74] The Ministry of Planning, *Poverty Estimate in 2012 in Cambodia*, http://www.mop.gov.kh/Projects/tabid/148/Default.aspx(ថតចម្លងថ្ងៃទី១៦ មិថុនា ២០១៦)។

[75] Sinaenglish, *World Bank vice president hails Cambodia's growth, poverty reduction*, 2015-11-02, http://english.sina.com/2015/1102/861186.html(ថតចម្លងថ្ងៃទី១៦ ខែ០៦ ឆ្នាំ២០១៦)។

[76] ពាណិជ្ជកម្មកម្ពុជា. ២០១៥. *ធនាគារពិភពលោក៖កំណើនសេដ្ឋកិច្ចកម្ពុជានៅល្អប្រសើរខណៈអត្រាភាពក្រីក្រធ្លាក់ចុះយ៉ាងលឿន.* ៣ វិច្ឆិកា. http://business-cambodia.com/ធនាគារពិភពលោក៖-កំណើនសេដ្ឋ/(ថតចម្លងថ្ងៃទី១៦ ខែ០៦ ឆ្នាំ ២០១៦)។

[77] ដដែល។

## តារាងទី៦៖ អត្រាភាពក្រីក្រតាមបណ្តាខេត្ត រាជធានីឆ្នាំ២០១៥[78]

| ល.រ | ខេត្ត រាជធានី | ចំនួនក្រុង ស្រុកខណ្ឌ | ចំនួនឃុំ សង្កាត់ | ចំនួនគ្រួសារ | ចំនួន ប្រជាជន | អត្រាភាព ក្រីក្រ(%) |
|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ៩ | ៦៥ | ១៧៨,៦១០ | ៧៩២,៦៧១ | ២១.១៩ |
| ២ | បាត់ដំបង | ១៤ | ១០២ | ២៤៦,៣៧៦ | ១,១៧៣,៤១៤ | ២៣.១៦ |
| ៣ | កំពង់ចាម | ១០ | ១០៩ | ២៤៦,៥៩៥ | ១,១៣៤,០២៦ | ១៧.៣២ |
| ៤ | កំពង់ឆ្នាំង | ៨ | ៦៩ | ១២០,០៦១ | ៥៣៧,៥១៣ | ២២.៧៣ |
| ៥ | កំពង់ស្ពឺ | ៨ | ៨៧ | ១៧០,៧៧០ | ៨៣៧,៧៣៥ | ២៣.១៣ |
| ៦ | កំពង់ធំ | ៨ | ៨១ | ១៥៨,១៧៨ | ៧៥៦,៦០៥ | ២៤.៤៧ |
| ៧ | កំពត | ៨ | ៩៣ | ១៤៣,០៨១ | ៦៦០,១០៨ | ១៥.៦៨ |
| ៨ | កណ្តាល | ១១ | ១២៧ | ២៥៤,២២៨ | ១,២១៩,៩៩១ | ១៤.៧៨ |
| ៩ | កោះកុង | ៧ | ២៩ | ២៧,៤៣២ | ១២៩,០៩០ | ១៤.៥៧ |
| ១០ | ក្រចេះ | ៦ | ៤៦ | ៧៨,៤៩០ | ៣៧២,០១៧ | ២៦.៩០ |
| ១១ | មណ្ឌលគីរី | ៥ | ២១ | ១៦,៥៩៣ | ៧៦,១៨៤ | ២៣.៥៨ |
| ១២ | ភ្នំពេញ | ១២ | ៩៦ | ២៧៨,៧៥២ | ១,៤៩៥,៩០២ | ១.០៨ |
| ១៣ | ព្រះវិហារ | ៨ | ៥១ | ៥២,៤៩២ | ២២៨,០៩០ | ២៨.៦៧ |
| ១៤ | ព្រៃវែង | ១៣ | ១១៦ | ២៦៩,៤៦១ | ១,១៩៩,១៤៦ | ១៧.៦៣ |
| ១៥ | ពោធិ៍សាត់ | ៦ | ៤៩ | ១០៤,៦៩៥ | ៤៧៣,៣២២ | ២៣.១៦ |
| ១៦ | រតនគីរី | ៩ | ៥០ | ៤០,៤៦១ | ១៨១,០៩៣ | ២៤.៤៦ |
| ១៧ | សៀមរាប | ១២ | ១០០ | ២០៦,៣៨៥ | ១,០៤២,២៨៦ | ២៣.២៩ |
| ១៨ | ព្រះសីហនុ | ៤ | ២៧ | ៤៤,១៦៤ | ២០៩,៨៤១ | ១៤.០២ |
| ១៩ | ស្ទឹងត្រែង | ៥ | ៣៤ | ២៩,៣១១ | ១៣៥,៦៥១ | ២៧.៣៧ |
| ២០ | ស្វាយរៀង | ៨ | ៨០ | ១៣៨,៤១១ | ៦១១,៥១១ | ១៥.០៦ |

[78] ប្រធានក្រុមការងារវិមជ្ឈការ វិសហមជ្ឈការនិងសិទ្ធិកុមារក្រសួងផែនការ, *អត្រាភាពក្រីក្រតាមបណ្តាឃុំសង្កាត់ក្រុងស្រុកខណ្ឌ និងខេត្តរាជធានី* (ភ្នំពេញ៖ ក្រសួងផែនការ, មេសា ២០១៥), ៧។

| | | | | | | |
|---|---|---|---|---|---|---|
| ២១ | តាកែវ | ១០ | ១០០ | ២១០,១៥០ | ៩៩៩,៨៩២ | ១៦.៣៨ |
| ២២ | ឧត្តរមានជ័យ | ៥ | ២៤ | ៥៣,៩១៧ | ២៣០,២៨០ | ២៨.៨៣ |
| ២៣ | កែប | ២ | ៥ | ៨,៧៣៦ | ៣៩,៨៨៥ | ១៤.៣៧ |
| ២៤ | ប៉ៃលិន | ២ | ៨ | ១៥,៥៦៥ | ៦៩,១៥៩ | ២២.៦៨ |
| ២៥ | ត្បូងឃ្មុំ | ៧ | ៦៤ | ១៨៣,៧០៣ | ៨៤៤,៣១៤ | ១៣.៩០ |
| សរុប | | ១៩៧ | ១,៦៣៣ | ៣,២៧៦,៦១៧ | ១៥,៣៩៤,២៧៦ | ១៨.៧៦ |

*(ប្រភព៖ អត្រាភាពក្រីក្រតាមបណ្តាឃុំសង្កាត់ក្រុងស្រុកខណ្ឌ និងខេត្តរាជធានីឆ្នាំ២០១៥)*

អត្រានៃភាពក្រីក្ររបស់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ត្រូវបានកាត់បន្ថយច្រើន ជាពិសេសគឺនៅរាជធានីភ្នំពេញ ដែលអត្រានៃភាពក្រីក្ររបស់ប្រជាជនមានត្រឹមតែ ១.០៨% ប៉ុណ្ណោះ។ តែយ៉ាងណា នៅតាមបណ្តាខេត្តនីមួយៗ អត្រានៃភាពក្រីក្រនេះ គឺនៅមានកម្រិតខ្ពស់នៅឡើយ ដែលទាមទារនូវការបន្តការអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើឱ្យសេដ្ឋកិច្ចគ្រួសារនីមួយៗមានការកើនទន្ទឹមនិងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ។

## ២.៧. ទិមជ្ឈការហិរញ្ញវត្ថុ

មូលនិធិឃុំ សង្កាត់ គឺជាសមាសភាគដ៏សំខាន់មួយនៃកិច្ចដំណើរការកំណែទម្រង់តាមបែបប្រជាធិបតេយ្យ ដោយសារថវិកាមួយចំនួនឃុំ សង្កាត់គឺជាអ្នករកបានដោយខ្លួនផ្ទាល់ និងមួយចំនួនទៀតគឺត្រូវបានវិភាជន៍ពីថវិការដ្ឋ និងអាជ្ញាធរថ្នាក់លើ ព្រមជាមួយនិងជំនួយនានាបន្ថែមទៀត។ មូលនិធិឃុំ សង្កាត់គឺជាមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ ដែលមូលនិធិនេះទទួលបាននូវកាចូលរួមធនធានប្រចាំឆ្នាំពីថវិការដ្ឋក្នុងកម្រិតអត្រា ២,៨០% នៃចំណូលចរន្តថវិការដ្ឋ សម្រាប់ឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨។[79] មូលនិធិឃុំ សង្កាត់ត្រូវបានបែងចែកជាពីរសមាសភាគ គឺសមាសភាគរដ្ឋបាលទូទៅ និងសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។[80]

ការផ្ទេរមូលនិធិឃុំ សង្កាត់ចាប់ពីឆ្នាំ២០០២ រហូតមកដល់បច្ចុប្បន្ន គឺមានភាពបត់បែនខ្លះៗទៅតាមស្ថានភាពប្រែប្រួល និងការរីកចម្រើនរបស់សេដ្ឋកិច្ចសង្គមនៃបណ្តាឆ្នាំនីមួយៗ។ ខាងក្រោមជាតារាងបង្ហាញពីមូលនិធិឃុំ សង្កាត់ ចាប់ពីឆ្នាំ២០០២ រហូតដល់បច្ចុប្បន្ន។

[79] អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់, លេខ ៩៦៥ អនក្រ.បក, ១១ កក្កដា ២០១៣, មាត្រា១។
[80] ដូច៨៨, ៧០។

### តារាងទី៧៖ មូលនិធិឃុំ សង្កាត់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៩[81]

| ឆ្នាំ | ថវិកា |
|---|---|
| ឆ្នាំ២០០២ | **៣០.៦៨៧.៩១០.០០០រៀល** |
| ឆ្នាំ២០០៣ | **៥១.៨១៩.៥២៨.០០០រៀល** |
| ឆ្នាំ២០០៤ | **៥៨.០០០.០០០.០០០រៀល** |
| ឆ្នាំ២០០៥ | **៦៦.១០០.០០០.០០០រៀល** |
| ឆ្នាំ២០០៦ | **៧៧.៨១៤.០០០.០០០រៀល** |
| ឆ្នាំ២០០៧ | **៨៩.៥៥០.០០០.០០០រៀល** |
| ឆ្នាំ២០០៨ | **៩៣.០២៥.០០០.០០០រៀល** |
| ឆ្នាំ២០០៩ | **១១៣.៣៥០.០០០.០០០រៀល** |

*(ប្រភព៖ ចំណូលមូលនិធិឃុំ សង្កាត់តាមរយៈគេហទំព័ររបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)*

ខាងក្រោមនេះជាទិន្នន័យ ដែលបង្ហាញពីមូលនិធិឃុំ សង្កាត់ចាប់ពីឆ្នាំ២០១០មក៖

### តារាងទី៨៖ ការផ្ទេរមូលនិធិឃុំ សង្កាត់ឆ្នាំ២០១០[82]

| **មូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០១០** | | |
|---|---|---|
| **មូលនិធិបានមកពីរដ្ឋ** | | **ផ្សេងៗ** |
| ជំហានទី១ | ៦៩.៨២៩.៧៨០.០០០រៀល | សម្រាប់ឃុំ សង្កាត់ទូទាំងប្រទេស (ផ្នែកអភិវឌ្ឍន៍ + ផ្នែករដ្ឋបាល) |
| ជំហានទី២ | ៤៩.០២៩.៤២០.០០០រៀល | |
| ជំហានទី៣ | ២៩.៧១៤.៨០០.០០០រៀល | |
| **សរុប** | **១៤៨.៥៧៤.០០០.០០០រៀល** | |
| **មូលនិធិបានមកពី UNDP/PSDD** | | **ផ្សេងៗ** |
| | ៤.៩៩៨.៦៣១.០០០រៀល | សម្រាប់ឃុំ សង្កាត់ចំនួន ១១៩៩ |
| | ១.៦៦៧.៦០០.០០០រៀល | សម្រាប់ឃុំ សង្កាត់ក្រីក្រចំនួន ២០០ |
| **សរុប** | **៦.៦៦៦.២៣១.០០០រៀល** | |

*(ប្រភព៖ របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំឆ្នាំ២០១០ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)*

---

[81] នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, *ចំណូលមូលនិធិឃុំ សង្កាត់*, http://gda-interior.gov.kh/index.php?option=com_content &view=article&id=86%3A2013-12-17-03-57-05&catid=25%3Aministry&Itemid=66&lang=kh (ថតចម្លងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦)។

[82] ដូច៧១, ៦។

**តារាងទី៩៖ ការផ្ទេរមូលនិធិឃុំ សង្កាត់ឆ្នាំ២០១១**[83]

| មូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០១១ | | |
|---|---|---|
| **មូលនិធិបានមកពីរដ្ឋ** | | **ផ្សេងៗ** |
| ជំហានទី១ | ៥៨.៩៧៨.០០០.០០០រៀល | សម្រាប់ឃុំ សង្កាត់ទូទាំងប្រទេស (ផ្នែកអភិវឌ្ឍន៍ + ផ្នែករដ្ឋបាល) |
| ជំហានទី២ | ៤៩.៨១៤.០០០.០០០រៀល | |
| ជំហានទី៣ | ៥០.៨៧៥.៦៧០.៥២០រៀល | |
| **សរុប** | **១៥៩.២៦៧.៦៧០.៥២០រៀល** | |
| **មូលនិធិគាំទ្រដោយ UNICEF** | | **ផ្សេងៗ** |
| | ២.៣៩២.៤៦៨.០៩៦រៀល | រាជធានី ខេត្តគោលដៅចំនួន១៥ |
| **សរុប** | **២.៣៩២.៤៦៨.០៩៦រៀល** | |

*(ប្រភព៖ របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំឆ្នាំ២០១១ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)*

**តារាងទី១០៖ ការផ្ទេរមូលនិធិឃុំ សង្កាត់ឆ្នាំ២០១២**[84]

| មូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០១២ | | |
|---|---|---|
| **មូលនិធិបានមកពីរដ្ឋ** | | **ផ្សេងៗ** |
| ជំហានទី១ | **៩៥.៣១៥.៥០៩.០០០រៀល** | សម្រាប់ឃុំ សង្កាត់ទូទាំងប្រទេស (ផ្នែកអភិវឌ្ឍន៍ + ផ្នែករដ្ឋបាល) |
| ជំហានទី២ | **៨០.០៦៨.៨៧៨.០០០រៀល** | |
| ជំហានទី៣ | **១៣.២៣៦.៩៨៧.៨៤៦រៀល** | |
| ជំហានទី៤ | **១៣.១៨៨.២៥០.០០១រៀល** | |
| ឥណទានបន្ថែម | **១៩.៨៤៣.៧០២.៣៩៧រៀល** | សម្រាប់ផ្នែកអភិវឌ្ឍន៍ |
| **សរុប** | **១៣១.២៤៩.៣២២.៨៤៨រៀល** | |
| **មូលនិធិគាំទ្រដោយ UNICEF** | | **ផ្សេងៗ** |
| | ២៩៧.៧៩៦.៧៩៧រៀល | ឃុំ សង្កាត់នៅខេត្តតាកែវ សម្រាប់គាំទ្រកម្មវិធីប្រែប្រួលអាកាសធាតុ |
| **សរុប** | **២៩៧.៧៩៦.៧៩៧រៀល** | |

*(ប្រភព៖ របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានប្រចាំឆ្នាំ២០១២)*

[83] យិន ម៉ាលីណា, *របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំឆ្នាំ២០១១ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន*, លេខ០៥៧ របក/រ.ម (ភ្នំពេញ៖ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, ២៦ ធ្នូ ២០១១), ៥។

[84] ដូច៧២, ៨។

**សម្គាល់៖** ក្នុងឆ្នាំ២០១២ ដោយមានការស្នើសុំពីឃុំ សង្កាត់ នាយកដ្ឋានរដ្ឋបាលមូលដ្ឋានបានរៀបចំផ្ទេរមូលនិធិបន្ថែមលើផ្នែកអភិវឌ្ឍន៍ចំនួន០៥លើក សរុបចំនួន **១៩.៤៨៣.៧០២.៣៩៧រៀល**(ស្មើនឹង ៣៩,៣០ភាគរយ ទៅឱ្យឃុំ សង្កាត់មួយចំនួននៅខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ធំ ខេត្តកំពត ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តស្វាយរៀង ខេត្តពោធិ៍សាត់ ខេត្តកោះកុង ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តសៀមរាប និងខេត្តបាត់ដំបង។

**តារាងទី១១៖ ការផ្ទេរមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤**[85]

| មូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០១៤ | | |
|---|---|---|
| **មូលនិធិបានមកពីរដ្ឋ** | | **ផ្សេងៗ** |
| ២៣៧.២៦៦.០០០.០០០រៀល | | សម្រាប់ឃុំ សង្កាត់ទូទាំងប្រទេស (ផ្នែកអភិវឌ្ឍន៍ + ផ្នែករដ្ឋបាល) |
| **សរុប** | **២៣៧.២៦៦.០០០.០០០រៀល** | |

*(ប្រភព៖ ព្រឹត្តិបត្រលើកទី៩គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឆ្នាំ២០១៥)*

**តារាងទី១២៖ ថវិការដ្ឋបាលឃុំ សង្កាត់សម្រាប់ឆ្នាំ២០១៥**[86]

| មូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០១៥ | | | |
|---|---|---|---|
| ចំណូល(លានរៀល) | | ចំណាយ(លានរៀល) | |
| ឧបត្ថម្ភពីថវិកាជាតិ | **២៧១.៩៥៤** | ចំណាយសរុប | **២៧១.៩៥៤** |
| សង្កាត់ចំណុះរាជធានី | **១៨ ០៧៧,៥៣** | សង្កាត់ចំណុះរាជធានី | **១៨ ០៧៧,៥៣** |
| សង្កាត់ចំណុះក្រុង | **២១ ៣២១,៩៧** | សង្កាត់ចំណុះក្រុង | **២១ ៣២១,៩៧** |
| ឃុំ | **២៣២ ៥៥៤,៥** | ឃុំ | **២៣២ ៥៥៤,៥** |

*(ប្រភព៖ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥)*

[85] ដូច៩៨, ៧០។

[86] ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥, លេខនស/រកម/១២១៤/០២៦, ១៨ ធ្នូ ២០១៤, មាត្រា១៥។

## តារាងទី១៣៖ ថវិការដ្ឋបាលឃុំ សង្កាត់សម្រាប់ឆ្នាំ២០១៦[87]

| មូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០១៦ | | | |
|---|---|---|---|
| ចំណូល(លានរៀល) | | ចំណាយ(លានរៀល) | |
| ឧបត្ថម្ភពីថវិកាជាតិ | **៣០៨ ៤១០** | ចំណាយសរុប | **៣០៨ ៤១០** |
| សង្កាត់ចំណុះរាជធានី | **២០ ៦១១,២** | សង្កាត់ចំណុះរាជធានី | **២០ ៦១១,២** |
| សង្កាត់ចំណុះក្រុង | **២៤ ៣៧៦,៤** | សង្កាត់ចំណុះក្រុង | **២៤ ៣៧៦,៤** |
| ឃុំ | **២៦៣ ៤២២,៦** | ឃុំ | **២៦៣ ៤២២,៦** |

*(ប្រភព៖ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦)*

## តារាងទី១៤៖ មូលនិធិឃុំ សង្កាត់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០១៦

| មូលនិធិឃុំ សង្កាត់ទទួលបានពីរដ្ឋ | |
|---|---|
| **ឆ្នាំ** | **ថវិកា** |
| ឆ្នាំ២០០២ | **៣០.៦៨៧.៩១០.០០០រៀល** |
| ឆ្នាំ២០០៣ | **៥១.៤១៩.៥២៨.០០០រៀល** |
| ឆ្នាំ២០០៤ | **៥៨.០០០.០០០.០០០រៀល** |
| ឆ្នាំ២០០៥ | **៦៦.១០០.០០០.០០០រៀល** |
| ឆ្នាំ២០០៦ | **៧៧.៨១៤.០០០.០០០រៀល** |
| ឆ្នាំ២០០៧ | **៨៩.៥៥០.០០០.០០០រៀល** |
| ឆ្នាំ២០០៨ | **៩៣.០២៥.០០០.០០០រៀល** |
| ឆ្នាំ២០០៩ | **១១៣.៣៤០.០០០.០០០រៀល** |
| ឆ្នាំ២០១០ | **១៤៨.៥៧៤.០០០.០០០រៀល** |
| ឆ្នាំ២០១១ | **១៥៩.២៦៧.៦៧០.៥២០រៀល** |
| ឆ្នាំ២០១២ | **១៣១.២៤៩.៣២២.៨៤៤រៀល** |
| ឆ្នាំ២០១៣ | **(ទិន្នន័យមិនអាចរកបាន)** |
| ឆ្នាំ២០១៤ | **២៣៧.២៦៦.០០០.០០០រៀល** |
| ឆ្នាំ២០១៥ | **២៧១.៩៥៤.០០០.០០០រៀល** |
| ឆ្នាំ២០១៦ | **៣០៨ ៤១០.០០០.០០០រៀល** |

[87] ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦, លេខនស/រកម/១២១៥/០១៦, ១៧ ធ្នូ ២០១៥, មាត្រា១៤។

ថវិកាដែលរដ្ឋបានវិភាជន៍ទៅឱ្យរដ្ឋបាលឃុំ សង្កាត់ពីមួយឆ្នាំ ទៅមួយឆ្នាំ មានការកើនឡើងរហូត ដោយឡែកមានតែថវិកាសម្រាប់ឆ្នាំ២០១២ទេ ដែលមានការធ្លាក់ចុះ និងថវិកាសម្រាប់ឆ្នាំ ២០១៣ មិនអាចរកទិន្នន័យមកបង្ហាញបាន។ តែយ៉ាងណាឃើញថា កំណើននៃមូលនិធិឃុំ សង្កាត់ មានន័យថាសេដ្ឋកិច្ចនៃប្រទេសកម្ពុជាមានការអភិវឌ្ឍជារៀងរាល់ឆ្នាំ។

# ជំពូកទី៤
# ការវិភាគទិន្នន័យ និងរបកគំហើញ

## ៤.១. វិភាគទិន្នន័យដែលរកបាន

### ៤.១.១. ភាពជាតំណាង

វិមជ្ឈការឃុំ សង្កាត់ បានផ្តល់ឱកាសខាងនយោបាយដល់គណបក្សនយោបាយ សម្រាប់ការកែលម្អភាពជាតំណាង នៅកម្រិតមូលដ្ឋាន និងក្រុមប្រជាពលរដ្ឋមានភាពទន់ខ្សោយ រួមទាំងស្ត្រី និងជនជាតិដើមភាគតិច។ ភាពជាតំណាង បានឆ្លុះបញ្ចាំងនូវការយល់ដឹងពីគោលការណ៍ប្រជាធិបតេយ្យដែលមានកំណត់ក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ហើយភាពជាតំណាង បានបើកឱកាសឱ្យប្រជាពលរដ្ឋអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនតាមរយៈតំណាង។

ថ្វីបើវាមានភាពល្អប្រសើរយ៉ាងនេះក្តី ក៏នៅតែមានបញ្ហា ដែលជៀសមិនផុតដែរ។ ភាពជាតំណាងបានផ្តល់ប្រយោជន៍ដល់គណបក្សកាន់អំណាចច្រើនជាង គណបក្សប្រឆាំងដែលទំនងជាមិនអាចពង្រឹងវត្តមានរបស់ខ្លួននៅតាមមូលដ្ឋានទេ ដោយសារតែធនធាន និងកម្លាំងខាងនយោបាយរបស់ខ្លួននៅមានកម្រិត។ ប្រធានក្រុមប្រឹក្សាគឺជាមេឃុំ ចៅសង្កាត់ ដែលបេក្ខភាពដែលមានឈ្មោះលើគេនៃគណបក្សដែលឈ្នះឆ្នោត។ ចឹងហើយឥទ្ធិពលក្នុងការដឹកឃុំ សង្កាត់ក៏ទំនោរទៅខាងគណបក្សរបស់ខ្លួនច្រើនជាងដែរ។ ឯគណបក្សប្រឆាំង ប្រហែលជាគ្មានឱកាសក្នុងការកសាងនូវស្នាដៃ ឱ្យប្រជាពលរដ្ឋបានឃើញនោះទេ។ បច្ចុប្បន្នឃើញថា ភាពជាតំណាងនៃស្ត្រីមានការកើនឡើង និងការយកចិត្តទុកដាក់ពីគ្រប់មជ្ឈដ្ឋាន តែកំណើនភាពជាតំណាងនៃស្ត្រីភេទនេះមិនមែនបានន័យថាស្ត្រីមានអំណាចខាងនយោបាយច្រើនជាងមុននោះទេ ដោយសារមានឧបសគ្គរាំងស្ទះខាងសង្គម សេដ្ឋកិច្ច វប្បធម៌ និងនយោបាយ។ ឧបសគ្គទាំងនោះមានដូចជា បន្ទុកគ្រួសារ ការអប់រំមានកម្រិត កង្វះភាពក្លាហានក្នុងការការពារគំនិតខ្លួន និងកង្វះជំនួយគាំទ្រផ្នែកហិរញ្ញវត្ថុ។ ដូច្នេះហើយគេគ្រាន់តែជួយសម្រួលដល់វត្តមានរបស់ស្ត្រីឱ្យច្រើនជាងមុន ក្នុងការងារសាធារណៈក៏ដូចជាការងារក្នុងសង្គម។

### ៤.១.២. មុខងាររបស់ឃុំ សង្កាត់

ចាប់តាំងពីការធ្វើកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ អស់រយៈពេលជាង ១០ ឆ្នាំមកនេះ ឃុំ សង្កាត់ ត្រូវរ៉ាប់រងនូវការងារ ដែលមានលក្ខណៈពហុវិស័យ។ ឃុំ សង្កាត់ ត្រូវធ្វើការងារជាច្រើន ដែលពាក់ព័ន្ធនឹងមហាផ្ទៃផង ការងារដែលពាក់ព័ន្ធនឹងនគរូបនីយកម្មផង ការងារដែលពាក់ព័ន្ធនឹង

វិស័យអប់រំ និងសុខុមាលភាពផង។ ប៉ុន្តែការងារទាំងនេះ ភាគច្រើនជាការងារ ដែលមិនសូវពិបាក ប៉ុន្មានទេ គឺវាគ្រាន់តែជាការបញ្ជាក់លិខិតស្នាមដែលពាក់ព័ន្ធប៉ុណ្ណោះ។

ទោះជាយ៉ាងណាក៏ ការផ្ទេរមុខងារ ទាំងធនធានថវិកាពីថ្នាក់ជាតិទៅឱ្យឃុំ សង្កាត់ គឺស្ថិតនៅក្រោមចំណុះរបស់សាមីក្រសួងនីមួយៗ ដែលជាអ្នកអនុវត្តដដែលទេ គ្រាន់តែអាជ្ញាធរដែនដីមានតួនាទីជាអ្នកគ្រប់គ្រង និងសម្របសម្រួលផ្នែករដ្ឋបាលដើម្បីឱ្យដំណើរការអនុវត្តផែនការសកម្មភាពតាមបែបលទ្ធិប្រជាធិបតេយ្យតាមរយៈវិមជ្ឈការកាន់តែប្រសើរឡើងប៉ុណ្ណោះ។

ឧទាហរណ៍៖ ប្រធានក្រុមប្រឹក្សាឃុំ ក៏ជាប្រធានគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពណាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ឃុំដែរ តែមេឃុំមិនមែនគាំទ្រផ្នែកបច្ចេកទេសសុខាភិបាលដល់មណ្ឌលសុខភាពបាននោះទេ គឺគ្រាន់តែសម្រួលដល់ដំណើរការសកម្មភាពរបស់មណ្ឌលសុខភាពនោះប៉ុណ្ណោះ។ ហើយគាត់អាចជួយក្នុងកិច្ចសហប្រតិបត្តិការមណ្ឌលសុខភាព ជួយផ្សព្វផ្សាយអំពីជំងឺឆ្លងការណែនាំប្រជាពលរដ្ឋឱ្យមកទទួលសេវានៅមណ្ឌលសុខភាព ឬក៏ស្វែងរកដំណោះស្រាយបញ្ហាវិវាទរវាងអ្នកផ្តល់សេវាសុខាភិបាល និងប្រជាពលរដ្ឋដែលមកទទួលសេវា ជាដើម ធ្វើយ៉ាងណាដើម្បីឱ្យឃុំទាំងមូលមានការអភិវឌ្ឍ។

ដោយឡែក ក្រឡេកមើលក្រសួង ស្ថាប័នដទៃ មិនទាន់មានសកម្មភាពផ្តល់នូវមុខងារ និងធនធានថវិកាទៅឱ្យថ្នាក់ឃុំ សង្កាត់នៅឡើយ។ ដូចជាការធ្វើលិខិតថ្កោលទោស ប្រជាពលរដ្ឋត្រូវនៅតាមបណ្តាខេត្ត ត្រូវធ្វើដំណើរមករាជធានីភ្នំពេញ ទើបអាចធ្វើបាននៅក្រសួងយុត្តិធម៌ ហើយបើការងារច្រើនទៀតនោះ ប្រជាពលរដ្ឋត្រូវចំណាយប្រាក់ លើការស្នាក់នៅបន្ថែមទៀត។ មួយវិញទៀតការធ្វើលិខិតបញ្ជាក់សុខភាព ប្រជាពលរដ្ឋ និងជាពិសេសកម្មករ កម្មការិនី ត្រូវមកធ្វើនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទើបបាន។ ដូច្នេះវាមិនបានផ្តល់ផលល្អសម្រាប់ប្រជាពលរដ្ឋទេ គឺមានតែធ្វើឱ្យប្រជាពលរដ្ឋមានការលំបាក ចំណាយប្រាក់ច្រើន និងខាតបង់ពេលវេលាច្រើន តែបើការងារទាំងនេះ អាចដំណើរការនៅថ្នាក់ឃុំ សង្កាត់បាន ច្បាស់ជាល្អប្រសើរជាពុំខាន។

### ៤.១.៣. ការអភិវឌ្ឍសមត្ថភាព

ការងារអភិវឌ្ឍសមត្ថភាពធនធានមនុស្ស គឺធ្វើឡើងដើម្បីបង្កើននូវប្រសិទ្ធភាពការងារ និងសមត្ថភាពយល់ដឹងអំពីតម្រូវការរបស់ប្រជាពលរដ្ឋ និងការឆ្លើយតបទៅតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ការងារថ្មីដែលត្រូវបានប្រគល់ឱ្យឃុំ សង្កាត់ ចាំបាច់ត្រូវតែវគ្គបណ្តុះបណ្តាលសមត្ថភាពរបស់អ្នកអនុវត្ត ទើបអាចដំណើរការការងារនោះបានល្អ ជាពិសេសការងារដែលគួរតែប្រើប្រាស់បច្ចេកវិទ្យាទំនើបៗឱ្យបានច្រើន។

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងធ្វើបទសម្ភាសន៍ ជាមួយនឹងថ្នាក់ដឹកនាំនៃរដ្ឋបាលសង្កាត់ ការអភិវឌ្ឍធនធានមនុស្សនេះមានសកម្មភាពរីកចម្រើនច្រើន។ វគ្គបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ជាច្រើន ដែលកន្លងមកត្រូវបានរៀបចំឡើយដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន និងគាំទ្រដោយដៃគូរអភិវឌ្ឍន៍នានា។ ម្យ៉ាងទៀតការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាក្រុមការងារទាំងមូលនៅឃុំ សង្កាត់ ក៏តែងតែទទួលបាននូវវគ្គបណ្តុះបណ្តាលដែលធ្វើឡើងដោយក្រុង ស្រុក ខណ្ឌ ដែលគាំទ្រសម្រាប់បង្កើនសមត្ថភាពការងារ និងប្រសិទ្ធភាពការងារផងដែរ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលដែលបានសិក្សាកន្លងមកនេះ ឃើញថាមានសកម្មភាពច្រើនគួរកត់សម្គាល់ តែជាតុពិតសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មិនទាន់មានសមត្ថភាពឆ្លើយតបគ្រប់ការងារទាំងអស់នោះបាន។ ជាក់ស្តែងពេលដែលចុះទៅសង្កាត់ទឹកល្អក់២ ដើម្បីធ្វើបទសម្ភាសន៍ជាមួយសមាជិកក្រុមប្រឹក្សាពីព័ត៌មានពាក់ព័ន្ធនឹងកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ គឺមានតែចៅសង្កាត់ប៉ុណ្ណោះ ទើបអាចឆ្លើយបាន។ ប៉ុន្តែដោយសារលោកចៅសង្កាត់ មានបញ្ហាសុខភាពមិនអាចមកបំពេញការងារបាន ទើបមិនអាចធ្វើការសម្ភាសន៍ជាមួយលោកបាន។ ចំណុចបញ្ជាក់ឱ្យឃើញថាសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សា មិនទាន់មានសមត្ថភាពគ្រប់គ្រាន់ទាំងអស់ទេ។ នេះគឺសង្កាត់ដែលនៅរាជធានីភ្នំពេញ ដែលសម្បូរទៅដោយអ្នកដែលមានចំណេះដឹងច្រើន ចុះបើឃុំដែលនៅតាមតំបន់ជនបទ ឬដាច់ស្រយាលវិញ តើសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំយ៉ាងម៉េចវិញទៅ?។

ដូច្នេះការអភិវឌ្ឍធនធានមនុស្សនៅក្នុងឃុំ សង្កាត់ ហាក់ដូចជាមិនទាន់ផ្តល់នូវលទ្ធផលល្អប្រសើរនៅឡើយទេ ដោយត្រូវការពេលវេលាច្រើន ដើម្បីបន្តការរៀបចំវគ្គបណ្តុះបណ្តាលសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេសឱ្យបានច្រើនកាន់តែល្អ។ ប៉ុន្តែក្នុងវគ្គបណ្តុះបណ្តាលសមត្ថភាពនីមួយៗ ក៏ត្រូវការសិក្ខាកាមដែលមានឆន្ទៈដើម្បីអភិវឌ្ឍសមត្ថភាពរបស់ខ្លួនផងដែរ។

### ៤.១.៤. គណនេយ្យភាព និងការឆ្លើយតប

ក្រោយបានអនុវត្តកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ច្រើនឆ្នាំមកនេះ គេអាចឃើញច្បាស់ពីការរីកចម្រើនខ្លះៗ នៅក្នុងគណនេយ្យភាព និងការឆ្លើយតបរបស់ក្រុមប្រឹក្សា ព្រោះតែប្រជាពលរដ្ឋគឺម្ចាស់សន្លឹកឆ្នោត ហើយធ្វើមិនល្អ នោះប្រជាពលរដ្ឋលែងបោះឆ្នោតគាំទ្រទៀត។ ក្រុមប្រឹក្សាមានទំនួលខុសត្រូវចំពោះប្រជាពលរដ្ឋ ហើយអនុវត្តនូវតួនាទី ឬអាណត្តិរបស់ខ្លួនដោយផ្អែកលើគោលការណ៍នៃគណនេយ្យភាព។

ចំណុចនេះបានធ្វើឱ្យប្រជាពលរដ្ឋ មានជំនឿចិត្តជាងមុន និងមានសកម្មភាពចូលរួមច្រើនក្នុងការងារសាធារណៈ។ ប្រជាពលរដ្ឋអាចត្រួតពិនិត្យការងាររបស់ក្រុមប្រឹក្សា និងធ្វើការវាយតម្លៃដោយដាក់ពិន្ទុទៅលើសកម្មភាពការងារទាំងនោះ។ ហេតុដូចនេះក្រុមប្រឹក្សា មិនអាចធ្វើការឱ្យតែរួចពីដៃ ឬមិនយកចិត្តទុកដាក់លើប្រសិទ្ធភាពការងារបានឡើយ។ ដូច្នេះការបម្រើការងាររបស់ក្រុមប្រឹក្សានីមួយៗត្រូវតែមានគណនេយ្យភាពរបស់ប្រជាពលរដ្ឋ ហើយក៏សម្រាប់ថ្នាក់លើខ្លួនផងដែរ។

ស្របតាមលទ្ធផលដែលបានបកស្រាយ ឃើញថាកំណើននៃការឆ្លើយតបរបស់ក្រុមប្រឹក្សាក៏មានការកើនឡើងដែរ។ តែទន្ទឹមនឹងការរីកចម្រើននូវគណនេយ្យភាព និងការឆ្លើយតបរបស់ក្រុមប្រឹក្សា ហាក់ដូចជាប្លែកបន្តិច។ ក្រុមប្រឹក្សាមានតួនាទីអភិវឌ្ឍមូលដ្ឋាន និងការរស់នៅប្រជាពលរដ្ឋតែការអភិវឌ្ឍត្រូវពឹងផ្អែកលើថវិការបស់ឃុំ សង្កាត់ ថវិកាពីរដ្ឋ និងដៃគូរអភិវឌ្ឍន៍។ យ៉ាងណាមិញថវិកាឃុំ សង្កាត់ក៏មិនមានកម្រិតដែរ។ ដើម្បីបង្កើនថវិការបស់ឃុំ សង្កាត់ ឃុំ សង្កាត់ខ្លួនឯងមិនមានលទ្ធភាពរកបានទេ ជាពិសេសឃុំ សង្កាត់ក្រីក្រ។ នៅចំពោះមុខកង្វះខាតនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពឹងផ្អែកទៅលើការសុំជំនួយគណបក្សនយោបាយ។ ដូច្នេះក្រុមប្រឹក្សា គឺមិនអាចផ្តាច់ចេញពីគោលនយោបាយរបស់បក្សបានឡើយ យ៉ាងណាក៏ត្រូវតែដើរតាមគោលនយោបាយរបស់បក្សដែរ។

**៤.១.៥. ហិរញ្ញវត្ថុ**

ពីមួយឆ្នាំ ទៅមួយឆ្នាំ ថវិការបស់ឃុំ សង្កាត់ មានការកើនឡើងច្រើន។ ការកើនឡើងនេះដោយសារតែការអភិវឌ្ឍនៃសេដ្ឋកិច្ចជាតិ បានធ្វើប្រជាពលរដ្ឋមានចំណូលច្រើន ដូច្នេះចំណូលរបស់ឃុំ សង្កាត់ ដែលបានមកពីការផ្តល់សេវានានាដល់ប្រជាពលរដ្ឋមានការកើនឡើង។ កំណើននៃថវិកាជាតិ ធ្វើឱ្យខ្ទង់ថវិការបស់ឃុំ សង្កាត់ក៏មានការកើនដែរ។ ម្យ៉ាងទៀតថវិកាដែលបានមកពីដៃគូរអភិវឌ្ឍន៍ សម្រាប់អភិវឌ្ឍ ឃុំ សង្កាត់ ក៏មានច្រើន។

កំណែទម្រង់ ធ្វើឱ្យរាជរដ្ឋាភិបាលកំណត់បាននូវរូបមន្តដែលប្រើប្រាស់សម្រាប់វិភាជន៍ថវិកាឱ្យឃុំ សង្កាត់ចំនួនយ៉ាងតិច ២.៨% នៃចំណូលចរន្តថវិការដ្ឋ។ ថវិកាដែលផ្តល់ឱ្យឃុំ សង្កាត់ ដើម្បីប្រើប្រាស់ក្រោមឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ទោះជាយ៉ាងណា ថវិកាដែលផ្តល់សម្រាប់ឃុំ សង្កាត់ គឺនៅតែមានចំនួនតិចនៅឡើយ ជាពិសេសសម្រាប់ឃុំ សង្កាត់ក្រីក្រ។ ថវិកាឃុំ សង្កាត់ដែលពុំមានជីវភាពធូរធារ ថវិកានេះបើប្រាស់ក្នុងដំណើរការរដ្ឋបាល និងអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ តែសម្រាប់គាំទ្រសកម្មភាពអប់រំ សេវាសុខភាព និងជួយជនក្រីក្រ គឺនៅមានកម្រិត ដែលមិនអាចបំពេញតម្រូវការរបស់ប្រជាពលរដ្ឋបានល្អនោះទេ។ ដូច្នេះរាជរដ្ឋាភិបាលគួរតែបន្ថែមថវិកាសម្រាប់ឃុំ សង្កាត់ ជាពិសេសសម្រាប់ឃុំ សង្កាត់ដែល

ក្រីក្រគឺត្រូវការខ្លាំង ដើម្បីធ្វើការអភិវឌ្ឍ ការផ្គត់ផ្គង់សេវាមណ្ឌលសុខភាព សេវាអប់រំ និងការលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ឱ្យមានភាពល្អប្រសើរ។

### ៤.១.៦. ភាពក្រីក្រ

កំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ បានធ្វើឱ្យឃុំ សង្កាត់មានការរីកចម្រើនលូតលាស់យ៉ាងឆាប់រហ័ស។ ប្រជាជនមានជីវភាពធូរធារជាងមុន ដោយសារតែកាត់បន្ថយការចំណាយទៅលើតម្លៃសេវាសាធារណៈ សេវាអប់រំ សេវាសុខភាព។ ឆ្លងតាមការសិក្សាស្រាវជ្រាវ អត្រានៃភាពក្រីក្ររបស់ប្រទេសកម្ពុជា មានការថយចុះ ដែលសូម្បីបរទេសក៏សរសើរដែរ។

សរុបមកយោងតាមការសិក្សាស្រាវជ្រាវ ឃើញថាឃុំ សង្កាត់ នៅមិនទាន់អាចអនុវត្តទៅតាមគោលនយោបាយវិមជ្ឈការទាំងស្រុងបានទេ។ បើក្រឡេកទៅមើលទ្រឹស្តី ក្រុមប្រឹក្សាមិនត្រឹមតែតំណាងឱ្យប្រជាពលរដ្ឋប៉ុណ្ណោះ តែថែមទាំងជាភ្នាក់ងាររបស់ថែមទៀត។ ដូច្នេះក្រុមប្រឹក្សា ចង់ឬមិនចង់ ត្រូវតែអនុវត្តតាមការណែនាំពីរដ្ឋបាលកណ្តាល។ ដូចជាផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវអនុម័តដោយក្រុមប្រឹក្សា ប៉ុន្តែត្រូវកែសម្រួលទៅតាមការណែនាំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើមានចំណុចដែលរដ្ឋមន្ត្រីមិនយល់ស្រប។ មួយវិញទៀតផ្នែកហិរញ្ញវត្ថុ ឃុំ សង្កាត់គឺត្រូវពឹងផ្អែកទៅលើថវិការបស់រដ្ឋផ្តល់ឱ្យច្រើនជាង ថវិកាដែលឃុំ សង្កាត់រកបាន។ ហេតុដូចនេះឃុំ សង្កាត់ មិនចេះតែធ្វើសកម្មភាពទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋទាំងស្រុងបានទេ។ និយាយរួមទៅប្រព័ន្ធវិមជ្ឈការឃុំ សង្កាត់ ត្រូវបានលាយឡំ និងគាំទ្រដោយវិសមជ្ឈការនៅឡើយទេ។

## ៤.២. របកគំហើញ

### ៤.២.១. ចំណុចខ្លាំង

ជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ បានបង្ហាញឱ្យឃើញចំណុចខ្លាំងនៃកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ដូចជា៖

- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ បានជួយបង្កើនរបបនយោបាយសេរីពហុបក្ស ជាពិសេសក្រុមប្រឹក្សាពហុបក្ស នៅកម្រិតមូលដ្ឋានតាមរយៈការបោះឆ្នោត។
- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ បានកសាងនូវរចនាសម្ព័ន្ធរបស់រដ្ឋ នៅកម្រិតមូលដ្ឋានឡើងវិញ ដែលកន្លងមកមិនត្រូវបានគេយកចិត្តទុកដាក់ដោយសារតែអស្ថេរភាពនយោបាយ និងសង្គ្រាមស៊ីវិល។

- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ ផ្តល់ឱ្យប្រជាពលរដ្ឋនូវសិទ្ធិ អំណាច ដែលត្រូវប្រើប្រាស់តាមរយៈតំណាង ហើយប្រជាពលរដ្ឋមានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ក្នុងវិស័យសាធារណៈច្រើនជាងមុន។
- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ បានកំពុង ចូលរួមក្នុងសកម្មភាពលុបបំបាត់អំពើពុករលួយ
- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ បានធ្វើឱ្យលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាកាន់តែរឹងមាំ ហើយសេដ្ឋកិច្ចកាន់តែរីកចម្រើន ដោយចេញពីភាពធូរធាររបស់ប្រជាពលរដ្ឋ។
- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ បានផ្តល់នូវការអភិវឌ្ឍយ៉ាងឆាប់រហ័ស ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធនៅមូលដ្ឋានឃុំ សង្កាត់នីមួយៗ
- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ ជាការដាស់ស្មារតីរបស់អ្នករដ្ឋបាលទាំងឡាយដែលផ្តល់សេវាជូនប្រជាពលរដ្ឋ មិនត្រូវប្រើប្រាស់នូវឥរិយាបថ ឬអាកប្បកិរិយារើសអើង និងគោរពតាមអាទិភាពនៃប្រជាពលរដ្ឋដែលមកមុន។
- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ បានចូលរួមលុបបំបាត់នូវអំពើពុករលួយ ដែលកន្លងមកប្រជាពលរដ្ឋតែងតែរអ៊ូរទាំពីភាពយឺតយ៉ាវនៃការផ្តល់សេវា តែបច្ចុប្បន្នមានល្អប្រសើរច្រើន។
- កំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់ បង្កើននូវប្រសិទ្ធភាពការងាររបស់ឃុំ សង្កាត់។

### ៤.២.២. ចំណុចខ្សោយ

តាមការសិក្សាស្រាវជ្រាវ ឃើញថាកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ ក៏នៅតែមានចំណុចខ្សោយដូចជា៖

- ការអភិវឌ្ឍឃុំ សង្កាត់នៅទូទាំងប្រទេសពុំភាពស្មើគ្នានោះទេ។ ភាគច្រើនសង្កាត់ មានការរីកចម្រើនជាងឃុំ ព្រោះសង្កាត់គឺនៅក្នុងរាជធានី ក្រុង ដែលមានប្រជាជនរស់នៅមានមុខរបរអាជីវកម្មច្រើន ឯឃុំខ្លះនៅតំបន់ជនបទ ឬតំបន់ដាច់ស្រយាលមានជីវភាពក្រីក្រ ហើយប្រជាជន ក៏មានភាពក្រលំបាកដែរ។
- ខ្វះខាតការផ្សព្វផ្សាយព័ត៌មានឱ្យប្រជាពលរដ្ឋបានដឹងឱ្យទូលំទូលាយ ពីកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ ព្រោះបើសូម្បីតែសមាជិកក្រុមប្រឹក្សាធម្មតា មិនសូវយល់ដឹងច្បាស់លាស់ផង ឯប្រជាពលរដ្ឋវិញគឺកាន់តែមិនដឹងអ្វីទាំងអស់។ ហេតុដូចនេះប្រជាពលរដ្ឋ នៅតែមិនដឹងពីផលប្រយោជន៍នៃការចូលរួមរបស់ខ្លួន នៅវេទិកាសាធារណៈ និងផែនការអភិវឌ្ឍន៍នានារបស់ឃុំ សង្កាត់ដែរ។

- សមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅមានកម្រិត ដែលមិនអាចយល់ច្បាស់ពីកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់។
- ឥរិយាបថរបស់ក្រុមប្រឹក្សា ជាពិសេសក្រុមប្រឹក្សាសង្កាត់ ហាក់ដូចជាមិនទាន់មានភាពទន់ភ្លន់នៅឡើយ និងមិនបានត្រួតពិនិត្យ និងវាយតម្លៃការងាររបស់មន្ត្រីក្រោមឱវាទ។
- ប្រជាពលរដ្ឋ ដែលរស់នៅតាមឃុំ សង្កាត់នីមួយៗ ជាពិសេសប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់នៃរាជធានីភ្នំពេញ មិនដែលបានស្គាល់ ឬជួបមុខតំណាងរបស់ខ្លួនឡើយ។

# សេចក្តីសន្និដ្ឋាន

រដ្ឋបាលឃុំ សង្កាត់ ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ តាំងពីឆ្នាំ២០០១ មកម្លេះ។ ការងារក្នុងឃុំ សង្កាត់ ត្រូវដឹកនាំដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកើតចេញពីការបោះឆ្នោតរបស់ប្រជាពលរដ្ឋ ហើយជាតំណាងឱ្យប្រជាពលរដ្ឋ បម្រើផលប្រយោជន៍ប្រជាពលរដ្ឋ។ គោលបំណងរបស់ឃុំ សង្កាត់ គឺត្រូវធ្វើការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅតាមមូលដ្ឋាននីមួយៗឱ្យបានរឹងមាំ និងជម្រុញអភិវឌ្ឍសេដ្ឋកិច្ចនៅតាមមូលដ្ឋាននីមួយៗផងដែរ។ ការងារនេះត្រូវការរយៈពេលយូរ ក្នុងការជម្រុញ និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់រដ្ឋបាលឃុំ សង្កាត់ ឆ្ពោះទៅសម្រេចគោលបំណងដោយជោគជ័យ។

ដើម្បីសម្រេចនូវគោលបំណងនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការធ្វើកំណែទម្រង់វិមជ្ឈការថ្នាក់ឃុំ សង្កាត់នេះ ដោយផ្តោតទៅលើកំណែទម្រង់គោលការណ៍សំខាន់ៗសម្រាប់ឱ្យរដ្ឋបាលឃុំ សង្កាត់នីមួយៗប្រកាន់ខ្ជាប់។ ដោយសារការមើលឃើញពីបញ្ហាដែលកើតឡើង នៅពេលដែលឃុំ សង្កាត់មានដំណើរការ និងធ្វើសកម្មភាពអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។ ដោយសារតែក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវឆ្លងកាត់បោះឆ្នោត ជាសកល ដោយសេរី ពីប្រជាពលរដ្ឋនៅទូទាំងប្រទេស សម្រាប់ជ្រើសរើសបេក្ខភាពដែលជាសមាជិកមកពីគណបក្សនយោបាយនានា ឱ្យក្លាយជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ។ ដូច្នេះអ្នកដែលជាប់ឆ្នោត គឺត្រូវធ្វើការបម្រើប្រជាជន ដោយមិនរើសអើង ប្រកាន់និន្នាការនយោបាយណាមួយឡើយ។ ភាពជាតំណាងរបស់ប្រជាពលរដ្ឋ គឺត្រូវមានការឆ្លើយតបគ្រប់តម្រូវការរបស់ប្រជាពលរដ្ឋ ទៅតាមសមត្ថភាព និងលទ្ធភាពរបស់ក្រុមប្រឹក្សានីមួយៗ។ រាល់ការបំពេញតម្រូវការទាំងនោះ ក្រុមប្រឹក្សាត្រូវធានាថាគ្រប់សេវា និងការងារទាំងឡាយដែលផ្តល់ឱ្យប្រជាពលរដ្ឋ គឺត្រូវភ្ជាប់មកជាមួយនូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាពការងារ។ គណនេយ្យភាព តម្លភាព និងប្រសិទ្ធភាពការងារនេះ នឹងធ្វើឱ្យឃុំ សង្កាត់អាចសម្រេចនូវគោលបំណងពង្រឹងលទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។ ការអភិវឌ្ឍឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗជារៀងរាល់ឆ្នាំតែងតែរៀបចំឡើងនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ ផែនការអភិវឌ្ឍន៍នេះ ត្រូវបានគាំទ្រថវិកា ដោយមូលនិធិឃុំ សង្កាត់ ដែលឃុំ សង្កាត់នីមួយៗរកបាន និងថវិកាដែលបានមកពីរដ្ឋ ដែលពីមួយឆ្នាំ ទៅមួយឆ្នាំមានការកើនឡើងជាលំដាប់។ ក្រៅពីនេះមូលនិធិឃុំ សង្កាត់ ក៏ទទួលបានពីដៃគូរអភិវឌ្ឍន៍នានាបន្ថែមពីលើនេះផងដែរ។ ដោយមានការគាំទ្រពីរាជរដ្ឋាភិបាលផង និងដៃគូរអភិវឌ្ឍន៍ផង ធ្វើឱ្យដំណើរការអភិវឌ្ឍន៍ឃុំ សង្កាត់ មានភាពល្អប្រសើរជាងមុន ជាពិសេសគម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គឺមាន

ច្រើនគួរឱ្យកត់សម្គាល់។ ទន្ទឹមនឹងការរីកចម្រើននេះ ឃើញថាស្ថានភាពរបស់ប្រជាជនសព្វថ្ងៃ ក៏មានភាពល្អប្រសើរជាងមុន ហើយកំណើននៃការចូលរួមរបស់ប្រជាពលរដ្ឋក្នុងវិស័យសាធារណៈក៏មានការកើនឡើងដែរ ដែលនេះបង្ហាញថា លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាកំពុងតែមានការរីកចម្រើន និងកាន់តែរឹងមាំ។

ថ្វីបើកំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ មានដំណើរការល្អ និងទទួលបាននូវសមិទ្ធផលដូចដែលបានបកស្រាយខាងលើ។ ប៉ុន្តែការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នៅទូទាំងប្រទេស គឺមិនដូចគ្នាទេ។ ភាគច្រើនឃុំ សង្កាត់ ដែលនៅក្នុងរាជធានី ឬ/និងតំបន់ទីប្រជុំជន មានជីវភាពធូរធារ ជាងឃុំ សង្កាត់ ដែលនៅឆ្ងាយពីរាជធានី ឬ/និងតំបន់ទីប្រជុំជន ជាពិសេសនៅតំបន់ដាច់ស្រយាលជាដើម។ ហើយរដ្ឋបាលឃុំ សង្កាត់បច្ចុប្បន្ន មិនមែនអនុវត្តតាមគោលនយោបាយវិមជ្ឈការទាំងស្រុងនោះទេ តែត្រូវលាយឡំជាមួយនឹងគោលនយោបាយវិសហមជ្ឈការនៅឡើយទេ។

# អនុសាសន៍

កំណែទម្រង់វិមជ្ឈការឃុំ សង្កាត់ ត្រូវបានធ្វើអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ បានផ្តល់នូវលទ្ធផលល្អប្រសើរ ដែលជាក់ស្តែងអាចសង្កេតឃើញនៅតាមបណ្តាឃុំ សង្កាត់ ដែលរស់នៅសព្វថ្ងៃ។ លទ្ធផលដែលទទួលបាននេះ មិនទាន់ចាត់ទុកថាជាជោគជ័យមួយ ដែលប្រជាជនចង់បានដែរ។ ដូច្នេះក្នុងនាមខ្ញុំ ជាពលរដ្ឋរស់នៅប្រទេសកម្ពុជា សូមបញ្ចេញមតិយោបល់ដូចតទៅ៖

- រាជរដ្ឋាភិបាល ដែលតាមរយៈក្រសួង ស្ថាប័ន និងអង្គភាពនានា គួរតែពិចារណាផ្តល់នូវមុខងារបន្ថែមទៀតដល់រដ្ឋបាលឃុំ សង្កាត់ ដោយភ្ជាប់ជាមួយធនធាន និងការបណ្តុះបណ្តាលដល់ក្រុមប្រឹក្សា និងបុគ្គលិកឃុំ សង្កាត់។
- រាជរដ្ឋាភិបាល គប្បីគួរតែបន្ថែមខ្ទង់ថវិកាឱ្យបានច្រើនដល់ឃុំ សង្កាត់ ជាពិសេសឃុំ សង្កាត់ដែលក្រីក្រ ដើម្បីអភិវឌ្ឍនៅមូលដ្ឋានឱ្យបានឆាប់រហ័ស និងការឆ្លើយតបចំពោះតម្រូវរបស់ប្រជាពលរដ្ឋឱ្យកាន់តែច្រើនឡើង។
- គណបក្សនយោបាយណា ដែលទទួលបានអាសនៈ ក្នុងពេលបម្រើការងារជាក្រុមប្រឹក្សាឃុំ សង្កាត់ សូមមេត្តាគិតដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋជាធំ និងមិនគួរប្រកាន់និន្នាការនយោបាយជាមួយសមាជិកក្រុមប្រឹក្សាណាមួយ ឬជាប្រជាពលរដ្ឋខ្លួនឯង។
- ក្រុមប្រឹក្សាឃុំ សង្កាត់ គួរតែត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកឃុំ សង្កាត់ ថាតើបានប្រើប្រាស់ឥរិយាបថបែបណាខ្លះចំពោះប្រជាពលរដ្ឋ នៅពេលដែលប្រជាពលរដ្ឋមកសាកសួរព័ត៌មាន ឬមកប្រើប្រាស់សេវា។

# គន្ថនិទ្ទេស


***ច្បាប់និងលិខិតបទដ្ឋានគតិយុត្តិ***

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៥, ១៩ មីនា ២០០១។

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់, លេខ នស/រកម/០៣០១/០៤, ១៩ មីនា ២០០១។

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥, លេខនស/រកម/១២១៤/០២៦, ១៨ ធ្នូ ២០១៤។

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦, លេខនស/រកម/១២១៥/០១៦, ១៧ ធ្នូ ២០១៥។

អនុក្រឹត្យស្តីពីការផ្ទេរធនធានពីថវិការដ្ឋជូនមូលនិធិឃុំ សង្កាត់, លេខ ៩៦៥ អនក្រ.បក, ១១ កក្កដា ២០១៣។

ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, លេខ៣៨៥៦ប្រ.ក, ០២ ធ្នូ ២០១៣។

ប្រកាសស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ នៃនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, លេខ១៩៥០ ប្រ.ក, ០៧ ឧសភា ២០០២។

សេចក្តីជូនដំណឹងស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ របស់សាលាខេត្តបន្ទាយមានជ័យ, លេខ ៣៧៣ សជណ, ០៥ កញ្ញា ២០១៣។

សេចក្តីជូនដំណឹងស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ របស់សាលាខេត្តបាត់ដំបង, លេខ ៩៧ សជណ, ១៧ កញ្ញា ឆ្នាំ២០១៣។

សេចក្តីជូនដំណឹងស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤ របស់សាលារាជធានីភ្នំពេញ, លេខ ១៧ សជណ, ១២ កញ្ញា ឆ្នាំ២០១៣។

***សៀវភៅ***

អ៊ុង ចំរើន. *សិក្ខាប័ននីតិរដ្ឋបាល*, បោះពុម្ពលើកទី១. ភ្នំពេញៈ ភ្នំពេញ, ២០១១។

***ឯកសារបង្រៀន***

បណ្ឌិត សឿន សោភ័ណ និងបណ្ឌិត សយ រាសី. "អភិបាលកិច្ចសាធារណៈ." ឯកសារបង្រៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៤-២០១៥។

### *ឯកសាររបាយការណ៍*

ប្រធានក្រុមការងារវិមជ្ឈការ វិសហមជ្ឈការនិងសិទ្ធិកុមារក្រសួងផែនការ. *អត្រាភាពក្រីក្រតាមបណ្តាឃុំសង្កាត់ក្រុងស្រុកខណ្ឌ និងខេត្តរាជធានី*. ភ្នំពេញ៖ ក្រសួងផែនការ, មេសា ២០១៥។

ស ខេង. *របាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអនុវត្ត៣ឆ្នាំដំបូង(ផអ៣) ក្នុងអំឡុងឆមាសទី១ ឆ្នាំ២០១២*. ភ្នំពេញ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កក្កដា ២០១២។

យិន ម៉ាលីណា. *របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំឆ្នាំ២០១០ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន*. លេខ០០៩លស/រ.ម. ភ្នំពេញ៖ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, ១១ កុម្ភៈ ២០១១។

យិន ម៉ាលីណា. *របាយការណ៍ស្តីពីសមិទ្ធផលការងាររបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានប្រចាំឆ្នាំ ២០១២*. លេខ០៤១របក/រម. ភ្នំពេញ៖ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, មីនា ២០១៣។

យិន ម៉ាលីណា. *របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំឆ្នាំ២០១១ របស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន*. លេខ០៥៧របក/រ.ម. ភ្នំពេញ៖ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន, ២៦ ធ្នូ ២០១១។

### *ព្រឹត្តិបត្រ*

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. *ព្រឹត្តិបត្រព័ត៌មាន*. ឆ្នាំទី១, លេខ១ (២០១៥)។

អង្គការផេក. *ព្រឹត្តិបត្រលើកទី៩គម្រោងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ*, លេខ៩ (២០១៥)។

ហេង សីហា, គឹម សេតារា និងសូ សុខប៊ុនធឿន. *អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យក្នុងប្រព័ន្ធនយោបាយបែបកូនកាត់៖ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងបរិបទប្រទេសកម្ពុជា*, លេខ១៤ (២០១១)។

### *ឯកសារអេឡិចត្រូនិក និងឯកសារជាភាសាអង់គ្លេស*

The Ministry of Planning. *Poverty Estimate in 2012 in Cambodia*. http://www.mop.gov.kh/Projects/tabid/148/Default.aspx (ថតចម្លងថ្ងៃទី១៦ មិថុនា ២០១៦)។

គណៈកម្មធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០១៣, ( 2013 Contractor Pre-qualification ).

http://www.ncdd.gov.kh/km/media-center/announcement/31-contractor-2013 (ថតចម្លង ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦)។

នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន. ២០១២. *វគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់សេវាសង្គមប្រកបដោយសមធម៌.* សៀមរាប៖ ០១ វិច្ឆិកា. http://gda-interior.gov.kh/index.php?option=com_content&view=article&id=110%3Aunicef-traning-at-siem-reap&catid=1%3Ageneral&Itemid=92&lang=kh (ថតចម្លងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៦)។

ខុមែប្រែហ្វល. ២០០៨. *ស្វ័យភាពក្រុមប្រឹក្សាឃុំ-សង្កាត់ និងគោលនយោបាយវិមជ្ឈការ.* ភ្នំពេញ៖ ០៨ កញ្ញា. http://kh.cisa.org.kh/index.php?option=com_content&task=view&id=776&Itemid=31(ថតចម្លងថ្ងៃទី២០ មិថុនា ២០១៦)។

ពាណិជ្ជកម្មកម្ពុជា. ២០១៥. *ធនាគារពិភពលោក៖កំណើនសេដ្ឋកិច្ចកម្ពុជានៅល្អប្រសើរខណៈអត្រាភាពក្រីក្រធ្លាក់ចុះយ៉ាងលឿន.* ៣ វិច្ឆិកា. http://business-cambodia.com/ធនាគារពិភពលោក៖-កំណើនសេដ្ឋ/(ថតចម្លងថ្ងៃទី១៦ ខែ០៦ ឆ្នាំ២០១៦)។

Sherif Rushdyç Achiecing Cambodia's Millennium Development Goals—Gap Analysis. 2009. October 15 ។

Sinaenglish. 2015. *World Bank vice president hails Cambodia's growth, poverty reduction.* http://english.sina.com/2015/1102/861186.html(ថតចម្លងថ្ងៃទី១៦ ខែ០៦ ឆ្នាំ២០១៦)។

### *ផ្សេងៗ*

រាជរដ្ឋាភិបាលកម្ពុជា. *ក្របខណ្ឌយុទ្ធសាស្ត្រស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ.* ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ១៧ មិថុនា ២០០៥។

រាជរដ្ឋាភិបាលកម្ពុជា. *កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ២០១០-២០១៩.* ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, ២៨ ឧសភា ២០១០។

រាជរដ្ឋាភិបាលកម្ពុជា. *កម្មវិធីនយោបាយ៖របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា.* ភ្នំពេញ៖ រាជរដ្ឋាភិបាលកម្ពុជា, កញ្ញា ២០១៣។

ក្រសួងមហាផ្ទៃ. *អភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់.* ភ្នំពេញ៖ ក្រសួងមហាផ្ទៃ, វិច្ឆិកា ២០០៥។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. *ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទីពីរ(២០១៥-២០១៧) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាម*

*បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.* ភ្នំពេញ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, ធ្នូ ២០១៤។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. *ផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ.* ភ្នំពេញ៖ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កក្កដា ២០១៣។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ. *ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ.* ភ្នំពេញ៖គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

# ឧបសម្ព័ន្ធ